# ប្រាសាទព្រះវិហារ



បណ្ឌិត ហង់ ជួន ណារ៉ុន




២០០៩

រូបនៅលើទំព័រទី១ គឺ «**គោបុរៈទី៥នៃប្រាសាទព្រះវិហារ**» (ថតដោយ **ហង់ ជួន ណារ៉ុន**) ។

# ប្រាសាទព្រះវិហារ

បណ្ឌិត ហង់ ជួន ណារ៉ុន

ភ្នំពេញ ២០០៩




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មតិយោបល់ និង សេចក្តីសន្និដ្ឋានទាំងឡាយ

គឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ដោយមិនឆ្លុះបញ្ចាំងនូវជំហរផ្លូវការ

របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិឡើយ

**(ហង់ជួន ណារ៉ុន)**

**«ថវិកាដែលបានមកពីការលក់សៀវភៅ**

# ប្រាសាទព្រះវិហារ

**នឹងយកទៅជួយឧបត្ថម្ភការងារអភិរក្សប្រាសាទព្រះវិហារដោយអាជ្ញាធរព្រះវិហារ»**

# ផែនទីខេត្តព្រះវិហារ



ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនទៅដល់បុព្វការីជន **កម្ពុជា** ទាំងអស់

ដែលខិតខំបូជាញើសឈាម ដោយមិនខ្លាចនឿយហត់

ដើម្បីកិច្ចអភិវឌ្ឍន៍ និង វិបុលភាព

នៃមាតុភូមិ **កម្ពុជា** យើង

ជាពិសេស

ដល់

វៀមច្បងនៃ

**កងកម្លាំងប្រដាប់អាវុធ**

ដែលបានពលីជីវិតដើម្បីការពារជាតិមាតុភូមិ

ក្នុងគោលដៅថែរក្សាវប្បធម៌ និង អារ្យធម៌ខ្មែរអោយបានគង់វង់

ទុកដល់កូនចៅ **កម្ពុជា** ជំនាន់ក្រោយ

**បោះពុម្ពលើកទី ១**

**© រក្សាសិទ្ធិ គ.ស. ២០០៩**

**ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ ព្រះវិហារ**

**បោះពុម្ពនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**លេខអ ១៣: ៩៧៨-៩៩៩៥០-៩៩០-២-២**

ISBN-13: 978-99950-990-2-2

Copyright © 2009

All rights reserved

## **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
## **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រាសាទព្រះវិហារ** គឺជាសម្បត្តិវប្បធម៌ដែលមិនអាចកាត់ថ្លៃបាន ដែលបុព្វបុរសយើងបានបន្សល់ទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយ និងមនុស្សជាតិ ។ ប្រាសាទ **ព្រះវិហារ** ក៏ដូចជាប្រាសាទដទៃទៀតដ៏ច្រើនលើសលប់នៃអាណាចក្រខ្មែរ គឺជារូបបំព្រួញនៃភាពរុងរឿងរបស់សង្គមខ្មែរបុរាណ និងជានិមិត្តរូបនៃភាពកំពូលរបស់អារ្យធម៌ខ្មែរ និងភាពឧស្សាហ៍ព្យាយាមរបស់ជនជាតិខ្មែរដែលបានប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបសម័យនោះ ដើម្បីកសាងនូវប្រាសាទដ៏ល្អឥតខ្ចោះ សម្រាប់ឧទ្ទិសដល់អាទិទេព គឺ **ព្រះសិវៈ** ។ **ប្រាសាទព្រះវិហារ** ត្រូវបានសាងសង់ឡើងជាច្រើនដំណាក់កាល ចាប់ផ្តើមសាងសង់ដោយព្រះបាទ **យសោវរ្ម័នទី១** នៅក្នុងសតវត្សរ៍ទី ៩ និងបញ្ចប់ដោយព្រះបាទ **សូរ្យវរ្ម័នទី ២** ដែលជាព្រះមហាវីរៈក្សត្រដែលបានសង់ប្រាសាទ **អង្គរវត្ត** ដ៏ល្បីល្បាញក្នុងពិភពលោកយើងនេះ នៅសតវត្សរ៍ទី ១២ ។

ដើម្បីធានាឱ្យបាននូវកិច្ចការអភិរក្ស និងការគ្រប់គ្រងនូវប្រាសាទ **ព្រះវិហារ** ប្រកបដោយនិរន្តរភាព **រាជរដ្ឋាភិបាលកម្ពុជា** បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីសម្រេចឱ្យបាននូវការចុះឈ្មោះរមណីយដ្ឋានប្រាសាទ **ព្រះវិហារ** ជាទីសក្ការ ក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកនៃអង្គការ **យូណេស្កូ** នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងទៅនេះ ប្រកបដោយជោគជ័យ ។ ការចុះប្រាសាទ **ព្រះវិហារ** ក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកឆ្លុះបញ្ចាំងពីតម្លៃសកលលេចធ្លោ សារៈសំខាន់អន្តរជាតិដ៏ធំធេង និង លក្ខណៈវិសេសវិសាលនៃប្រាសាទ **ព្រះវិហារ** ជាទីសក្ការ ដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាង **ប្រាសាទ បរិស្ថានធម្មជាតិ មនុស្ស** និង **អាទិទេព** ។

ក្នុងន័យនេះ ខ្ញុំសូមអបអរសាទរចំពោះ បណ្ឌិត **ហង់ ជួន ណារ៉ុន** ដែលបានខិតខំចងក្រងសៀវភៅ **«មគ្គុទ្ទេសក៍ដើម្បីទស្សនាប្រាសាទព្រះវិហារ»** នេះឡើង ដើម្បីចូលរួមចំណែកស្រាវជ្រាវវប្បធម៌ និង អារ្យធម៌ខ្មែរ ។ ខ្ញុំសង្ឃឹមថាសៀវភៅ **«មគ្គុទ្ទេសក៍ដើម្បីទស្សនាប្រាសាទព្រះវិហារ»** នេះនឹងចូលរួមវិភាគទានក្នុងការបំផុសឱ្យយុវជន យុវនារី និង ប្រជាជនកម្ពុជាយើងបានយល់ដឹងថែមទៀតពីមរតកវប្បធម៌ដ៏ថ្លៃថ្លារបស់យើង និងស្វែងយល់ឱ្យកាន់តែច្បាស់នូវគំនិត និង ទស្សនៈដែលបង្កប់នៅពីក្រោយស្នាដៃប្រកបដោយទេព្យកោសល្យខ្ពស់ និងសិល្បារម្មណ៍សាស្ត្ររបស់ស្ថាបត្យករ និង សិល្បករខ្មែរសម័យបុរាណ ។

**ហ៊ុន សែន**

# អារម្ភកថា

អារ្យធម៌ខ្មែរបានឈានដល់កម្រិតកំពូលចាប់ពីសតវត្សរ៍ទី ១១ ដល់សតវត្សរ៍ទី ១៣ ។ នៅពេលនោះ ព្រះមហាក្សត្រខ្មែរបានកសាងនូវប្រាង្គប្រាសាទជាច្រើន ដើម្បីឧទ្ទិសដល់ព្រះអាទិទេព ឬ បុព្វការីជនរបស់ព្រះអង្គ និង ដើម្បីធានាឱ្យបាននូវវិបុលភាព និង ឯកភាពជាតិខ្មែរ ។

ប្រាសាទ **ព្រះវិហារ** ត្រូវបានកសាងឡើងនៅលើកំពូលភ្នំដងរែកដ៏ខ្ពស់ស្កឹមស្កៃ ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ ប្រមាណជា ៤០០ គីឡូម៉ែត្រ ខាងជើងរាជធានីភ្នំពេញ និង ១៤០ គីឡូម៉ែត្រ នៅទិសឦសាននៃបុរី **អង្គរ** នៅជាប់នឹងព្រំប្រទល់ជាមួយព្រះរាជាណាចក្រថៃឡង់ ។

ប្រាសាទ **ព្រះវិហារ** មិនមែនអាចសង់ហើយ ក្នុងរយៈពេលតែមួយថ្ងៃទេ ។ ប្រាសាទនេះត្រូវបានសាងសង់ឡើងដំបូង បន្ទាប់មកត្រូវបានសង់បន្ថែមហើយបន្ថែមទៀត ដោយព្រះមហាក្សត្រខ្មែរជាច្រើនអង្គ សម្រាប់ជាទីបូជនីយដ្ឋានរបស់ប្រជាជនខ្មែរ ។ ប្រាសាទ **ព្រះវិហារ** ត្រូវបានចាប់ផ្ដើមសាងសង់ឡើងនៅក្នុងសតវត្សរ៍ទី ៩ នៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី២** (គ.ស.៨០២-គ.ស.៨៥០) នៅពេលដែលបុត្ររបស់ព្រះអង្គគឺព្រះអង្គម្ចាស់ **ឥន្ទ្រាយុទ្ធ** បានយកសិវលិង្គ **ស្រីសិខរិស្វរ** ពី **លិង្គបុរី** (វត្តភូ) មកតម្កល់លើភ្នំព្រះវិហារ ។ ព្រះបាទ **យសោវរ្ម័នទី ១** (៨៨៩-៩១០) បានសាងសង់បន្ត ដោយបានប្រើប្រាស់នូវគ្រឿងសំណង់ស្រាលៗ ដូចជាការសង់នូវប្រាង្គប្រាសាទ **ស្រី សិខរិស្វរ** ។

នៅគ.ស. ១០០២ ព្រះបាទ **សូរ្យវរ្ម័នទី ១** បានទទួលរាជាភិសេកជា **ចក្រវារ្តិន** ។ នៅឆ្នាំ ១០១៨ ដើម្បីពង្រឹងអាណាចក្រខ្មែរ ព្រះអង្គបានឧទ្ទិសព្រះសិវលិង្គដែលមានព្រះនាមថា **សូរ្យវរ្ម័នស្វរ** ។ ព្រះសិវលិង្គមួយអង្គដាក់នៅប្រាសាទ **ព្រះវិហារ** ព្រះសិវលិង្គទីពីរដាក់នៅ **ឥសានត្ថធិត** នៅមុំទន្លេមេគង្គ និង ព្រះសិវលិង្គទី ៣ ដម្កល់នៅលើភ្នំ **សូរ្យទ្រ** គឺ ភ្នំជីសូរ ។ ដូច្នេះ ប្រាង្គប្រាសាទធំជាងគេរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** មិនមែនស្ថិតនៅអង្គរទេ តែនៅលើភ្នំដងរែក គឺប្រាសាទ **ព្រះវិហារ** ។ ព្រះអង្គបានឧទ្ទិសប្រាសាទ **ព្រះវិហារ** ដល់ព្រះអាទិទេពភ្នំ គឺ **សិខរិស្វរ** និង **ភទ្រេស្វរ** ដែលព្រះអង្គយកមកពី **វត្តភូ** ដើម្បីអភិសេកទទួលអានុភាពជេស្ដានៃ **លិង្គបិវត** ។

មុនរជ្ជកាលនៃព្រះបាទ **សូរ្យវរ្ម័នទី ២** ប្រាសាទ **ព្រះវិហារ** ត្រូវបានជួសជុល កែលម្អថែមទៀត ដោយគោរពនូវវិធាននៃការសាងសង់ប្រាសាទបុរាណខ្មែរ ។

ការសាងសង់ប្រាសាទ **ព្រះវិហារ** ត្រូវបានបញ្ចប់នៅក្នុងរជ្ជកាលនៃព្រះបាទ **សូរ្យវរ្ម័នទី ២** (១១១២ - ១១៥២) ដែលជាព្រះមហាវិរៈក្សត្រដែលសាងសង់ប្រាសាទ **អង្គរវត្ត** ។ ប្រាសាទ **ព្រះវិហារ** មិនមែនត្រឹមតែជាប្រាសាទដ៏វិសេសវិសាលទេ តែជាប្រាសាទមួយមិនធម្មតា ខុសពីប្រាសាទផ្សេងៗទៀតរបស់ខ្មែរដែលសាងសង់បែមុខទៅទិសខាងកើត ។ ចំណែកប្រាសាទ **ព្រះវិហារ** វិញត្រូវបានសាងសង់បែមុខទៅទិសខាងជើង ។

ប្រាសាទ **ព្រះវិហារ** គឺជាសមិទ្ធផលឯកគ្មានពីរ ជាស្ថាបត្យកម្មដ៏ឆ្នើម មានចម្លាក់ និងក្បូរក្បាច់រចនាដ៏រស់រវើក និងស្រស់ឆើតឆាយ តាមរចនាបថផ្សេងៗនៃសតវត្សទី ១០ និង ទី ១១ ដែលបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងបរិស្ថាន ធម្មជាតិ មនុស្ស និង វត្ថុស័ក្តិសិទ្ធិនៅក្នុងលោកនេះ ។ បើមើលពីចំហៀង ឬបើមើលពីក្រោម យើងឃើញប្រាសាទ **ព្រះវិហារ** អណ្តែតលើព្នំដ៏វេហា ដែលរឹតតែញាំងឱ្យប្រាសាទ **ព្រះវិហារ** នេះកាន់តែមានភាពស័ក្តិសិទ្ធិថែមទៀត ។ ប្រាសាទនេះសាងសង់ជាដំណាក់ៗ ហើយប្រសិនបើទេសចរដើរឡើងពីដំណាក់មួយទៅ ដំណាក់មួយទៀត គេនឹងមានអារម្មណ៍ថា កំពុងដើរឆ្លងពីភពមនុស្សលោកទៅកាន់ភពក្សត្រ និង ទីបំផុតទៅកាន់ **លំនៅដ្ឋានរបស់អាទិទេព** គឺ **ព្រះសិវៈ** តែម្តង ។ ដូច្នេះហើយដោយសារតម្លៃជាសកលនេះ ទើបប្រាសាទ **ព្រះវិហារ** ត្រូវបានអង្គការ **យូណេស្កូ** បានចុះទៅក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៨ ។

សៀវភៅ **ប្រាសាទព្រះវិហារ** នេះចែកចេញជាបីជំពូក ។ ជំពូកទី១ បរិយាយអំពី **ប្រវត្តិសាស្ត្រ វប្បធម៌ និង អរិយធម៌ខ្មែរ** ។ ប្រាសាទ**ព្រះវិហារ**ត្រូវបានសាងសង់ឡើង ដោយមហាក្សត្រជាច្រើនអង្គ និងសាងសង់ឡើងតាមរចនាបថខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលសាងសង់ផ្សេងៗគ្នា ។ ដូច្នេះ ដើម្បីយល់ឱ្យបានច្បាស់ពី **ប្រាសាទព្រះវិហារ** អ្នកអានត្រូវស្គាល់ប្រវត្តិសាស្ត្រខ្មែរ រចនាបថនៃសិល្បៈខ្មែរ ហើយជាពិសេសការវិវត្តនៃប្រាសាទខ្មែរឱ្យបានច្បាស់សិន ។

ជំពូកទី២ និយាយអំពី **ទីតាំងភូមិសាស្ត្រ សាសនា និង ព្រះមហាក្សត្រខ្មែរដែលកសាងប្រាសាទព្រះវិហារ** ។ ជំពូកនេះ យើងផ្តោតទៅលើកត្តាទីតាំងភូមិសាស្ត្រ កត្តាសាសនា និងការចូលរួមវិភាគទានរបស់ព្រះមហាក្សត្រ និងព្រះរាជគ្រូរបស់ព្រះមហាក្សត្រ ក្នុងការសាងសង់ប្រាសាទព្រះវិហារ ។

ជំពូកទី៣ ពិពណ៌នាពីប្រាសាទព្រះវិហារ ។ ជំពូកទីបីគឺជា «**មគ្គុទ្ទេសក៍ដើម្បីទស្សនាប្រាសាទព្រះវិហារ**» តែម្តង ។

ខ្ញុំសូមថ្លែងនូវអំណរគុណដល់សហការីរបស់ខ្ញុំ ជាពិសេស លោក **អ៊ុង លុយណា** ដែលបានផ្តល់នូវគំនិតល្អៗ ដើម្បីកែលម្អសៀវភៅ និង ការស្រាវជ្រាវនេះឱ្យមានលក្ខណៈជាប្រព័ន្ធ ។

ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម **ជុច ភឿន** រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលបានពិនិត្យលើការសរសេរ និងបានផ្តល់នូវការកត់សម្គាល់ជាច្រើន ដែលអាចឱ្យខ្ញុំកែលម្អសៀវភៅ «**ប្រាសាទព្រះវិហារ**» នេះឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយខ្លាំងឡើង ។

ខ្ញុំសូមថ្លែងនូវអំណរគុណដល់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានផ្តល់នូវថវិកាដើម្បីបោះពុម្ពសៀវភៅនេះ ក្នុងគោលដៅចូលរួមចំណែកក្នុងការផ្សព្វផ្សាយឱ្យយុវជនជំនាន់ក្រោយបានយល់ដឹងច្បាស់ពីសិល្បៈវប្បធម៌ខ្មែរ ។

**ហង់ ជួន ណារ៉ុន**

ភ្នំពេញ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៩

# ប្រាសាទ ព្រះវិហារ

## ជំពូកទី ១

## ប្រវត្តិសាស្ត្រ វប្បធម៌ និង អរិយធម៌ខ្មែរ

### ១.១. ប្រវត្តិសាស្ត្រខ្មែរ

នៅលើទឹកដីភាគខាងកើតនៃប្រទេសកម្ពុជាមានការតាំងទីលំនៅ តាំងពីសម័យយុគថ្មមកម្ល៉េះ ។ តាមឯកសាររបស់លោក **ដេវីឌ ឆាណ្តល័រ** នៅសំរោងសែន គេបានជីកដីឃើញឆ្អឹងលលាដ៍ក្បាល ដែលបញ្ជាក់ថា មានមនុស្សមករស់នៅតាំងពីជិត ១៥០០ ឆ្នាំមុន គ.ស. ។ កំណាយដោយលោកស្រី **មូរ៉េ** នៅស្ថានីយល្អាងស្ពានក្នុង អំឡុងទស្សវត្សទី៦០ បានបញ្ជាក់ពីវត្តមានរបស់មនុស្សនៅលើទឹកដីដ៏បុរាណនេះតាំងតែពី ឆ្នាំ ៤២៩០ មុនគ.ស. ។ តាមឯកសាររបស់បណ្ឌិត **មីសែល ត្រាណេ** រដ្ឋខ្មែរតំបូងត្រូវបានបង្កើតឡើងនៅដើមសតវត្សរ៍ ទី១ នៃគ្រិស្តសករាជ ដោយព្រឹត្តិការណ៍ឥណ្ឌារូបនីយកម្មបានគ្រប់គ្រងលើរដ្ឋ និងរាជធានីតូចធំមួយចំនួន ដូចជា **ស្រេស្ឋបុរៈ** ស្ថិតនៅម៉ឺ ចម្ប៉ាសាក់នៅប្រទេសលាវ ដែលជារាជធានីដំបូងនៃសន្តតិវង្សចេនឡា មុនការបង្កើតរដ្ឋ **ឦសានបុរ** ឬ **សម្បូណ៌ព្រៃគុក** ដែលបានសាងសង់ឡើងដោយព្រះបាទ **ឦសានវរ្ម័នទី១** ។

នៅបុរេសម័យ មានតែជនជាតិធំៗចំនួនបីប៉ុណ្ណោះដែលតាំងទីលំនៅនៅអាស៊ីអគ្នេយ៍ គឺ ជនជាតិ **ខ្មែរ** ជនជាតិ **មន** និង ជនជាតិ **ចាម** ។ ជនជាតិខ្មែរ គឺជាជនជាតិដើមនៃអាស៊ីអគ្នេយ៍ ដែលតាំងទីលំនៅក្នុងជ្រលងនៃ ទន្លេ **មេគង្គ** ភាគកណ្តាល និង ភាគខាងក្រោម ។ ជនជាតិមនរស់នៅផ្នែកខាងជើង និង ខាងលិចទន្លេមេគង្គ គឺ នៅចំភូមិភាគកណ្តាលនៃប្រទេសថៃបច្ចុប្បន្ន និងនៅតាមខ្ពង់រាបកូរ៉ាត ផ្នែកខាងជើងជួរភ្នំដងរែក ។ ចំណែកឯ ជនជាតិចាមវិញ រស់នៅក្នុងភូមិភាគខាងកើត តាមបណ្តោយមាត់សមុទ្រនៃឧបទ្វីបឥណ្ឌូចិន ។ ជនជាតិថៃ និង ជនជាតិវៀតណាម គឺជាជនជាតិចំណូលថ្មី ដែលមានដើមកំណើតពីប្រទេសចិន ។ នៅក្នុងដំណើរឆ្ពោះទៅទិសខាង ត្បូង ជនជាតិថៃបានលេបយកទឹកដីរបស់មន និង ខ្មែរ ។ ទីបំផុត មនត្រូវបានភូមា និង សៀមលេបយកទឹកដីអស់ ។ ចំណែកឯជនជាតិវៀតណាមក៏ចុះមកពីទិសខាងកើត មកទិសខាងត្បូង ហើយបានលេបយកទឹកដីចម្បាអស់ដែរ ។

ប្រទេសមនមានឈ្មោះថា **អាណាចក្រទ្វារវតី** មានព្រំប្រទល់ជាប់នឹង **អាណាចក្រខ្មែរ** ហើយលាត

សន្ទឹងតាមដងទន្លេមេណាមចៅប្រាយ៉ា ។ អាណាចក្រទ្វារវតីទទួលឥទ្ធិពលពីសិល្បៈឥណ្ឌាដំបូងគេដូច អាណាចក្រខ្មែរ និង ចម្ប៉ាដែរ ។ បើវិនិច្ឆ័យទៅតាមសិល្បៈទ្វារវតី ដែលជាសិល្បវិរីកចម្រើន ជាពិសេសព្រះពុទ្ធរូប នៅវត្តប្រាមេន ខេត្តអយុធ្យាដែលមានកាលបរិច្ឆេទនៅសតវត្សទី៨នៃគ្រឹស្តសករាជ បញ្ជាក់ថាជនជាតិមនទំនងជា គោរពព្រះពុទ្ធសាសនា និកាយថេរវាទ ។

យើងឃើញថាអាណាចក្រទាំងពីរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ជាពិសេសខាងវិស័យវប្បធម៌ ដោយសារភាសារខ្មែរ និង ភាសារមនស្ថិតនៅក្នុងគ្រួសារខ្មែរ- មនតែមួយ ហើយភាសារទាំងពីរនេះមានចារនៅក្នុង សិលាចារឹករបស់ខ្មែរ ។ បើតាមមតិរបស់លោក **ធីរី ហ្សេហ្វៀរ** (Thierry Zéphir) សាស្ត្រាចារ្យនៃសាលា **លូវ៍រ** បានឱ្យដឹងថា ព្រះពុទ្ធបដិមា «**ទ្វារវតី**» ក្នុងកាយវិការបង្រៀន (វិតកិមុទ្រ) និង រូបពោធិ៍សត្វមានលក្ខណៈជាខ្មែរ សុទ្ធសាធ នៅក្នុងរចនាបថព្រៃក្មេង ឬ កំពង់ព្រះ ដូចជាគេបានរកឃើញនៅក្នុងតំបន់បានហ្វៃ ឬ តំបន់ព្រះនគរជ័យ (បច្ចុប្បន្ននៅក្នុងទឹកដីថៃ) ដែលធ្លាប់មានសិល្បៈនៃដួងព្រលឹងខ្មែរ និង បង្ហាញពីសិល្បៈទ្វារវតីផងដែរ (**ទស្ស ដំណែលខ្មែរ** លេខ ០១)។

ដោយសារតែវប្បធម៌ខ្មែរ និង វប្បធម៌មនមានលក្ខណៈស្រដៀងគ្នា និងមានប្រភពតែមួយពីឥណ្ឌាសម័យ ដំបូងនេះហើយ ជាពិសេសភាសារដែលស្ថិតនៅក្នុងគ្រួសារខ្មែរ- មនតែមួយ ដែលមានប្រភពពីភាសារសំស្ក្រឹត ទើបមានប្រវត្តិវិទូមួយចំនួនបានលើកឡើងពីអំណះអំណាងនៃ **អារ្យធម៌ខ្មែរ- មន** ហាក់បីដូចជាអារ្យធម៌តែមួយ ។ តាមមតិរបស់ខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា នៅដើមដំបូងជនជាតិខ្មែរ និង ជនជាតិមនបានចម្លងយកសិល្បៈ និង វប្បធម៌ឥណ្ឌាទាំងស្រុងតែម្តង ពីប្រភពតែមួយ ដោយមិនទាន់បានបម្លែងសិល្បៈនេះ ឱ្យក្លាយទៅជាអត្តសញ្ញាណ ជាតិរបស់ខ្លួននៅឡើយ ។ ម្យ៉ាងវិញទៀត សិល្បៈខ្មែរ និង សិល្បៈទ្វារវតីនៅមុនសម័យអង្គរបានទទួលឥទ្ធិពលពីគ្នា ទៅវិញទៅមក ។ ឧទាហរណ៍ ដូចជាស្ថានីយបុរាណវិទ្យា **ស៊ីទេព** ដែលជាស្ថានីយខ្មែរនៅក្នុងទឹកដីថៃ ដែលជា បេះដូងនៃអាណាចក្រទ្វារវតីជាតឹកតាងស្រាប់ ។

ដោយសារតែវប្បធម៌នៃជនជាតិទាំងពីរមានលក្ខណៈស្រដៀងគ្នា យើងមិនអាចកំណត់ព្រំប្រទល់រវាង អាណាចក្រទាំងពីរឱ្យបានជាក់លាក់បានទេ ហើយនៅកន្លែងខ្លះជនជាតិខ្មែរ និង ជនជាតិមនរស់នៅជាអ្នកភូមិផង របងជាមួយទៀតផង ។ ឧទាហរណ៍ តាមប្រភពរបស់លោក **ដាវីដ ស្នែលហ្គ្រោវ** នៅស្ថានីយ **មឿងសីមា** ដែលស្ថិត នៅខាងលិចនៃ **នគររាជសីមា** នៅលើខ្ពង់រាបកូរ៉ាត គេឃើញមានផ្នូរខ្មោចអាយុជាង ២០០០ ឆ្នាំ និង ឃើញមាននូវសំណល់ប្រាសាទមន និង ប្រាសាទខ្មែរផងដែរ ។

ជនជាតិខ្មែរ និង ជនជាតិមន គឺជាជនជាតិដែលភាគច្រើនរស់នៅតាមតំបន់ព្រៃភ្នំ ថ្វីត្បិតតែមានខ្លះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រស់នៅតាមមាត់សមុទ្រក៏ដោយ ។ នៅតាមមាត់សមុទ្រនៃឧបទ្វីបឥណ្ឌូចិន ភាគច្រើនជនជាតិដែលរស់នៅទីនោះ គឺជាជនជាតិចាម ដែលមានដើមកំណើតមកពីឧបទ្វីម៉ាឡេ និង ឥណ្ឌូនេស៊ី ។ ជនជាតិខ្មែរទទួលនូវឥទ្ធិពលខាងផ្នែកភាសា វប្បធម៌ និង សាសនា ដោយផ្ទាល់ពីឥណ្ឌា ជាពិសេសតាមរយៈមជ្ឈមណ្ឌលពាណិជ្ជកម្មនៅ **អូកែវ** នៃ **អាណាចក្រភ្នំ** ឬ **ហ្វូណន** ។

## ១.១.១. អាណាចក្រភ្នំ ឬ ហ្វូណន

នៅខាងដើមគ្រិស្តសករាជ **អាណាចក្រភ្នំ** ឬ **នគរភ្នំ** ដែលភាសាចិនហៅថា **ហ្វូណន** គឺជារដ្ឋសំខាន់ជាងគេនៅអាស៊ីអគ្នេយ៍ ។ ប្រវត្តិវិទូ **សឺដែស** យល់ឃើញថា រាជធានីរបស់អាណាចក្រភ្នំ គឺជា **វ្យាធបុរៈ** (បុរីនៃស្តេចទាក់ដំរី) ដែលស្ថិតនៅម្តុំបាភ្នំ និងបាណាមក្នុងខេត្តព្រៃវែងសព្វថ្ងៃនេះ ។ អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងក្លាចំនួនពីរលើក គឺលើកទីមួយនៅដើម គ.ស.ទី១ និង មួយលើកទៀតនៅដើម គ.ស.ទី ៥ ។

បើតាមការស្រាវជ្រាវរបស់បណ្ឌិត **មីសែល ត្រាណេ** វប្បធម៌ និងអារ្យធម៌ខ្មែរមានតាំងពីសម័យបុរេប្រវត្តិ ហើយបានជួបនឹងវប្បធម៌ចិន មុនការហូរចូលនៃវប្បធម៌នៃវប្បធម៌ឥណ្ឌានាដើមសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ ។ ទំនាក់ទំនងរវាងខ្មែរ និងចិនឆ្លុះបញ្ចាំងតាមរយៈស្គរមហាធិក ឬ ស្គរអារក្សហៅទឹកភ្លៀង ដែលគេបានរកឃើញនៅក្នុងចក្រភពបុរេអង្គរ ក៏ដូចជាក្បាច់ក្បូរលម្អលើវត្ថុសិល្បៈមួយចំនួន ដូចជាជួង កាំបិត កងដៃ កងជើងជាដើម ។

**អាណាចក្រភ្នំ** គឺជាអាណាចក្រមួយតូច តែ គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏សំខាន់នៅអាស៊ីអគ្នេយ៍ ហើយកំពង់ផែ **អូកែវ** ដើរតួនាទីមួយដ៏សំខាន់នៅក្នុងពាណិជ្ជកម្មនេះ ។ ឥណ្ឌាភាវូបនីយកម្ម ឬ ការទទួលធាតុផ្សេងៗនៃវប្បធម៌ឥណ្ឌាបានកើតមានឡើងចាប់តាំងពីសតវត្សរ៍ទី ៤-៣ មុនគ្រិស្តសករាជម្ល៉េះ ក្នុងពេលជាមួយគ្នានឹងពាណិជ្ជកម្មជាមួយចិនដែរ ដោយឈរលើមូលដ្ឋាននៃការវិភាគ វត្ថុសិល្បៈបុរាណ ដូចជាអង្កាំ កុលាលភាជន៍ និងកំណត់ហេតុផ្សេងៗជាដើម ។ នរវិទូបានបែងចែកឥណ្ឌាភាវូបនីយកម្មជាពីរប្រភេទ៖ ប្រភេទទី១ គឺតាមរយៈការប្រើប្រាស់ភាសាសំស្ក្រឹត ច្បាប់ និង ព្រហ្មញ្ញសាសនា និង ប្រភេទទី ២ គឺ តាមរយៈស្រុកភូមិ ទំនៀមទម្លាប់ និងជំនឿរបស់អ្នកស្រុក ។

ការផ្សព្វផ្សាយវប្បធម៌ឥណ្ឌាប្រព្រឹត្តិទៅជាពីរដំណាក់កាល៖ ដំណាក់កាលទី១ គឺតាមរយៈពួកជំនួញដែលខិតខំរៀនសូត្រភាសាអ្នកស្រុកដើម ហើយខ្លះក៏បានរៀបមង្គលការជាមួយស្ត្រីជនជាតិដើម និង ដំណាក់កាលទី២ គឺតាមរយៈពួកបញ្ញវន្តក្នុងវណ្ណៈខ្ពស់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាណាចក្រភ្នំមានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា ។ ព្រះរាជាគង់ប្រថាប់នៅក្នុងប្រាសាទឈើ ដែលមានច្រើនជាន់ ។ ព្រះរាជាមានឋានន្តរនាមជា **ក្រុងភ្នំ** ព្រោះយកតាមភ្នំដែលព្រះអង្គគង់យាងឡើងទៅធ្វើសក្ការបូជាចំពោះព្រះ **មហេស្វរ** និងមានតម្កល់លិង្គព្រះ **គិរិស** គឺឈ្មោះព្រះឥសូរដែលសណ្ឋិតនៅលើភ្នំនោះ ។ ក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំបានចងស្ពានមេត្រីជាមួយប្រទេសធំៗ ដូចជាប្រទេសឥណ្ឌា និងប្រទេសចិន ។ កំពង់ផែ **អូកែវ** ជាកំពង់ផែដ៏ធំមួយរបស់អាណាចក្រភ្នំ ។ អ្នកប្រាជ្ញបារាំង លោក **លុី ម៉ាល្លើរ៉េ** បានធ្វើកំណាយនៅស្ថានីយ **អូកែវ** ហើយរកឃើញខឿនសំណង់ផ្សេងៗ ព្រមទាំងវត្ថុផ្សេងច្រើនទៀតមកពីចក្រភពរ៉ូម និង ឥណ្ឌា ។

អាណាចក្រភ្នំប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាផ្លូវការ ក៏ប៉ុន្តែ ភាសាខ្មែរក៏ត្រូវបានគេប្រើប្រាស់ទន្ទឹមនឹងភាសាសំស្ក្រឹតដែរ ។ ក្នុងវិស័យជំនឿសាសនា ប្រជាជននៅអាណាចក្រភ្នំបានកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌា គឺព្រាហ្មណ៍សាសនា និង ពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាដែលនាំចូលអាណាចក្រភ្នំដំបូង គឺព្រះពុទ្ធសាសនាថេរវាទ ដែលប្រើប្រាស់ភាសាសំស្ក្រឹត ។ ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានការគោរពចំពោះ **ព្រះឥសូរ ព្រះវិស្ណុ ព្រះហរិហរ (វិស្ណុ** និង **ឥសូរ** រួមគ្នា) និង **ព្រះព្រហ្ម** ។

ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបុរាណត្រូវបានសាងសង់ពីដីឥដ្ឋ ។ ខឿនសំណង់ផ្សេងៗដែលគេបានរកឃើញនៅកំពង់ផែអូកែវ និងនៅអង្គរបុរីក៏ជាសំណង់ពីឥដ្ឋ ។ ខាងផ្នែកសិល្បៈបដិមា គេបានរកឃើញព្រះពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន **ព្រះក្រឹស្ណគោវទ្ធន** ។ ស្នាដៃទាំងនេះមានលក្ខណៈជាឥណ្ឌានៅឡើយ ។

តាមប្រភពឯកសាររបស់លោក **ប៊ែណារ ហ្វីលីប ហ្គ្រោសលីយេ** អាណាចក្រភ្នំ មិនគ្រាន់តែជាអំណាចសមុទ្រ និងជំនួញប៉ុណ្ណោះទេ ។ ប្រទេសនេះបានធានាឱ្យមានធនធានកសិកម្មរបស់គេយ៉ាងច្រើនបំផុត ដោយរៀបចំទឹកដីរបស់គេបានប្រសើរ ដោយឈរលើការប្រឹងប្រែងដ៏មហិមា តាមរយៈការបង្កើតនូវប្រព័ន្ធព្រែកជីកសម្រាប់បង្ហូរទឹក និងធ្វើការស្រោចស្រពយ៉ាងប្រទាក់គ្នាចម្រុះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រាប់ដំណាំស្រូវ ។ ប្រព័ន្ធព្រែកជីកទាំងនេះប្រទាក់ក្រឡាគ្នាពីមួយទៅមួយ រួចហើយក៏បត់បែនទៅនឹងបុរី ហើយក៏បម្រើដល់ការដឹកជញ្ជូននានា ជាពិសេសសម្រាប់នាវាធំៗ ដែលអាចចូលដល់ទៅក្រុងនៅខាងក្នុង ។ ជាការពិតណាស់ នៅតាមដងផ្លូវទាំងនេះហើយ ដែលឥទ្ធិពលឥណ្ឌាបានជ្រាបចូលទៅតំបន់ខាងក្នុងបានយ៉ាងងាយ ។

ចាប់តាំងពីស.វ.ទី៦ នេះផងដែរ អាណាចក្រ **ស្រីវិជ័យ** (Srîvijaya) ដែលស្ថិតនៅមាត់សមុទ្រផ្នែកអគ្នេយ៍នៃកោះ **ស៊ូមាត្រា** បានក្លាយទៅជាមហាអំណាចជើងទឹកមួយនៃអាស៊ីភាគអគ្នេយ៍ ។ ប្រការនេះក៏ជា


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មូលហេតុមួយផងដែរនៃការធ្លាក់ចុះនៃ **អាណាចក្រភ្នំ** ។ **ស្រីវិជ័យ** គ្រប់ដណ្ដប់លើពាណិជ្ជកម្មឆ្លងកាត់ឈូងសមុទ្រ **ម៉ាឡាកា** ហើយដែលមានរាជវង្ស **សៃលេន្ទ្រ** (Sailendras) គោរពព្រះពុទ្ធសាសនាសោយរាជ្យ ។ ព្រះរាជវង្ស **សៃលេន្ទ្រ** គឺជាស្ថាបនិកប្រាសាទ **បូរបូឌួ** (Borobudur) ប្រាសាទ **ចន្ឌ សេវុ** (Çandi Sewu) និងប្រាសាទ ជាច្រើនទៀត ។ **ស្រីវិជ័យ** ដណ្ដើមបានអាណាចក្រតូចៗមួយចំនួននៅតាមមាត់សមុទ្រនៃឧបទ្វីបម៉ាឡេ ដែលពីមុនត្រូវនាំសួយសារអាករទៅឱ្យ **អាណាចក្រភ្នំ** ។

## ១.១.២. អាណាចក្រចេនឡា

ឯកសារចិនបានបញ្ជាក់ថា ចេនឡាពីដើមឡើយ គឺជាសាមន្តរដ្ឋរបស់អាណាចក្រភ្នំ ។ អាណាចក្រអំណាចអង្គុរលើកដំបូង ចាប់ផ្ដើមឡើងនៅទិសពាយ័ព្យនៃប្រទេសសៀមសព្វថ្ងៃ តាមដងទន្លេសេម៉ូន ។ អាណាចក្រចេនឡាដំបូង ខាងកើតមានព្រំប្រទល់ជាប់នឹងទន្លេមេគង្គកណ្ដាល ក្នុងតំបន់ចំបាសាក់ ក្នុងប្រទេសឡាវសព្វថ្ងៃ និងក្រចេះ និងទល់នឹងប្រទេសចាម ដែលបានទទួលឥទ្ធិពលឥណ្ឌា ។ បន្ទាប់មកមានចលនាស្ទុះចុះរបស់ខ្មែរទៅកាន់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ ។ នៅពាក់កណ្ដាលទី២ នៃ ស.វ.ទី ៦ ចេនឡាមានអានុភាពកាន់តែខ្លាំងឡើងៗ ហើយចាប់ផ្ដើមវាយលុកប្រឆាំងនឹងអាណាចក្រភ្នំ ។ អាណាចក្រចេនឡាក៏លាតសន្ធឹងតាមដងទន្លេមេគង្គ ពីសម្បូណ៌ទៅដល់កំពង់ចាម រួចហើយក៏ឆ្ពោះទៅដល់យកអាណាចក្រភ្នំជាចំណុះនៅឆ្នាំ ៥៥០ ។

អ្នកប្រាជ្ញបារាំងលោក **ប៊ែណារ ហ្វីលីប ហ្គ្រោសលីយេ** បានសរសេរថា ៖ «មហន្តរាយដែលបណ្ដាលមកពីទឹកជំនន់បានបំផ្លាញទីក្រុង និងប្រព័ន្ធបញ្ចូលទឹកក្នុងស្រែ ហើយបង្ខំឱ្យប្រជារាស្ត្រភៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់នៅភាគខាងជើង ពេលនោះកូសាំងស៊ីនក៏ក្លាយទៅជាវាលល្បប់មួយស្ងាត់ជ្រងំ ។ ប្រហែលជាឆ្លៀតឱកាសនេះហើយដែលព្រះបាទ **ភវវរ្ម័ន** បានវាយយកប្រទេសហ្វូណននៅប្រមាណឆ្នាំ ៥៥០ ដើម្បីបង្កើត **រាជាណាចក្រខ្មែរ**» ។

យ៉ាងណាមិញយើងឃើញថា ទំនាស់រាជបល្ល័ង្ក ទំនាស់ខាងសាសនា និងមហន្តរាយធម្មជាតិ គឺជាបុព្វហេតុបង្គ្រប់ទៅវិញទៅមកក្នុងចម្បាំងរវាងចេនឡា និងអាណាចក្រភ្នំ ។ នៅពាក់កណ្ដាលទី២ នៃស.វ.ទី ៦ ព្រះបាទ **ភវវរ្ម័ន** និងប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម **ចិត្រសេន** បានវាយលុកយកអាណាចក្រភ្នំ ចាប់តាំងពីខេត្តក្រចេះដល់ប៉ុរីរម្យនៅចន្លោះទន្លេមូល និងជួរភ្នំដងរែក និងដល់មង្គលបុរី ។ អាណាចក្រភ្នំក៏លើករាជធានីចេញពី **វ្យាធបុរៈ** ទៅតាំងនៅទិសខាងត្បូង គឺនៅត្រង់ **នរវរនគរ** គឺនៅត្រង់ **អង្គរបុរី** ក្នុងខេត្តតាកែវ ។

បន្ទាប់ពីព្រះបាទ **ភវវរ្ម័ន** សោយទិវង្គត ព្រះបាទ **ចិត្រសេន** បានឡើងសោយរាជ្យនៅឆ្នាំ ៦០០ ដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យកព្រះនាមថា **មហេន្ទ្រវរ្ម័ន** ។ បុត្ររបស់ព្រះអង្គ គឺព្រះបាទ **ឦសានវរ្ម័ន** បានឡើងសោយរាជ្យនៅឆ្នាំ ៦១៦ ។ ព្រះអង្គបានបញ្ចប់សង្គ្រាមជាមួយអាណាចក្រភ្នំ ដោយវាយយកបានរាជធានី **នរវរនគរ (អង្គរបុរី)** ប្រមាណនៅឆ្នាំ ៦៣០ ។ ព្រះបាទ **ឦសានវរ្ម័ន** បានតាំងរាជធានីនៅ **ឦសានបុរៈ** ដែលជារមណីយដ្ឋាន **សម្បូណព្រៃគុក** នៅក្នុងខេត្តកំពង់ធំ ដែលជារាជធានីដំបូងបង្អស់របស់នគរភ្នំ និងចេនឡារួមគ្នា ហើយដែលលេចធ្លោឡើងនៅសតវត្សទី ៧ ក្នុងដងស្ទឹងសែន ។ ប្រវត្តិវិទូបានចាត់ទុកថា **អាណាចក្រខ្មែរ** បានចាប់កកើតឡើងនៅដើមសតវត្សរ៍ទី៧នេះឯង ហើយភូមិភាគកណ្តាលនៃឥណ្ឌូចិនទាំងមូល ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់រាជវង្សវរ្ម័ន ឬ «អ្នកការពារក្សត្រប្រទេសទាំង ១០១» ។ ស្តេចដែលសោយរាជ្យក្រោយព្រះអង្គ គឺព្រះបាទ **ភវវរ្ម័នទី ២** ។ ព្រះបាទ **ជ័យវរ្ម័នទី ១ (៦៥៧- ៦៨១)** ដែលជាបុត្រព្រះបាទ **ភវវរ្ម័នទី ២** បានឡើងសោយរាជ្យនៅមុនឆ្នាំ ៦៥៧ ហើយបានសាងសង់ប្រាសាទនៅតំបន់ **វ្យាធបុរៈ** និង នៅ **វត្តភូ** ។

តាមប្រភពឯកសាររបស់លោក **អាដេម៉ារ ឡឺក្លែរ** នៅចុងសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជ ប្រទេសឥណ្ឌាមានឥទ្ធិពលយ៉ាងខ្លាំងមកលើ **អាណាចក្រខ្មែរ** ដោយសារបណ្តាក្រុមឧបនិវេសន៍ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយនៅទីនេះបន្តិចម្តងៗ គឺក្រុមឧបនិវេសន៍ហិណ្ឌូ ហើយរាជវង្សស្តេចដែលសោយរាជ្យនៅ **អាណាចក្រខ្មែរ** សុទ្ធតែជាប់អម្បូរក្សត្រិយ៍ ឬ ព្រាហ្មណ៍ និងម៉្យាងទៀតសាសនាដែលគេគោរព គឺព្រហ្មញ្ញសាសនា ឬ ព្រះពុទ្ធសាសនា ។ ច្បាប់ទម្លាប់ ប្រពៃណី ដែលគេអនុវត្ត សុទ្ធតែមានប្រភពចេញមកពីឥណ្ឌា ។ គេគោរពបូជាអាទិទេពរបស់ឥណ្ឌា គេអានសៀវភៅដែលសរសេរនៅឥណ្ឌា ។ ពួកព្រាហ្មណ៍មកតាំងទីលំនៅក្នុងឥណ្ឌូចិនដោយស្ម័គ្រចិត្ត ព្រោះអ្នកស្រុកអនុវត្តតាមទ្រឹស្តីរបស់គេ ហើយលើកកូនក្រមុំឱ្យគេទៀតផង ។

នៅដើម ស.វ.ទី៨ (៧០៦) អាណាចក្រចេនឡាត្រូវបែងចែកជាពីរ ដោយសារតែអំណាចកណ្តាលចុះខ្សោយ ÷ ភាគខាងជើងហៅថា **ចេនឡាដីគោក** ជាតំបន់ភ្នំ និង ជ្រលងភ្នំ (ប្រទេសឡាវភាគកណ្តាល) និងភាគខាងត្បូងហៅថា **ចេនឡាទឹកលិច** ដែលមានតំបន់សម្បូណ៌ដោយបឹង និងមានសមុទ្រព័ទ្ធជុំវិញ (ពីអាងទន្លេមេគង្គ ត្រង់ល្បាក់ខោន ដល់សមុទ្រ) ។ របបចេនឡាបានបែកបាក់ខ្ចាយទៅជារដ្ឋតូចៗគ្មានលំនឹង ។

ក៏ប៉ុន្តែ ការបាក់បែកផ្ទៃក្នុងនៃអាណាចក្រចេនឡាបង្កើតឱ្យមានអស្ថិរភាពនយោបាយ បណ្តាលឱ្យកងទ័ពជ្វាចូលមកលុកលុយ ហើយដាក់អាណាចក្រចេនឡាជាចំណុះ ។ នៅ ស.វ.ទី៨ (ឆ្នាំ ៧៧៤ និង ៧៨៧) រាជវង្ស **សៃលេន្ទ្រ** បានលើកគ្នាទៅវាតត្បាតឆ្នេរសមុទ្រប្រទេសចម្ប៉ា ។ ពួកជ្វាបានធ្វើដំណើរឡើងតាមទន្លេមេគង្គដល់ **សម្ភុបុរៈ** ដុតបំផ្លាញទីក្រុង ឡោមព័ទ្ធរាជវាំង ចាប់បានព្រះរាជានាម **មហីបតិវរ្ម័ន** កាត់យកព្រះសិរ ហើយយកទៅប្រទេសជ្វា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.១.៣. លទ្ធិទេវរាជ (មូលដ្ឋាននៃអរិយធម៌អង្គរ)

**ព្រះបាទជ័យវរ្ម័នទី២** បានយាងត្រឡប់ពីស្រុកជ្វា ប្រហែលជានៅ គ.ស. ៨០០ នៅពេលដែលរាជវង្ស **សៃលេន្ទ្រ** បានចុះទន់ខ្សោយ ហើយរំដោះប្រទេសជាតិឱ្យមានឥស្សរភាពឡើងវិញ និងបង្រួបបង្រួមប្រទេសឱ្យមានឯកភាពជាតិឡើងវិញ ។ ព្រះអង្គបានផ្លាស់ប្ដូររាជធានីយ៉ាងញឹកញាប់ ដើម្បីបង្រួបបង្រួមទឹកដី ដូចជានៅ **ឥន្ទ្របុរ** **កុតិ** **ហរិហរាល័យ** និងនៅ **អមរេន្ទ្របុរ** ជាដើម ។ បន្ទាប់មក ព្រះអង្គបានយាងទៅគង់លើភ្នំគូលែន (**មហេន្ទ្របវ៌ត**) ។ នៅលើកំពូលភ្នំគូលេន **ព្រះបាទជ័យវរ្ម័នទី២** បញ្ជាឱ្យព្រាហ្មណ៍ឈ្មោះ **ហិរណ្យទាម** ប្រារព្ធ «**ពិធីទេវរាជ**» ដើម្បីឱ្យប្រទេសខ្មែររួចពីចំណុះប្រទេសជ្វា ហើយអភិសេកព្រះអង្គឱ្យមានឋានៈ ជា **ចក្រវាតិន** (ស្ដេចចក្រវាល) នៅ គ.ស. ៨០២ ។

**លទ្ធិទេវរាជ** គឺការរៀបចំអភិសេក **សិវលិង្គ** ដែលគេសន្មតថា បានមកពីព្រះឥសូរតាមរយៈព្រាហ្មណ៍ ដោយមានគោលដៅដូចតទៅ៖

- ដើម្បីឱ្យ **អាត្ម័នពិសិដ្ឋ** របស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុងសេវលិង្គនោះ ដែលបានក្លាយជានិមិត្តរូបនៃទេវរាជ ។ សិវលិង្គ ដែលក្លាយជានិមិត្តរូបរបស់ជាតិ ជួយការពារអាណាចក្រខ្មែរឱ្យរួចផុតពីគ្រោះចង្រៃផ្សេងៗ ក៏ដូចជាពីសត្រូវដែលមកឈ្លានពាន ។
- ធ្វើឱ្យព្រះរាជាក្លាយទៅជាព្រះឥសូរ ។ ក្រោយពីការធ្វើពិធីអភិសេក «**ពិធីទេវរាជ**» នេះហើយ ព្រះរាជាក៏មានឋានៈ ជា **ចក្រវាតិន** (ស្ដេចចក្រវាល) ដែលជាព្រះឥសូរបែងភាគ ដែលមានអំណាចអាចគ្រប់គ្រងទៅលើសព្វសត្វ ហើយបញ្ញារបស់ព្រះរាជា គឺជាបញ្ញារបស់អាទិទេព ។ ប្រការនេះមានន័យថា ព្រះរាជាទទួលបញ្ញាដោយផ្ទាល់ពីអាទិទេព ដើម្បីគ្រប់គ្រងផែនដី ។
- ដោយព្រះឥសូរមានលំនៅនៅលើ **ភ្នំកៃលាស** សិវលិង្គដែលជាតំណាង ព្រះឥសូរផង និងជាតំណាងព្រះរាជាផង ក៏ត្រូវយកទៅតម្កល់លើភ្នំដែរ ។ ប្រសិនបើគ្មានភ្នំធម្មជាតិទេ គេត្រូវសាងប្រាសាទដែលមានខឿនច្រើនជាន់ ឱ្យមានកម្ពស់ដូចភ្នំ ហើយដែលគេហៅថា **ប្រាសាទភ្នំ** (Mountain temple)។ ប្រាសាទភ្នំនេះត្រូវស្ថិតនៅចំកណ្ដាលរាជធានី ដែលគេចាត់ទុកថា នៅចំស្នូលនៃចក្រវាល ។

ព្រះរាជបុត្ររបស់ព្រះបាទ **ជ័យវរ្ម័នទី ២** ព្រះនាម **ជ័យវធ៌ន** ឬ **ជ័យវរ្ម័នទី ៣** បានឡើយសោយរាជ្យស្នងព្រះបាទ **ជ័យវរ្ម័នទី ២** ដោយគង់នៅ **ហរិហរាល័យ** រហូតដល់ គ.ស. ៨៧៧ ។ នៅពេលដែលព្រះអង្គចូលទិវង្គត ប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម **ឥន្ទ្រវរ្ម័នទី ១** បានឡើងគ្រងរាជសម្បត្តិ ។ ព្រះអង្គបានដឹក


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បារាយណ៍ **ឥន្ទ្រតដាក** នៅខាងជើងរាជធានីមានប្រវែង ៣.០០០ ម៉ែត្រ និង ទទឹង ៨០០ ម៉ែត្រ ។ នៅឆ្នាំ ៨៧៩ ព្រះបាទ **ឥន្ទ្រវរ្ម័ន** បានកសាងប្រាសាទ **ព្រះគោ** ដើម្បីឧទ្ទិសថ្វាយចំពោះព្រះមាតា ព្រះបិតា និងជីដូនជីតា ។ នៅឆ្នាំ ៨៨១ ទ្រង់បានកសាងប្រាសាទ **បាគង** ដែលជាប្រាសាទភ្នំទីមួយសាងពីថ្មភក់សម្រាប់តម្កល់ទេវលិង្គ **ឥន្ទ្រេស្វរ** ។

## ១.២. សម័យអង្គរ

ព្រះរាជបុត្ររបស់ព្រះបាទ **ឥន្ទ្រវរ្ម័នទី ១** ព្រះនាម **យសោវរ្ម័នទី ១** បានឡើងសោយរាជ្យ ។ ព្រះអង្គបានកសាងរាជធានី **យសោធបុរ** ហើយបាននាំយកទេវរាជពី **ហរិហរាល័យ** ទៅតម្កល់ទីនោះ ។ ព្រះបាទ **យសោវរ្ម័ន** ទី ១ បានកសាងបារាយណ៍នៅទិសឦសានមានឈ្មោះថា **យសោធរតដាក** មានប្រវែង ៧ គ.ម. និង ទទឹង ១,៨ គម ។ ព្រះអង្គបានកសាង **ប្រាសាទព្រះវិហារ** ។

លុះព្រះបាទ **យសោវរ្ម័នទី ១** ចូលទិវង្គត បុត្រច្បងព្រះអង្គព្រះនាម **ហស៌វរ្ម័នទី ១** បានឡើងសោយរាជ្យពី គ.ស. ៩០០ ដល់ គ.ស. ៩២២ ។ ព្រះអង្គបានកសាងប្រាសាទ **បក្សីចាំក្រុង** ។

ចាប់ពី គ.ស. ៩២១ ព្រះបាទ **ជ័យវរ្ម័នទី ៤** បានយាងចេញពី **យសោធបុរ** ដើម្បីទៅគង់នៅ **គោកគគីរ (កោះកេរ្តិ៍)** ចម្ងាយ ៧០ គម ពីអង្គរ ហើយបានកសាង **ប្រាសាទធំ** សម្រាប់តម្កល់សេវលិង្គ **ត្រិភុវនេស្វរ** នៅ គ.ស. ៩៣១ ។

ព្រះបាទ **រាជេន្ទ្រវរ្ម័ន** ដែលជាបុត្ររបស់ប្អូនស្រីរបស់ព្រះបាទ **យសោវរ្ម័នទី ១** បានឡើងសោយរាជ្យហើយលើករាជធានីមក **យសោធបុរ** វិញ ។ ព្រះអង្គបានកសាងប្រាសាទ **មេបុណ្យខាងកើត** នៅកណ្តាលបារាយណ៍ **យសោធរតដាក** នៅ គ.ស. ៩៥២ ។ នៅ គ.ស. ៩៦១ ព្រះអង្គបានកសាងប្រាសាទ **ប្រែរូប** ដើម្បីតម្កល់សេវលិង្គ **រាជេន្ទ្រភទ្រេស្វរ** ។ ព្រះអង្គបានកសាងប្រាសាទ **ភិមានអាកាស** ផងដែរ ។

បុត្ររបស់ព្រះបាទ **រាជេន្ទ្រវរ្ម័ន** ព្រះនាម **ជ័យវរ្ម័នទី ៥** បានឡើងសោយរាជ្យនៅ គ.ស. ៩៦៨ ហើយបានកសាងក្រុងថ្មី **ជយេន្ទ្រនគរី** និង បានកសាងប្រាសាទ **តាកែវ** ។ ព្រះអង្គបានសោយទិវង្គតនៅ គ.ស. ១០០១ ហើយក្មួយរបស់ព្រះអង្គព្រះនាម **ឧទយាទិត្យវរ្ម័នទី ១** បានឡើងសោយរាជ្យ តែក៏ចូលទិវង្គតទៀតទៅ ។ បន្ទាប់មកមានការដណ្តើមរាជ្យសម្បត្តិរវាងស្តេចពីរអង្គ ។

ព្រះបាទ **សូរ្យវរ្ម័នទី ១** បានដណ្តើមបានអង្គរ ហើយឡើងសោយរាជ្យនៅឆ្នាំ ១០១០ ។ ព្រះអង្គបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កសាងបង្ហើយប្រាសាទ **ភិមានអាកាស** ប្រាសាទ **តាកែវ គោបុរ** នៃព្រះបរមរាជវាំង ប្រាសាទ **ភ្នំជីសូរ** កសាងបន្តប្រាសាទ **ព្រះវិហារ** និង **ព្រះខ័នកំពង់ស្វាយ** ។

ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** ដែលជាព្រះរាជបុត្រច្បងនៃព្រះបាទ **សូរ្យវរ្ម័នទី ១** បានឡើងសោយរាជ្យនៅ គ.ស. ១០៥០ ។ ព្រះអង្គបានកសាងប្រាសាទ **បាពួន** ដែលនៅកណ្ដាលក្រុង **អង្គរទី ២** និងបានជីក **បារាយណ៍ខាងលិច** មានប្រវែង ៨ គ.ម. និង ទទឹង ២,២ គ.ម. និងបានសាងប្រាសាទ **មេបុណ្យខាងលិច** ។ នៅពេលដែលព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** សោយទិវង្គតនៅ គ.ស. ១០៦៦ ព្រះអនុជព្រះអង្គព្រះនាម **ហស៌វរ្ម័នទី ៣** បានឡើយសោយរាជ្យ ។ តែព្រះអង្គមិនបានកសាងអ្វីទេ ដោយជាប់ធ្វើសង្គ្រាមជាមួយចាម និងដៃវៀត ហើយបានចូលទិវង្គតនៅ គ.ស. ១០៨០ ។ ព្រះបាទ **នឫបតីន្ទ្រវរ្ម័ន** បានឡើងស្នងរាជ្យពីព្រះអង្គពី គ.ស. ១០៨០ ដល់ គ.ស. ១១១៣ ។

ក៏ប៉ុន្តែ មានស្ដេចមួយអង្គទៀតបានសោយរាជ្យនៅក្រុង **មហីធរបុរ** ព្រះនាម **ជ័យវរ្ម័នទី ៦** ។ ព្រះអង្គបានបន្តសាងសង់ប្រាសាទ **ភ្នំសណ្ដក** ប្រាសាទ **ព្រះវិហារ** ប្រាសាទ **វត្តភូ** និង ប្រាសាទ **ភីម៉ៃ** (ពុទ្ធសាសនា) ។

ព្រះបាទ **សូរ្យវរ្ម័នទី ២** បានឡើងសោយរាជ្យ ដោយបង្រួបបង្រួមអាណាចក្រពីរ និងបានអភិសេកនៅ គ.ស. ១១១៣ ។ ស្នាព្រះហស្ដដ៏ធំរបស់ព្រះអង្គ គឺការសាងប្រាសាទ **អង្គរវត្ត** ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ ។ ក្រៅពីនេះព្រះអង្គបានបន្តកសាង ប្រាសាទ **ភ្នំជីសូរ** ប្រាសាទ **ភ្នំសណ្ដក** ប្រាសាទ **វត្តភូ** ប្រាសាទ **ព្រះវិហារ** ។ ព្រះអង្គបានសង់ថ្មីនូវប្រាសាទ **ព្រះពិធុរ** ប្រាសាទ **ចៅសាយទេវតា** ប្រាសាទ **ធម្មានន្ទ** និង ប្រាសាទ **បន្ទាយសំរែ** ។

ព្រះបាទ **ធរណីវរ្ម័នទី ២** ដែលជាប្អូនជីដូនមួយរបស់ព្រះបាទ **សូរ្យវរ្ម័នទី ២** បានឡើងសោយរាជ្យបន្ត។ ព្រះអង្គមានបុត្រ មួយអង្គព្រះនាម **ជ័យវរ្ម័ន** ដែលជាអនាគតព្រះបាទ **ជ័យវរ្ម័នទី ៧** ។ នៅគ.ស. ១១៦៥ មានឧត្តមមន្ត្រីម្នាក់បានជ្រែករាជ្យ ដោយយកឈ្មោះ **ត្រិភូវនាទិត្យវរ្ម័ន** តែត្រូវធ្វើគត់ដោយស្ដេចចាមព្រះនា **ជ័យឥន្ទ្រវរ្ម័ន ទី ៤** ដែលវាយយកបានក្រុងអង្គរ ។

ព្រះបាទ **ជ័យវរ្ម័នទី ៧** បានរំដោះអាណាចក្រខ្មែរពីចាម ហើយបានទទួលរាជាភិសេក នៅ គ.ស. ១១៨១ ហើយបានកសាង **អង្គរទី ៣** គឺ **អង្គរធំ** ដែលមានកំពែង មានគោបុរៈ ៥ និងមាន គូទឹកព័ទ្ធជុំវិញ និងមានប្រាសាទ **បាយ័ន** នៅចំកណ្ដាល ។ ព្រះអង្គបានកសាងប្រាសាទ **បន្ទាយក្ដី តាព្រហ្ម ព្រះខាន់ នាគព័ន្ធ តាសោម ក្រោលគោ បន្ទាយឆ្មារ** (បាត់ដំបង) **វត្តនគរ** (កំពង់ចាម) និង **តាព្រហ្ម** (បាទី) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៣. លក្ខណៈសំខាន់ៗនៃប្រាសាទបុរាណខ្មែរ

ជាទូទៅ ប្រាសាទខ្មែរត្រូវបានសាងសង់ដោយបែរមុខទៅទិសខាងកើត តាមអ័ក្សបណ្តោយទិសកើត- លិច ទៅតាមវដ្តព្រះអាទិត្យនៃចក្រវាល ។ ការកំណត់ទិសក្នុងការសាងសង់ប្រាសាទខ្មែរមានប្រភពមកពីសាសនា លោកធាតុវិទ្យា និង តារាវិទ្យា ។ ក៏ប៉ុន្តែ គេតែងតែជួបប្រទះនូវករណីលើកលែងខ្លះ ដូចជា ប្រាសាទ**អង្គរវត្ត** បែមុខទៅទិសបស្ចិម ប្រាសាទ**តោះកៀ្ត** បែមុខទៅទិសឦសាន និងប្រាសាទ**ព្រះវិហារ** បែមុខទៅទិសឧត្តរជាដើម ។ ដោយគោរពតាមលោកធាតុឥណ្ឌា ប្រាសាទខ្មែរត្រូវបានគេចាត់ទុកថា ជាតំណាងនៃចក្រវាល ។ ប្រាសាទបុរាណខ្មែរ ត្រូវបានសាងសង់ឡើង ដើម្បីឧទ្ទិសថ្វាយអាទិទេព ខាងព្រហ្មញ្ញសាសនា ដូចជាព្រះឥសូរ ឬ ព្រះវិស្ណុ ឬ ព្រះពុទ្ធសាសនា ឧទ្ទិសថ្វាយទេវរាជ ឬ ឧទ្ទិសថ្វាយបុព្វបុរសរបស់ព្រះមហាក្សត្រ ។

ការសាងសង់ប្រាសាទបុរាណមានការប្រែប្រួលទៅតាមសម័យកាល ។ នៅពេលដែលស្ថាបត្យកម្មនៃការសាងសង់ប្រាសាទបុរាណខ្មែរបានឈានដល់កម្រិតកំពូល យើងសង្កេតឃើញថា ស្ថាបត្យកម្មខ្មែរមានប្លង់ចំនួន ៣ ជាមូលដ្ឋាន គឺៈ ប្លង់រាងការេ ប្លង់រាងចតុកោណកែង និង ប្លង់រាងកាកបាទ ។ ក៏ប៉ុន្តែ នៅសតវត្សរ៍ទី ១៣ ប្រាសាទបាយ័នមានប្លង់រាងមូល ចែកជាកាំប្រាំបីហ៊ុំព័ទ្ធបន្ទប់កណ្តាល សម្រាប់តម្កល់ព្រះពុទ្ធស្តេចបដិមា ។

### ១.៣.១. គូទឹកព័ទ្ធជុំវិញប្រាសាទ

តាមទេវកថាឥណ្ឌា គូទឹកព័ទ្ធជុំវិញប្រាសាទតំណាងឱ្យមហាសាគរ ដែលជាព្រំដែននៃលំនៅស្ថានរបស់អាទិទេព និង ពិភពលោករបស់មនុស្ស ។ ជាធម្មតា មាត់ច្រាំងនៃគូទឹកព័ទ្ធជុំវិញប្រាសាទទប់ដោយដុំថ្មបាយក្រៀមដែលរៀបជាជួរៗ និង ជាថ្នាក់ៗ ។ គូទឹកនេះត្រូវបានប្រើប្រាស់ ដើម្បីដឹកជញ្ជូនថ្មទៅសាងសង់ប្រាសាទ ដោយសារតែគេអាចដឹកជញ្ជូនថ្មតាមក្បូន ទៅដាក់តាមការដ្ឋានសំណង់ប្រាសាទពីគ្រប់ទិសទាំងអស់ និងត្រូវបានប្រើប្រាស់ ជាអាងស្តុកទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និង សម្រាប់ប្រព័ន្ធស្រោចស្រពផងដែរ ។

### ១.៣.២. ព្រះលាន

ប្រាសាទខ្មែរតែងតែមានទីព្រះលាន ដែលសាងសង់នៅដើមផ្លូវចូលប្រាសាទ ឬ នៅចុងផ្លូវចូលប្រាសាទ ឬមួយក៏នៅមុខគោបុរៈ ដែលជាក្លោងទ្វារចូលប្រាសាទ ។

### ១.៣.៣. ផ្លូវចូលប្រាសាទ

ផ្លូវចូលប្រាសាទត្រូវបានសាងសង់តាមបណ្តោយអ័ក្សកើត- លិច ចំពោះប្រាសាទភាគច្រើន លើកលែងតែប្រាសាទមួយចំនួនដែលត្រូវបានសាងសង់ខុសពីវិធាននៃការសាងសង់ប្រាសាទខ្មែរ ។ នៅប្រាសាទបន្ទាយស្រី និង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទព្រះវិហារ ផ្លូវចូលប្រាសាទមានអមសងខាងដោយបង្គោលខ័ណ្ឌសីមា ។ ចំពោះផ្លូវចូលដែលសាងសង់តាមរចនាបថបាពួនវិញ បង្កាន់ដៃមានរាងខ្ពស់ជាងគេ ហើយទ្រដោយទម្រទម្រាងបួនជ្រុង ។ ចំណែកឯនៅប្រាសាទអង្គរវត្តវិញ ផ្លូវចូលប្រាង្គប្រាសាទអមទៅដោយនាគរាជមួយគូ ដែលញាំងឱ្យផ្លូវចូលនេះរឹតតែមានភាពវិសេសវិសាលថែមទៀត ។

## ១.៣.៤. កំផែងព័ទ្ធជុំវិញប្រាសាទ

កំផែងព័ទ្ធជុំវិញប្រាសាទ គឺជាតំណាងនៃភ្នំដែលខ័ណ្ឌពិភពលោក ។ ម្យ៉ាងវិញទៀត កំផែងនេះមានគោលដៅបិទបាំងទីសក្ការៈដ៏ពិសិដ្ឋនេះ កំណត់ចំនួនអ្នកដែលមកទស្សនា ដោយទុកសម្រាប់ឱ្យតែអ្នកដែលមានបុណ្យ និងធ្វើឱ្យប្រាង្គប្រាសាទមានលក្ខណៈកាន់តែអាថ៌កំបាំងថែមទៀត ។

## ១.៣.៥. កំពែងថែវ

ស្ថាបត្យករនៃប្រាសាទខ្មែរបានសាងសង់បន្ថែមនូវជញ្ជាំងមួយជាន់ទៀត បន្ថែមទៅលើកំផែងព័ទ្ធជុំវិញប្រាសាទ ដើម្បីបង្កើតឡើងនូវកំពែងថែវ ។ ថែវប្រាសាទនេះប្រក់ក្បឿង ឬ មានរៀបឥដ្ឋបន្ទុបពីលើ ហើយនៅពេលក្រោយៗមក ប្រក់ដោយដុំថ្មភក់ ។

## ១.៣.៦. គោបុរៈ

គោបុរៈ គឺជាទ្វារចូលនៃរបងទីក្រុង ឬ របងប្រាសាទ ។ ប្រសិនបើប្រាសាទមានរបងច្រើនជាន់ ឬ មានប្រាសាទដែលសាងសង់ជាច្រើនថ្នាក់ គឺគោបុរៈនៃរបងខាងក្រៅ ដែលជាគោបុរៈសំខាន់ជាគេ ។ នៅពេលដែលស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ គោបុរៈមានលក្ខណៈកាន់តែស្មុគស្មាញ រហូតដល់អាចចាត់ទុកថាជាប្រាង្គប្រាសាទតែម្ដង ។

## ១.៣.៧. ព្រះពន្លា ម៉ាន់ដាផា

នៅក្នុងស្ថាបត្យកម្មនៃប្រាសាទខ្មែរ ព្រះពន្លា **ម៉ាន់ដាផា** គឺជាអគារ ដែលពេលខ្លះមានសសរជាជួរសម្រាប់ជាទីសក្ការៈបូជា ហើយតភ្ជាប់ទៅនឹងប្រាង្គប្រាសាទកណ្ដាល ។ គេតែងប្រើប្រាស់ ព្រះពន្លា **ម៉ាន់ដាផា** នេះសម្រាប់លេងភ្លេង រាំបន់ស្រន់ដល់អាទិទេព ឬ សម្រាប់រៀបចំពិធីខាងផ្នែកសាសនា ។ ដូច្នេះហើយទើបពេលខ្លះ គេហៅព្រះពន្លា **ម៉ាន់ដាផា** ថាជាអគាររបាំ ។

### ១.៣.៨. ហោត្រៃ

ហោត្រៃ គឺជាផ្នែកមួយដ៏សំខាន់ ដែលគេតែងតែជួបប្រទះនៅក្នុងប្រាសាទខ្មែរ ។ ស្ថាបត្យករបុរាណខ្មែរតែងតែសង់អគារហោត្រៃចំនួនពីរ ដើម្បីឱ្យឆ្លុះគ្នាល្អ ។ ហោត្រៃ គឺជាកន្លែងដែលគេរក្សាទុកនូវទ្រព្យសម្បត្តិ និងគម្ពីរខាងផ្នែកសាសនានៃប្រាសាទបុរាណខ្មែរ ។

### ១.៣.៩. ប្រាង្គកណ្ដាល

ប្រាង្គកណ្ដាល គឺជាបដិសរណដ្ឋាន (Sanctuaire) សំខាន់ជាងគេនៃប្រាសាទ ដែលជាទីកន្លែងសម្រាប់ដម្កល់ទេវរាជ និងជាមជ្ឈមណ្ឌលនៃលោកធាតុ ។ ប្រាសាទបុរាណអាចមានប្រាង្គតែមួយ ឬ អាចមានប្រាង្គច្រើននៅលើខឿនតែមួយ ។ ប្រាង្គអាចមានរាងជាសាជីលើខឿនខ្ពស់ ដែលមានមួយជាន់ ឬ ច្រើនជាន់ ។ ខឿន គឺជាមូលដ្ឋាននៃប្រាសាទដែលមានច្រើនជាន់ និង មានរាងជាសាជីជាច្រើនជាន់ថ្នាក់ ។ ប្រាង្គត្រូវបានសាងសង់លើខឿនដែលមានជណ្ដើរពីរទៅបីកាំ ។ នៅចំកណ្ដាលប្រាង្គ មានដាក់រូបបដិមារទេវរាជ ដែលតម្កល់លើជើងទម្រមួយ ។ ចំពោះប្រាសាទដែលឧទ្ទិសចំពោះព្រះឥសូរ រូបបដិមារទេវរាជ គឺជាសិវលិង្គ ដែលគេសន្មតថាបានមកពីព្រះឥសូរ តាមរយៈព្រាហ្មណ៍ ហើយដែលជានិមិត្តរូបនៃទេវរាជ ។

### ១.៣.១០. ផ្តែរ

ផ្តែរទ្វារមានការវិវត្តទៅតាមរចនាបថរបស់ប្រាសាទ ។ ការវិវត្តនេះឆ្លុះបញ្ចាំងពីការទទួលយកវប្បធម៌ឥណ្ឌាមកកែច្នៃ ដើម្បីចម្រាញ់យកសិល្បៈ និងស្ថាបត្យកម្មដែលមានអត្តសញ្ញាណជាតិខ្មែរ ។ ការសិក្សាអំពីផ្តែរមានសារៈសំខាន់ដោយសារផ្តែរនេះកំណត់កាលប្រវត្តិរបស់ប្រាសាទបុរាណផងដែរ ។ ម៉្យាងវិញទៀត បើតាមមតិរបស់បណ្ឌិត **មីសែល ត្រាណេ** ផ្តែរមិនត្រឹមតែមានតួនាទីលម្អប្រាសាទប៉ុណ្ណោះទេ ថែមទាំងបំពេញតួនាទីខាងវិស័យសាសនាទៀតផង ដោយមានជំនឿថាចម្លាក់ផ្តែរជួយការពារប្រាសាទ និងសាសនិកជន ពីខ្មោចព្រាយបិសាច ឬ ឧបទ្រពចង្រៃ ។ យើងសង្កេតឃើញថា នៅប្រាសាទ **សម្បូរណ៍ព្រៃគុក** ស្ថាបត្យករបានចម្លងផ្តែរពីប្រាសាទឥណ្ឌាស្ទើរតែទាំងស្រុង ដែលឆ្លុះបញ្ចាំងពីសិល្បៈខ្មែរដែលស្ថិតនៅក្នុងតំណាក់កាលដំបូងនៅឡើយ ។

ជារួមប្រាសាទបុរាណខ្មែរត្រូវបានចាត់ថ្នាក់ទៅតាមការវិវត្តនៃរចនាបថ ពីមួយសម័យកាល ទៅសម័យកាលមួយទៀត ដោយសិល្បករ និងស្ថាបត្យករផ្ដល់នូវតម្លៃទៅលើធម្មជាតិ ទៅលើសត្វ ទៅលើមនុស្ស ឬ ទៅលើតម្លៃអរូបិយជាដើម ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ១.៣.១១. ហោជាង

នៅលើផ្ដែរ ស្ថាបត្យករបុរាណខ្មែរដាក់ហោជាង មានរាង និងចម្លាក់ក្បាច់ ដែលប្រែប្រួលតាមសម័យកាល ។ ប្រាសាទសំបូរព្រៃគុកសាងសង់ពីឥដ្ឋ មានរាងតូចដូចប្រាសាទនៅឥណ្ឌា ហើយគ្មានហោជាងទេ ដូចរូបថតខាងក្រោមបង្ហាញស្រាប់ ។ ប្រាសាទនៃរចនាបថព្រៃក្មេង និងកំពង់ព្រះ ក៏គ្មានហោជាងដែរ ។



ប្រាសាទនៃរចនាបថកូលែនចាប់ផ្ដើមមានហោជាង ដែលនៅលើគែមមានឆ្លាក់ក្បាច់ស្លឹកឈើ និងទងឈើ ដែលឆ្លុះបញ្ចាំងពីកម្លាំងទ្រព្យធម្មជាតិ ។ ហោជាងមានការវិវត្តច្រើននៅក្នុងរចនាបថ **កោះកេរ្ដិ៍** ដែលមានរាងជា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រីកោណ ។ នៅលើផ្ទៃហោជាង សិល្បករខ្មែរបុរាណច្រើនឆ្លាក់ឆាកខ្លះៗពីរឿងបុរាណឥណ្ឌា ដូចជារឿង **មហាភារតៈ** និងរឿង **រាមកេរ្តិ៍** ជាដើម ។ ឧទាហរណ៍ហោជាងនៃទ្វារខាងត្បូងនៃគោបុរៈទី៤ នៃប្រាសាទ**ព្រះវិហារ** គឺជាទេវកថា **កូរសមុទ្ធទឹកដោះ** ដ៏ល្បីល្បាញនោះ ។



### ១.៣.១២. សសរពេជ្រ

សសរពេជ្រ គឺជាសសរទ្រផ្តែរ ដែលដាក់នៅសងខាងទ្វារប្រាសាទ ។ សរសរពេជ្រនេះក៏មានការវិវត្ត និង ផ្លាស់ប្តូររូបរាងទៅតាមរចនាបថផងដែរ ។ ប្រាសាទនៃរចនាបថសំបូរព្រៃគុកមានសសរពេជ្ររាងមូលថ្មី ដូចបាន បង្ហាញនៅក្នុងរូបខាងក្រោមស្រាប់ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



សសរពេជ្រនេះវិវត្តពីមូល ទៅរាងជ្រុង ខ្លះមានបួនជ្រុង ហើយខ្លះទៀតមានប្រាំបីជ្រុង ។ សសរពេជ្រនៃប្រាសាទព្រះវិហារមានរាងអដ្ឋកោណ ដែលទ្រផ្តែរទ្វារលម្អដោយចម្លាក់ស្លឹកឈើ ខ្លះបញ្ចាំងនូវសភាពសមតា និងខ្លះគ្នាទៅវិញទៅមក ជាមួយនឹងទេវរូបដែលនៅកណ្តាល ។

### ១.៣.១៣. បារាយណ៍

បារាយណ៍ គឺជាអាងស្តុកទឹក និង ជានិមិត្តរូបនៃមហាសាគរ ហើយជាផ្នែកមួយដ៏សំខាន់នៃស្ថាបត្យកម្មខ្មែរបុរាណ ។ ព្រះមហាក្សត្រខ្មែរខ្លះបានសាងសង់ប្រាសាទនៅក្នុងបារាយណ៍ ។ ជារួម ប្រជាជនខ្មែរប្រើប្រាស់បារាយណ៍ជាទីសក្ការៈបូជាផង និង សម្រាប់ធារាសាស្រ្តផង ។

### ១.៣.១៤. ចម្លាក់បុរាណខ្មែរ

ចម្លាក់បុរាណខ្មែរមានបីប្រភេទដូចតទៅ÷

**១.៣.១៤.១. ចម្លាក់លិប**- គឺជាក្បាច់ឆ្លាក់នៅលើផ្ទាំងថ្មចូលទៅក្នុងផ្ទៃថ្ម តែមិនស្ទាវផុសចេញពីផ្ទៃថ្មទេ ។ ចម្លាក់លិប (Bas-relief) ច្រើនឆ្លាក់នៅលើជញ្ជាំងប្រាសាទ ដូចជានៅថែវប្រាសាទអង្គរវត្ត ឬ ប្រាសាទបាយ័នជាដើម ។

**១.៣.១៤.២. ចម្លាក់លៀន**- គឺជាក្បាច់ឆ្លាក់លៀនយ៉ាងខ្ពស់ចេញពីផ្ទៃថ្ម ដោយសារគេដាប់ថ្មឱ្យជ្រៅ ដើម្បីឱ្យចម្លាក់ផុសចេញពីថ្មតែម្តង ។ ចម្លាក់លៀន (Haut-relief) ច្រើនឆ្លាក់នៅលើផ្តែរ លើសសរពេជ្រ និងលើជញ្ជាំងប្រាសាទ ។

១.៣.១៤.៣. **ចម្លាក់លោត**- គឺជាការឆ្លាក់រូបសត្វ ឬ មនុស្សឱ្យដាច់ពីជញ្ជាំង ប៉ុន្តែមានទម្រដាក់ឱ្យផ្អែកជាប់ជញ្ជាំងដើម្បីទប់ចម្លាក់នេះឱ្យនៅនឹង ។ រូបបដិមាករក៏អាចចាត់ទុកថាជា ចម្លាក់លោត (Ronde-bosse) ផងដែរ ។

## ១.៤. រចនាបថនៃប្រាសាទបុរាណខ្មែរ

ការសាងសង់ប្រាសាទបុរាណខ្មែរមានការវិវត្ត និងកែលម្អជាប្រចាំ ដែលឆ្លុះបញ្ចាំងពីដំណាក់កាលយុវវ័យ ភាពចាស់ទុំ និងជរាភាព ។ អ្នកដែលសិក្សាសិល្បៈខ្មែរ បានបែងចែកប្រាសាទបុរាណខ្មែរជាស្ថាបត្យកម្ម **មុនសម័យអង្គរ** (ពីស.វ.ទី១ ដល់ ស.វ. ទី ៨) ស្ថាបត្យកម្ម **សម័យអង្គរ** (ពីស.វ.ទី ៩ ដល់ ស.វ. ទី ១៣) និង ស្ថាបត្យកម្ម **ក្រោយសម័យអង្គរ** (ពីស.វ.ទី១៤ ដល់សព្វថ្ងៃនេះ) ។ លោក **ត្រូដ ហ្សាក់** បានគូសបញ្ជាក់ថា សិល្បៈខ្មែរបានវិវត្តទៅតាមវិធីសាស្ត្របួនយ៉ាង គឺៈ

ទីមួយ- គឺ តក្កកម្ម មានន័យថា ការបង្កើតអ្វីៗថ្មីទាំងស្រុង ។

ទីពីរ- ការចូលរួមវិភាគទានពីសិល្បៈបរទេស (គឺពីសិល្បៈឥណ្ឌា តែក៏មានសារធាតុខ្លះនៃសិល្បៈជ្វា និងសិល្បៈចាមដែរ) ។

ទីបី- ការខ្ចីនូវរចនាបថពីអតីតកាល តែមិនបានចម្លងទាំងស្រុងនូវរចនាបថទេ ដោយគ្រាន់តែស្វែងរកប្រធានបទចាស់ៗ ដើម្បីបញ្ចូលសារជាថ្មី ដោយមានធ្វើវិសោធនកម្មទៅលើអ្វីដែលមានចាស់ ។

ទីបួន- ការចម្លងតាមនូវបច្ចេកទេសផ្សេងៗ ហើយអ្វីដែលគេច្រើនជួបប្រទះ គឺការចម្លងតាមនូវក្បូរក្បាច់រចនានៃសំណង់ឈើតូចតាច ។

ដោយឈរលើមូលដ្ឋាននៃការសិក្សានូវលក្ខណៈពិសេសខាងផ្នែកស្ថាបត្យកម្ម ឬ ក្បាច់រចនាផ្សេងៗ លោក **ហ្វីលីព ស្ទែន** និង **ហ្ស៊ីលប៊ែត ដឺ គូរ៉ាល់-រ៉េមុយហ្សាត** បានបង្កើតបានជាបញ្ជីនៃរចនាបថចំនួន ១៣ ដោយដាក់ឈ្មោះតាមប្រាសាទសំខាន់ៗនាសម័យនោះ ដែលមានលក្ខណៈពិសេសទាំងនោះ ហើយដែលតំណាងឱ្យរចនាបថសម័យនោះ ។ តាមរយៈការសិក្សានៃរូបចម្លាក់ លោក **ហ្សង់ បួស៊ីលីយេរ** និង **ពីយែរ ឌុយប៉ុង** បានបន្ថែមនូវរចនាបថពីរទៀត គឺរចនាបថភ្នំដា និង រចនាបថប្រាសាទអណ្តែត ។ ដូច្នេះ សិល្បៈខ្មែរបានវិវត្តទៅតាមរចនាបថចំនួន ១៥ ។ យើងឃើញថា សិល្បៈខ្មែរក្នុងដំណាក់កាលដំបូងស្ថិតនៅក្នុងសភាពក្មេងខ្ចីនៅឡើយ ហើយខ្ចីពីសិល្បៈឥណ្ឌាយ៉ាងច្រើន ដោយពុំទាន់ស្លឱ្យចេញជាអត្តសញ្ញាណជាតិខ្មែរឱ្យបានទាំងស្រុងនៅឡើយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## I-ស្ថាបត្យកម្មមុនសម័យអង្គរ

រចនាបថមុនសម័យអង្គរមាន រចនាបថភ្នំដា រចនាបថសម្បូណព្រៃគុក រចនាបថព្រៃក្មេង រចនាបថប្រាសាទអណ្ដែត រចនាបថកំពង់ព្រះ និង រចនាបថកូលែន ។

## ១.៤.១. រចនាបថ ភ្នំដា

សិល្បៈខ្មែរនៃរចនាបថភ្នំដា គឺជាសិល្បៈដែលនៅក្មេងខ្ចីនៅឡើយ នៅក្នុងចន្លោះសតវត្សរ៍ទី៦ និង ដើមសតវត្សរ៍ទី ៧ ។ ប្រាសាទភ្នំដាជាប្រាសាទឥដ្ឋ ដែលសង់លើកំពូលភ្នំនៃខេត្តតាកែវ លើខឿនថ្មបាយក្រៀមដែលបន្ទុបលើខឿនប្រាសាទបុរាណ ហើយមានប្រអប់ទ្វារធ្វើពីថ្ម ។ គេបានរកឃើញនូវសសរពេជ្រផងដែរ ។ ក៏ប៉ុន្តែ បើតាមមតិរបស់បណ្ឌិត **មីសែល ត្រាណេ** ប្រាសាទភ្នំដានេះមិនមែនសាងឡើងនាសតវត្សទី ៥ ឬ ទី ៦ ទេ តែនៅសតវត្សរ៍ទី១១ ទេវិញ ដោយសង់លើខឿនប្រាសាទចាស់មួយនាសម័យនគរភ្នំ ។

ចំណែកឯរូបចម្លាក់បីនៃរចនាបថមុនអង្គរ សម័យនគរភ្នំ ដែលរកឃើញនៅក្នុងប្រាសាទ ដែលមានលក្ខណៈធម្មជាតិនិយម និងពិសិដ្ឋនិយម គឺ៖




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ព្រះវិស្ណុដៃ ៨ មួយអង្គ ដោយមានរង្វង់រាងជាធ្នូនៅខាងក្រោយសម្រាប់ទ្រទ្រង់ទេវរូប និង

- ពុទ្ធបដិមា ២ អង្គទៀតដែលមានស្លាកស្នាមវប្បធម៌ឥណ្ឌា- ក្រិក ។

ក៏ប៉ុន្តែ តាមយោបល់លោក **មីសែល ត្រាណេ** ផ្តែរទ្វារ រូបរាងប្រាសាទ និងចម្លាក់សសរពេជ្រស្ថិតនៅក្នុងរចនាបថបាពួនទេវិញ ។ បញ្ហានេះយើងសង្កេត ឃើញថា ប្រាសាទនីមួយៗតែងតែសាងសង់ឡើងវិញដោយព្រះមហាក្សត្រជាបន្តបន្ទាប់ ដូចជាប្រាសាទព្រះវិហារ ដែលសាងសង់ដោយព្រះមហាក្សត្រខ្មែរជាច្រើនអង្គ និងមានរចនាបថចម្រុះគ្នាដូច្នេះដែរ ។ ក្នុងន័យនេះដែរ លោក **ហ្សង់ បំរសឺលីយេះ** បានចាត់ថ្នាក់រចនាបថភ្នំដារដោយឈរលើមូលដ្ឋាននៃរូបបដិមាករតែប៉ុណ្ណោះ ។

## ១.៤.២. រចនាបថ សម្បូណព្រៃគុក

ប្រាសាទ **សម្បូណព្រៃគុក** ស្ថិតនៅក្នុងខេត្តកំពង់ធំដែលសាងសង់ឡើង នៅក្នុងស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទ **ឦសានវរ្ម័ន** ដែលបានតាំងរាជធានីនៅ **ឦសានបុរះ** ដែលជារាជធានីដំបូងបង្អស់របស់នគរភ្នំ និងចេនឡារួមគ្នា ហើយដែលប្រវត្តិវិទូបានចាត់ទុកថាជាដើមកំណើតនៃ **អាណាចក្រខ្មែរ** ។



ប្រាសាទទាំងនេះសង់ ដោយឥដ្ឋ លើកលែងតែផ្តែរ សសរពេជ្រ និងស៊ុមទ្វារដែលធ្វើពីថ្មភក់ ។ ប្រាសាទ **សម្បូណ៌ព្រៃគុក** ចែកចេញជាពីរក្រុម ។ ប្រាសាទមួយចំនួនដែលស្ថិតនៅផ្នែកខាងត្បូង និងខាងជើងត្រូវបានសាងសង់ឡើងនៅក្នុង ស.វ. ទី៧ ។ ចំណែកប្រាសាទមួយក្រុមទៀតសាងសង់ឡើងនៅពេលក្រោយ ។



ក្បាច់រចនា និងផ្តែរទ្វាររចនាបថ **សម្បូណ៌ព្រៃគុក** មានចម្លាក់ផ្តេក រាងជាធ្នូ ដែលមានរូបបណ្តោងនៅចំកណ្តាល ។ នៅខាងចុងផ្តែរមានលម្អដោយសត្វមករ ដែលជាសត្វសមុទ្រតំណាងទឹក ងាកក្បាលចូលក្នុង និងលើកកន្ទុយឡើងលើ ។ គឺជាក្បាច់នៃសត្វមករងាកក្បាលចូលក្នុងនេះហើយ ដែលឆ្លុះបញ្ចាំងពី «*ចលនាដូចគ្នា*» នៃផ្តែរទ្វាក្នុងរចនាបថ **សម្បូណ៌ព្រៃគុក** ។ នៅក្រោមធ្នូ គេមានព្យួររំយោលទងផ្កា ស្លឹកឈើ និងមែកឈើ ដែលមានលក្ខណៈដូចជាប្រាសាទនៅឥណ្ឌាដែរ ។ ចំណែកឯសសរពេជ្រមានរាងមូល ។



ផ្តែរទ្វារនៃប្រាសាទ **សម្បូណ៌ព្រៃគុក** ខាងលើនេះក៏មានលក្ខណៈដូចៗគ្នាដែរ ដែលលម្អដោយក្បូរក្បាច់ឆ្លុះបញ្ចាំងពីធម្មជាតិ លម្អដោយស្លឹកឈើ និងមានលក្ខណៈឆ្លុះបញ្ចាំងគ្នាល្អ ។ ចំណុចសំខាន់ គឺ ស្ថាបត្យកម្ម **សម្បូណ៌ព្រៃគុក** មានស្លាកស្នាមដ៏ច្រើនលើសលុបនៃវប្បធម៌ឥណ្ឌា ។

រូបបដិមាព្រះនាងទុគ៌ា ដែលរកឃើញនៅក្នុងប្រាសាទ ហើយដែលដាក់តាំងនៅក្នុងសារមន្ទីរជាតិបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្រ្តីឥណ្ឌាតែម្តង ។ រូបក្បាលបុរសដែលធ្លាក់នៅក្នុងប្រាសាទ គឺជាបុរសដែលមានពុក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មាត់ និងមានលក្ខណៈជាបុរសជនជាតិឥណ្ឌា ។



### ១.៤.៣. រចនាបថ ព្រៃក្មេង

បន្តិចម្តងៗ ស្ថាបត្យករបុរាណខ្មែរបានផ្នែប្រឌិតផ្តែរទ្វារ ដែលវិវត្តទៅតាមរចនាបថ ដូចជាផ្តែរទ្វារនៃរចនាបថ **ព្រៃក្មេង** ក្នុងពាក់កណ្តាលទី២ នៃស.វ.ទី៧ (ពីឆ្នាំ ៦៣៥ ដល់ ៧០០) ។ រចនាបថ **ព្រៃក្មេង** ចាប់ផ្តើមពីពេលដែលព្រះបាទ **ភវវរ្ម័នទី២** បានឡើងសោយរាជ្យបន្ទាប់ពីព្រះបាទ **ឦសានវរ្ម័ន** បានចូលទិវង្គតនៅក្នុងឆ្នាំ ៦៣៥ ។ ដែលជាសតវត្សរ៍ដែលអាណាចក្រចេនឡាកំពុងរីកចម្រើន ឆ្លុះបញ្ចាំងតាមរយៈការខិតខំប្រឹងប្រែងរបស់សិល្បករ ក្នុងការស្វែងរកសុក្រិតភាពនៃសមាមាត្រ និងសមតា ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្តែរទ្វារនៃរចនាបថ **ព្រៃក្មេង** ហាក់បីដូចជាមិនសូវល្អដូចមុនឡើយ ។ ផ្តែរលែងមានរូបសត្វ **មករ** ទៀតហើយ ។ យើងឃើញមានគំនូសផ្តេកខាងលើ មានកូនធ្នូតូចៗពីរជារម្មូរស្លឹកឈើដែលមានលក្ខណៈរាបស្មើ ហើយខាងចុង មានរាងខុបចូលក្នុង ។ ក្បាច់មូលនៅចំកណ្តាលលែងមានចម្លាក់រូបមនុស្សហើយ គេឃើញមានតែ វិយោលផ្កាវល្លិ៍ព្យួរចុះក្រោមដែលគេហៅថា «**ចលនានៅមួយកន្លែង**» ។ សសរពេជ្រមានរាងមូល ដូចរចនាបថ **សម្បូណព្រៃគុក** ដែរ តែមានបន្ថែមក្បាច់ខ្សែ ជាពិសេសមានវិយោល និងបន្តោងរយ៉ាប្លែកៗជាច្រើន ។

ប្រាសាទនៃរចនាបទ **ព្រៃក្មេង** មាន ÷ ប្រាសាទព្រៃក្មេងដែលជាប្រាសាទមួយតូចនៅក្នុងតំបន់អង្គរ ប្រាសាទស្វាយព្រាម ប្រាសាទបាសិត ប្រាសាទ ព្រៃប្រាសាទ និង ប្រាសាទភ្នំបាយ៉ង ។

## ១.៤.៤. រចនាបថ ប្រាសាទអណ្តែត

រចនាបថ **ប្រាសាទអណ្តែត** មានរយៈកាលជំនាន់រចនាបថ **ព្រៃក្មេង** ដែរ ។ ក្រោយពីព្រះបាទ ព្រះបាទ **ភវវរ្ម័នទី ២** សោយទិវង្គតទៅ ព្រះបាទ **ជ័យវរ្ម័នទី ១** (៦៥៧-៦៨១) ដែលជាបុត្របានឡើងសោយរាជ្យ នៅមុនឆ្នាំ ៦៥៧ ។ ព្រះអង្គបានពង្រីក និងពង្រឹងអំណាចរបស់ព្រះអង្គនៅក្នុងឥណ្ឌូចិនភាគខាងត្បូង ។ គេឃើញ មាននូវសិលាចារឹក និងប្រាសាទជាច្រើនដែលបានសាងសង់នៅក្នុងរជ្ជកាលនេះ ។

យើងមិនដឹងច្បាស់ពីរាជធានីនៅសម័យនោះនៅឡើយ ។ ប្រវត្តិវិទូបានសន្និដ្ឋានថា រាជធានីនេះ **អមរិន្ទ្របុរៈ** ប្រហែលជាស្ថិតនៅម្តុំអង្គរ ដែលមាន **ប្រាសាទអកយំ** នៅចំកណ្តាល ។ បន្ទាប់មកប្រហែលជា រាជធានីនេះត្រូវបានលើកយកមកកាន់តំបន់នៃប្រាសាទ **ត្រពាំងផុង** ដែលត្រូវបានព្រះបាទ **ជ័យវរ្ម័នទី២** បានកែ លម្អថែមទៀត ។

នៅក្នុងរជ្ជកាលនៃព្រះបាទ **ជ័យវរ្ម័ន ទី ១** ព្រហ្មញ្ញសាសនាសិវនិយមកំពុងរីកចម្រើន ជាពិសេស ការគោរពលិង្គព្រះឥសូរ ។ ចំណែកឯកការគោរពបូជាព្រះពុទ្ធសាសនាមហាយានកាន់តែធ្លាក់ចុះ ដោយសារតែ គេមិនសូវឃើញនូវរូបចម្លាក់ព្រះពុទ្ធរូបនៅក្នុងសម័យកាលនេះទេ ។

ស្ថាបត្យកម្មនៃដំណាក់កាលនេះមានលក្ខណៈបន្តពីរចនាបថ **ព្រៃក្មេង** ហើយត្រូវបានគេចាត់ទុកថាជា ដំណាក់កាលទីពីរនៃរចនាបថ **ព្រៃក្មេង** ថែមទៀតផង ហើយរចនាបថ **ប្រាសាទអណ្តែត** មានរយៈកាលជំនាន់ រចនាបថ **ព្រៃក្មេង** ដែរ ។ ស្នាដៃវិចិត្រដែលឆ្លុះបញ្ចាំងជាងគេនៃរចនាបថ **ប្រាសាទអណ្តែត** គឺ រូបចម្លាក់ **ហរិហរៈ** នៃប្រាសាទ **អណ្តែត** ដែលស្ថិតនៅក្នុងសារៈមន្ទីរជាតិនៃទីក្រុងភ្នំពេញ ។



## ១.៤.៥. រចនាបថ កំពង់ព្រះ

ប្រាសាទភូមិប្រាសាទ និង ប្រាសាទកំពង់ព្រះ គឺជាតំណាងនៃរចនាបថ **កំពង់ព្រះ** ដែលសាងសង់ពីឥដ្ឋ ។ ប្រាសាទទាំងនេះសាងសង់នៅក្នុង ស.វ.ទី៨ នៅពេលដែលអាណាចក្រចេនឡាត្រូវបែងចែកជាពីរ ដោយសារតែអំណាចកណ្តាលចុះខ្សោយ ÷ គឺ **ចេនឡាដីគោក** និង **ចេនឡាទឹកលិច** ហើយប្រទេសជាតិក៏មានសង្គ្រាមទៀត។



សិល្បៈខ្មែរឆ្លុះបញ្ចាំងនូវភាពបែកបាក់នេះ ដោយរលត់បាត់អស់នូវវិញ្ញាណ នៅសល់តែភាពសាមញ្ញដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ញុំភាពផ្អែប្រឌិត ។ ផ្តែទ្វារនៃរចនាបថកំពង់ព្រះមានលក្ខណៈសាមញ្ញ ហើយចម្លងភ្ជាប់បិទបន្តបន្ទាប់គ្នា មានរាងជាស្លឹកឈើមួយសំណុំដាក់ផ្តេកគងលើគ្នាជាបន្តបន្ទាប់ ។ នៅចំកណ្តាលក៏គេឃើញមានស្លឹកឈើ ដែលមានលក្ខណៈដូចរាហ៊ូ ឬ កល ។ ដូច្នេះ រចនាបថ **កំពង់ព្រះ** បង្ហាញពីធម្មជាតិនិយម ដោយលម្អផ្តែរទ្វាដោយស្លឹកឈើ និងទងឈើទាំងស្រុង ។ សសរពេជ្រនៅរក្សារាងមូលដដែល តែលម្អដោយក្បាច់ចិញ្ចៀនកង់ៗបន្តបន្ទាប់គ្នា បីដូចជាទងផ្កា ។ ចំណែកឯហោជាងវិញ មានរាងដូចអក្សរ U ផ្កាប់ចុះក្រោម ហើយនៅលើផ្ទៃហោជាងមានរូបតូចៗមួយចំនួន ។

ប្រាសាទនៃរចនាបទ **កំពង់ព្រះ** មាន ÷ ប្រាសាទកំពង់ព្រះ (កំពង់ឆ្នាំង) ប្រាសាទអកយំ ប្រាសាទត្រពាំងផុង ប្រាសាទបាសិត ប្រាសាទភូមិប្រាសាទ (កំពង់ធំ) ។





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ១.៤.៦. រចនាបថ គូលែន

រចនាបថ **គូលែន** ឆ្លុះបញ្ចាំងផងដែរនូវស្ថេរភាពនយោបាយ និងសង្គមនៃរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី ២** ដែលបានបានរំដោះប្រទេសជាតិឱ្យមានឥស្សរភាពឡើងវិញ និងបង្រួបបង្រួមប្រទេសឱ្យមានឯកភាពជាតិឡើងវិញ ។ លោក **ហ្វីលីព ស្ទែន** បានបរិយាយដោយខ្លីថា ÷ ការសិក្សាសសរពេជ្រ ផ្តែរ និងរូបបដិមារបានបង្ហាញថា រចនាបថគូលែនមានទិដ្ឋភាពបីយ៉ាងដែលបង្រួបគ្នា ÷ (១) សសរពេជ្រមានរចនាបថឯកភាពគ្នា (២) ផ្តែរមានលក្ខណៈកែលម្អយ៉ាងវិចិត្រ និងការឆ្នៃប្រឌិតយ៉ាងរស់រវើករបស់សិល្បករ ដែលខ្ចីសិល្បៈពីគេខ្លះ តែកែឆ្នៃឱ្យក្លាយទៅជាអត្ត-សញ្ញាណរបស់ខ្លួន និង (៣) រូបបដិមារដែលឆ្លុះបញ្ចាំងពីសម័យអន្តរកាល នៅចន្លោះរចនាបថដែលកន្លងផុត និងរចនាបថដែលនឹងមកដល់ ។

ដំណាក់កាលនៃ **រចនាបថគូលែន** គឺជាដំណាក់កាលនៃការរស់ឡើងវិញនៃសិល្បៈជាតិ ដែលបង្ហាញពីការបង្កើតឡើងថ្មី និង តក្កកម្មយ៉ាងផុសផុល កម្ចីពីរចនាបថមុនៗហើយកែឆ្នៃបន្ត និងការចម្លងខ្លះៗពីទស្សនទានសិល្បៈបរទេស ដូចជាសិល្បៈចាម និងជ្វាជាដើម ។ ឧទាហរណ៍ នៅលើខ្ពង់រាបគូលែនមានប្រាសាទពីរ ដែលស្រដៀងបេះបិទទៅនឹងសិល្បៈចាម ។ ស្ថាបត្យកម្មនៃប្រាសាទដំរីក្រាបមានលក្ខណៈដូចស្ថាបត្យកម្មចាម លើកលែងតែទ្វារមុខ សសរពេជ្រ ផ្តែរ ហោជាង និង សសរដែលមានលក្ខណៈជាសិល្បៈខ្មែរ ។

សសរពេជ្រនៃរចនាបថគូលែនបង្ហាញពីភាពសម្បូណ៌បែប និងការឆ្នៃប្រឌិតយ៉ាងប៉ិនប្រសព្វ ។ សសរពេជ្រទាំងនេះមានរាងប្រាំបីជ្រុង ឬ បួនជ្រុងស្មើ ដែលខុសពីរចនាបថសម្បូណ៌ ព្រៃក្មេង និងកំពង់ព្រះ ដែលមានរាងមូល ។ នៅក្រោយរចនាបថគូលែន សសរពេជ្រជ្រុងមានតែនៅប្រាសាទបាគង និង ប្រាសាទបន្ទាយស្រីប៉ុណ្ណោះ ។ ការលេចចេញនូវសសរពេជ្ររាងអដ្ឋកោណ (ដែលមានជ្រុងប្រាំបី) នៃរចនាបថ **គូលែន** នឹងត្រូវសិល្បករខ្មែររក្សាទុកសម្រាប់រចនាបថផ្សេងទៀត ។

ផ្តែទ្វារនៃរចនាបថ **គូលែន** បង្ហាញពីលក្ខណៈសម្បូណ៌បែបនៃរចនាបថនេះ ដែលឆ្លុះបញ្ចាំងពីសម័យកាលកំណែទម្រង់ និងមានលក្ខណៈដូចតទៅ÷ លំនាំក្បាច់នៅដដែល ការចម្លងពីរចនាបថមុនៗ សមាសធាតុខ្ចីពីបរទេស និងតក្កកម្ម ។ ផ្តែរនៃរចនាបថគូលែនយកលំនាំក្បាច់នៃរចនាបថ **សម្បូណ៌ព្រៃគុក** និង **ព្រៃក្មេង** ដូចជាក្បាច់រាងធ្នូ ចម្លាក់រាងមូលពងក្រពើ វិយោល បន្ទោងរយ៉ា សត្វមករ ។ ក៏ប៉ុន្តែ សិល្បករបានកែខ្លះៗដើម្បីឱ្យខុសពីរចនាបថមុន គឺការជំនួសធ្នូដោយបណ្តុំស្លឹកឈើ សត្វ **មករ** ដាក់ឱ្យបែមុខចេញក្រៅវិញ វិយោល និងបន្ទោងមានរាងធំៗ ។ នៅពេលខ្លះ នៅចំកណ្តាលផ្តែរគេដាក់រាហ៊ូ គ្រុឌ ឬ ទេវរូប ។ ផ្តែទ្វារនៃរចនាបថ **គូលែន** បង្ហាញពីនិមិត្តរូបនៃកម្លាំងទ័ពរបស់ព្រះបាទ **ជ័យវរ្ម័នទី២** ក្នុងការប្រយុទ្ធជាមួយជ្វា តាមរយៈក្បាច់ត្របកឈូក និងក្បាច់ផ្កា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ព្រលិត ដែលជានិមិត្តរូបរបស់កម្លាំងកងទ័ព កម្លាំងទ្រព្យធម្មជាតិ និង កសិកម្ម ។ តាមរយៈផ្តែរខាងលើនេះ មែកឈើលម្អផ្តែរបែកមែកសាខាឡើងលើ និងចេញទៅខាងក្រៅ ហើយនៅខាងចុងយើងឃើញមានក្បាលសត្វមករ បែរក្បាលចេញក្រៅ ។ ក៏ប៉ុន្តែ សត្វមករនេះមានលក្ខណៈខុសពីរចនាបថមុនៗ ដោយសារវាមានរាងដូចជាដំរី ។ នៅចំកណ្តាលផ្តែរនៃរចនាបថគូលែន សិល្បករខ្មែរឆ្លាក់ទេវរូបអមសងខាងដោយអមាត្យពីរនាក់កាន់ផ្លិតបក់ ដែលញ៉ាំងឱ្យផ្តែរនេះមានទិដ្ឋភាពកាន់តែអធិកអធមខ្លាំងឡើងថែមទៀត ។ ក្បាច់បន្ទោងរយ៉ានៅលើផ្តែរមានលក្ខណៈធំជាងក្បាច់បន្ទោងរយ៉ានៃរចនាបថមុនៗ ។ ក្បាច់បន្ទោងរយ៉ានេះមានលក្ខណៈសាមញ្ញនៃរចនាបថខ្មែរក្នុងសតវត្សទី ៧ តែថ្ពក់នឹងមែកឈើដែលពុះផ្តែរជាពីរកំណាត់តាមខ្សែបណ្តោយ ។ នៅខាងក្រោមទេវរូបយើងឃើញមានក្បាលរាហ៊ូមានដៃពីរទ្របល្ល័ង្គ ។

ការចម្លងពីរចនាបថមុនៗឆ្លុះបញ្ចាំងតាមរយៈក្បាច់បន្ទោងរយ៉ាចំនួនប្រាំខាងលើ ដែលសិល្បករខ្មែរនឹងបោះបង់ចោលនៅក្នុងការលម្អផ្តែរក្នុងរចនាបថក្រោយៗទៀត ។ ម៉្យាងវិញទៀត នៅលើផ្តែរខ្លះគេឃើញមានប្រើក្បាច់ចម្លាក់រាងមូលពងក្រពើ ដោយមានឆ្លាក់រូបមនុស្សនៅកណ្តាល ដូចជានៅក្នុងរចនាបថសម្បូណ៌ផងដែរ ។ សមាសធាតុខ្ចីពីបរទេសឆ្លុះបញ្ចាំងតាមរយៈឥទ្ធិពលចាម និងជ្វា ក្នុងស្ថាបត្យកម្ម និងក្បាច់រចនានៃប្រាសាទខ្លះ ដូចជាក្បាលរាហ៊ូមានលក្ខណៈដូចរាហ៊ូជ្វាដែរ ។

ទន្ទឹមនឹងនេះ គេឃើញមានស្នាដៃតក្កកម្មនៃរចនាបថគូលែនផងដែរ ដែលបង្ហាញពីភាពឆ្នៃប្រឌិតរស់រវើក និងភាពប៉ិនប្រសព្វនៃសិល្បករខ្មែរជំនាន់នោះ តាមរយៈការបំផ្លែងលំនាំក្បាច់រចនា និងជវភាព ដែលរក្សាបាននូវតុល្យភាពយ៉ាងសុក្រិតនៃ **រចនាបថគូលែន** ។

ព្រះបាទ **ជ័យវរ្ម័នទី ២** បានសាងសង់ប្រាសាទជាច្រើននៃរចនាបទ **គូលែន** ដូចជាប្រាង្គ (សេ១) នៅសម្បូណ៌ព្រៃគុក ប្រាសាទនៅបន្ទាយព្រៃនគរ ប្រាង្គខាងជើងនៃប្រាសាទព្រៃប្រាសាទ ប្រាសាទដំរីក្រាប ប្រាសាទអូផ្អុង ប្រាសាទខ្ទីងស្លាប់ ប្រាសាទរូបអារក្ស ប្រាសាទថ្មដាប់ ប្រាសាទគគីរ ប្រាសាទក្រហម ប្រាសាទអ្នកតា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ប្រាសាទត្រពាំងផុង (រលួស)*

ព្រះបាទ **ជ័យវរ្ម័នទី ២** ទ្រង់គង់នៅលើភ្នំគូលែនបានមួយរយៈ ទើបយាងមកតាំងរាជធានីនៅ **ហរិហរាល័យ** វិញ ដោយនាំយកលិង្គទេវរាជមកជាមួយផង ។ ព្រះអង្គសោយទិវង្គតនៅ **ហរិហរាល័យ** នៅ គ.ស. ៨៥០ ដោយទទួលមរណនាមថា **បរមេស្វរ** ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនា **ជយវធន** បានឡើងសោយរាជ្យ ដោយយកព្រះនាមថាព្រះបាទ **ជ័យវរ្ម័នទី ៣** (គ.ស.៨៥០-៨៧៧) ។ ព្រះអង្គគង់នៅ **ហរិហរាល័យ** រហូតដល់ឆ្នាំ ៨៧៧ និង បានកសាង **ប្រាសាទត្រពាំងផុង** ដែលស្ថិតនៅក្នុងរលួស និង ដែលឆ្លុះបញ្ចាំងនូវរចនាបថអន្តរកាលពី **រចនាបថគូលែន** ទៅ **រចនាបថព្រះគោ** ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## II-ស្ថាបត្យកម្មសម័យអង្គរ

រចនាបថសម័យអង្គរចែកចេញជារចនាបថ **មុន-បុរាណនិយម** មាន រចនាបថព្រះគោ រចនាបថភ្នំបាក់ខែង រចនាបថកោះកេរ្តិ៍ និងរចនាបថប្រែរូប ។ ចំណែកឯករចនាបថ **បុរាណនិយម** មាន រចនាបថបន្ទាយស្រី រចនាបថឃ្លាំង រចនាបថបាពួន និង រចនាបថអង្គរវត្ត ។

### ១.៤.៧. រចនាបថ ព្រះគោ

ប្រាសាទនៃរចនាបថព្រះគោកសាងឡើងនៅក្នុងរជ្ជកាលនៃព្រះបាទ **ឥន្ទ្រវរ្ម័នទី១** ដែលឡើងគ្រងរាជសម្បត្តិនៅក្នុងគ.ស. ៨៧៧ (ចុងស.វ.ទី ៩) ។ ព្រះអង្គបានរៀបចំឱ្យជីកបារាយណ៍ **ឥន្ទ្រតដាក** នៅខាងជើងរាជធានី ដើម្បីបម្រើឱ្យសាសនាផង និងប្រព័ន្ធស្រោចស្រពផង ។ ព្រះអង្គបានកសាងប្រាសាទព្រះគោ ដែលជាប្រាសាទ-វត្តលើដីរាបនៅក្នុងឆ្នាំ ៨៧៩ និងជាពិសេស ព្រះអង្គបានកសាងប្រាសាទ-ភ្នំលើកទីមួយ ដោយប្រើថ្មភក់គឺប្រាសាទបាគងនៅ គ.ស.៨៨១ ។ ក្បាច់រចនានៃប្រាសាទទាំងនោះបានឈានដល់កម្រិតគុណភាពមួយ ដែលមិនទាន់មានប្រាសាទណាល្អលើសទេ ។




fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទនៃក្រុមប្រាសាទ **រលួស** ដូចជាប្រាសាទព្រះគោ ប្រាសាទបាគង និង ប្រាសាទលលៃ ត្រូវបាន កសាងឡើងដោយមាននូវសមាសធាតុទាំងអស់នៃសិល្បៈខ្មែរសម័យអង្គរ៖ ប្រាសាទរាបស្មើ ប្រាសាទ-ភ្នំ របងព័ទ្ធជុំវិញដោយមានគោបុរៈ ឬ ខ្លោងទ្វារចូល បណ្ណាល័យ សាលទ្រវែង ដែលបន្ទាប់មកក្លាយទៅជាកំពែងថែវ គូទឹកព័ទ្ធជុំវិញប្រាសាទ ផ្តែរ សសរពេជ្រ សសរទ្រ ហោជាង ទេវតា ហើយថែមទាំងចាប់ផ្តើមមានចម្លាក់លិប (Bas-relief) ធំៗទៀតផង ។



ប្រាសាទ **បាគង** ដែលជារាជធានី **ហរិហរាល័យ** (រលួស)

ផ្តែរទ្វារនៃប្រាសាទ **ព្រះគោ** គឺជាផ្តែរដ៏ល្អបំផុត និងមានលក្ខណៈពេញលេញបំផុតនៃសិល្បៈខ្មែរ ។ ចាប់ពីរចនាបថនេះទៅ ផ្តែរទ្វារនៃរចនាបថក្រោយៗចាប់ផ្តើមបាត់បន្តិចម្តងៗនូវសមាសធាតុបង្កើតនៃផ្តែរទ្វារប្រាសាទខ្មែរ។ សមាសធាតុនៃផ្តែរមាន៖ ក្បាច់ផ្តេក ក្បាច់កណ្តាល ក្បាច់គែមសងខាង ក្បាច់ពុះកាត់ជាបួនផ្នែក ក្បាច់ខាងលើក្បាច់ផ្តេក ក្បាច់ខាងក្រោមក្បាច់ផ្តេក ក្បាច់ទម្រក្បាច់គែម ក្បាច់គែមខាងក្រោម និង ក្បាច់គែមខាងលើ ។

លោក **ហ្សីលប៊ែត ដឺ គូរ៉ាល់-រ៉េមូយហ្សាត** បានពិពណ៌នាយ៉ាងល្អិតល្អន់ពីផ្តែរនៃប្រាសាទ **ព្រះគោ**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ថា៖ «*ក្បាច់ផ្តែកជាសំណុំស្លឹកឈើ ដែលពេលខ្លះត្រង់ ហើយពេលខ្លះពត់ពែនត្រូវបានបង្កើតឡើងដើម្បីជំនួសធ្នូ ។ បន្ទាប់មកក្បាច់ផ្តែកជាមែកឈើនេះ បែកចេញជាក្បាច់គែមសងខាង ជាក្បាលសត្វមករ ជាក្បាលនាគរាជ ជាស្លឹកឈើវិញត្របាញ់ ឬទៅតាមការស្រមើស្រមៃរបស់សិល្បករ ។ នៅក្រោមក្បាច់ផ្តែក គេឃើញមាននៅសល់តែក្បាច់ជាស្លឹកឈើវិញត្របាញ់ប៉ុណ្ណោះ ហើយសិល្បករខ្មែរលែងប្រើក្បាច់វំយោល និងបន្តោងរយ៉ាទៀតហើយ*» ។

ចំពោះក្បាច់នៅកណ្តាលនៃផ្តែទ្វាររចនាបថព្រះគោបង្ហាញពីតួអង្គរាហូ គ្រុឌ ព្រះឥន្ទ្រជិះដំរីក្បាលបី ទេវរូប ឬ ផ្កាឈូក ។ រាហ៊ូ គឺជាតំណាងភាពអមតៈនៃសង្គមខ្មែរ ដែលខ្វាក់ធម្មជាតិពីប្រអប់មាត់ ។ សសរពេជ្រនៃរចនាបថព្រះគោ នៅតែមានរាងមូលដដែល ហើយហោជាងមានរាងជា U ផ្កាប់ចុះ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៤.៨. រចនាបថ បាខែង



រចនាបថ **បាខែង** គឺជាប្រាសាទដែលបានសាងសង់នៅចុង ស.វ.ទី ៩ និង ដើមស.វ.ទី ១០ ។ ព្រះបាទ **យសោវរ្ម័ន** បានចាកចេញពី **ហរិហរាល័យ** (រលួស) ហើយមកសង់រាជធានីនៅ **យសោធបុរ** (អង្គរទី ១) ដោយជ្រើសរើសយកភ្នំមួយ ដើម្បីសង់ប្រាសាទ **ភ្នំបាខែង** មានរាងជាសាជីមានខឿនច្រើនថ្នាក់ ដែលស្ថិតនៅចំកណ្ដាលរាជធានី សម្រាប់តម្កល់សិវលិង្គ **យសោធរេស្វរ** (គ.ស. ៨៩៣) ។ ព្រះអង្គបានជីកបារាយណ៍




fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



**យសោធរតដាក** មានប្រវែង ៧,៥ គម និង ទទឹង ១,៨ គម ។ ព្រះអង្គបានសាងសង់ប្រាសាទលលៃ នៅចំកណ្តាលបារាណ៍ **ឥន្ទ្រតដាក** ដើម្បីឧទ្ទិសជូនដល់ព្រះមាតាបិតារបស់ព្រះអង្គ ។

រចនាបថ **បាខែង** បានបន្តនូវប្រពៃណីយនៃរចនាបថ **ព្រះគោ** ប៉ុន្តែបានបោះបង់ចោលឥដ្ឋ ដោយយកថ្មភក់ និងថ្មបាយក្រៀមទៅសាងប្រាសាទវិញ ។ ប្រាសាទនៃរចនាបទ **បាខែង** មាន ÷ ប្រាសាទភ្នំបាខែង ប្រាសាទ ភ្នំក្រោម និង ប្រាសាទភ្នំបូក ។ រចនាបថនេះបានប្រឌិតសម្លៀកបំពាក់ចាប់ភ្លី ជាលើកដំបូង ។ ចំពោះផ្តែរវិញ រចនាបថ **បាខែង** មានលក្ខណៈអន់ថយជាងផ្តែរនៃរចនាបទ **ព្រះគោ** ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៤.៩. រចនាបថ កោះកេរ្តិ៍

ព្រះបាទ **ជ័យវរ្ម័នទី ៤** បានដណ្តើមរាជ្យពីក្មួយព្រះអង្គព្រះនាម **ឦសានវរ្ម័នទី ២** ហើយឡើងសោយរាជ្យនៅ គ.ស. ៩២៨ ។ ព្រះបាទ **ជ័យវរ្ម័នទី ៤** បានលើករាជធានីពី **យសោធរបុរ** ទៅកាន់កាន់គោកគគី **(កោះកេរ្តិ៍)** វិញ ។ ក្នុងគោលបំណងពង្រឹងរាជានុភាព និង មហិទ្ធិឫទ្ធិ ព្រះអង្គបានកសាងទីក្រុងថ្មី **កោះកេរ្តិ៍** នេះ និងបានកសាងជាច្រើន ដូចជា **ប្រាសាទធំ** ដែលជាប្រាសាទភ្នំមានខឿន ៧ ជាន់ សម្រាប់តម្កល់រាជលិង្គ **ត្រិភុវនេស្វរ** ។



បាសាទនៃរចនាបថ **កោះកេរ្តិ៍** ត្រូវបានសាងសង់ចាប់ពី គ.ស. ៩២១ ដល់ គ.ស. ៩៤៤ ។ ប្លង់ប្រាសាទគឺអនុវត្តយកខ្សែបន្ទាត់មេដ្យាទំរជាមេនៅលើវាលរាប ។ រូបចម្លាក់នៃរចនាបថ **កោះកេរ្តិ៍** ចាប់ផ្តើមបង្ហាញពីរូបមានចលនា ដូចជា រូបព្រះសិវៈរាំ រូបគ្រុឌដើរ រូបចំបាប់រវាងសុគ្រីព និងពាលី រូបចំបាប់រវាងយក្ខ និង ទេវតា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ផ្ដែរទ្វារនៃរចនាបថកោះកេរ្តិ៍លុបក្បាច់ត្របកឈូកចោល ដោយដាក់រូប **ទេពប្រណម្យ** ជំនួសវិញ ដែលជានិមិត្តរូបនៃការស្វាគមន៍ចំពោះព្រះបាទ **ជ័យវរ្ម័នទី៤** និងការការកាត់ផ្ដាច់នូវទំនាក់ទំនងជាមួយ **យសោធបុរៈ** ។



*រូបបដិមាករ «**ព្រះព្រហ្ម**» តាមរចនាបថ «**កោះកេរ្តិ៍**» នៅសារមន្ទីរ **ហ្គីមេ** (បារីស)*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



សសរពេជ្រនៃរចនាបថ **កោះកេរ្តិ៍** នៅមានឆ្លាក់ក្បាច់ចិញ្ចៀន និង ស្លឹកឈើជាច្រើន ។ ហោជាងមានរាងជាអក្សរ U ផ្កាប់ចុះ តែមានច្រើនជាន់ ។ ប្រាសាទនៃរចនាបថ **កោះកេរ្តិ៍** មាន ÷ ប្រាសាទធំ ប្រាង្គប្រាសាទនាងខ្មៅ ប្រាសាទដំរី ប្រាសាទក្រហម ប្រាសាទចិន ប្រាសាទបួក ប្រាសាទប្រាំ ។




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៤.១០. រចនាបថ ប្រែរូប

ក្រោយពីព្រះបាទ **ជ័យវរ្ម័នទី ៤** បានចូលទិវង្គត វិបត្តិស្នងរាជ្យបានកើតឡើង ហើយព្រះបាទ **រាជេន្ទ្រវរ្ម័ន** ដែលជាបុត្ររបស់ប្អូនស្រីព្រះបាទ **យសោវរ្ម័នទី ១** ព្រះនាម **មហេន្ទ្រទេវី** និងព្រះអង្គ **មហេន្ទ្រវរ្ម័ន** បានឡើងសោយរាជ្យ ដោយមានការគាំទ្រពីសំណាក់ព្រាហ្មណ៍ដែលរស់នៅ **យសោធរបុរៈ** ។ ដូច្នេះ ព្រះអង្គបានលើករាជធានីពី **កោះកេរ្តិ៍** មក **យសោធរបុរៈ** វិញ ហើយបង្កើតជា «**អង្គរទី២**» ។ ព្រះអង្គបានសាងសង់ប្រាសាទ **មេបុណ្យខាងកើត** និង **ប្រាសាទប្រែរូប** ដែលជាប្រាសាទសំខាន់នៃរចនាបថប្រែរូបនេះ ។



*ប្រាសាទប្រែរូប*

រចនាបថប្រែរូបឆ្លុះបញ្ចាំងការត្រលប់ទៅរកអតីតកាល ក្នុងវិស័យស្ថាបត្យកម្ម និងក្បូរក្បាច់រចនាប្រាសាទ។ ការវិលទៅរកអតីតកាល គឺការចម្លងតាមផ្តែរនៃប្រាសាទក្រុមរលួស ដូចជាប្រាសាទព្រះគោ ប្រាសាទបាគង និង ប្រាសាទលលៃ ហើយជាពិសេស គឺប្រាង្គនៃប្រាសាទមេបុនខាងកើត និង ប្រាសាទប្រែរូបត្រូវបានសាងសង់ដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ប្រើឥដ្ឋ ហើយក្បាច់រចនាមានស្រោបបាយអរ និងក្នុងទ្រង់ទ្រាយជាប្រាសាទភ្នំ ដែលមានខឿនសាងអំពីថ្មដែលទ្រប្រាសាទធំៗចំនួនប្រាំដែលធ្វើអំពីឥដ្ឋ ។

**ប្រាសាទប្រែរូប** គឺជាស្នាដៃដ៏ធំធេង និងមានសមាមាត្រល្អបំផុត សាងសង់ពីថ្មបាយក្រៀម និងឥដ្ឋ ។ រចនាបថនេះឆ្លុះបញ្ចាំងពីការសាងសង់ប្រាសាទភ្នំដោយគ្មានថែវ តែមានបន្ទប់វែងព័ទ្ធជុំវិញសាជីស្ទើរតែជាប់នឹងរបងទី១ របស់ប្រាសាទ ។



***ផ្តែរនៃប្រាសាទមេបុណ្យខាងកើត***



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ផ្តែរទ្វារនៃ **ប្រាសាទមេបុណ្យខាងកើត** បង្ហាញពីព្រះឥន្រ្ទជិះលើ ដំរីក្បាលបី ដែលជាម្ចាស់លើសត្វ ទឹក និងធម្មជាតិ ។ ទន្ទឹមនឹងនេះ ស្ថាបត្យករលម្អផ្តែរដោយសត្វមករ សត្វនាគ តំណាងឱ្យទឹក និង រាហ៊ូតំណាងឱ្យព្រលឹងអមតៈ ។

## ១.៤.១១. ប្រាសាទ បន្ទាយស្រី

ប្រាសាទបន្ទាយស្រី ត្រូវបានចាប់ផ្តើមសាងសង់នៅ គ.ស. **៩៦៧** ដោយព្រះរាជគ្រូរបស់ព្រះបាទ **រាជេន្ទ្រវរ្ម័ន** ឈ្មោះ **យជ្ញវរាហៈ** នៅទិសខាងជើងនៃ **យសោធរបុរៈ** ។ ប្រាសាទនេះសាងសង់ក្នុងរជ្ជកាលនៃស្តេចពីរអង្គ ដោយសារនៅក្នុងគ.ស.៩៦៧ ព្រះបាទ **រាជេន្ទ្រវរ្ម័ន** សោយទិវង្គត ហើយបុត្ររបស់ព្រះអង្គព្រះនាម **ជ័យវរ្ម័នទី ៥** បានឡើងសោយរាជ្យ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទបន្ទាយស្រី គឺជាប្រាសាទសង់ពីថ្មភក់ពណ៌ផ្កាឈូក ប្រកបដោយចម្លាក់យ៉ាងល្អពាសពេញតួប្រាសាទ ។ រចនាបថ **បន្ទាយស្រី** គឺជារចនាបថឯក ដែលល្អយ៉ាងវិសេសវិសាល ដែលឆ្លុះបញ្ចាំងពីសម្រស់ដ៏ឧត្តុង្គឧត្ដម និង សុក្រិតភាពនៃក្បូរក្បាច់រចនា និងស្ថាបត្យកម្មនៃប្រាសាទនេះ ។ ផ្ដែរនៃប្រាសាទបន្ទាយស្រីបង្ហាញពីការបន្តរចនាបថនៃប្រាសាទប្រែរូប និង មេបុណ្យខាងកើត និងការចម្លងតាមផ្ដែរនៃប្រាសាទលលៃ ប្រាសាទព្រះគោ និងប្រាសាទបាគង ។



ផ្ដែរប្រាសាទបន្ទាយស្រីមានក្បាច់ផ្ដេក ដែលកាត់ផ្ដែរជាបួនកង់ ដែលមានលក្ខណៈដូចរចនាបថ សម្បូណ៌ព្រៃគុក និង រចនាបថព្រៃក្មេង ។ ចំពោះសសរពេជ្រវិញ យើងឃើញមានប្រើឡើងវិញនូវសសរពេជ្រមូលជាលើកចុងក្រោយនៃប្រាសាទបុរាណខ្មែរ ដោយប្រើប្រាស់លាយឡំជាមួយនឹងសសរពេជ្ររាងអដ្ឋកោណ ។ ចំណែកឯក្បូរក្បាច់កម្រងផ្កា និង ភ្ញីផ្កាវិញត្រូវបានប្រើប្រាស់ទាំងនៅផ្នែកខាងលើ និងផ្នែកខាងក្រោមនៃសសរពេជ្រ ។ ហោជាងគឺជាសមាសធាតុដ៏សំខាន់បំផុតនៃរចនាបថ **បន្ទាយស្រី** ។







fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ដូចហោជាងនៃរចនាបថកោះកេរ្តិ៍ ហោជាងនៃប្រាសាទបន្ទាយស្រីមានបីប្រភេទ ÷ មានរាងជាអក្សរ U ផ្កាប់ចុះ មានបីជាន់ និងមានរាងធ្មេញរណា (រូបខាងលើ) ហោជាងខ្មែរមានច្រើនជាន់ និង ហោជាងត្រីកោណ។ ចំណែកឯក្បូរក្បាច់រចនាលើផ្ទៃហោជាងវិញមាន លម្អដោយស្លឹកឈើព័ទ្ធជុំវិញទេវរូប ឬ រឿងដែលដកស្រង់ពីទេវកថាឥណ្ឌា ។ គែមខាងក្រៅនៃហោជាង ពត់ពេនចេញជាក្បាលនាគរាជ្យយ៉ាងវិសេសវិសាល ។ ចំណែកឯសសរប្រាសាទបន្ទាយស្រីមានលម្អដោយក្បូរក្បាច់រចនា និងការកែឆ្នៃរូប រាហ៊ូ មករ សឹង្ហ និង នាគរាជ ហើយជាពិសេសគឺផ្កាឈូក ។

## ១.៤.១២. រចនាបថ ឃ្លាំង

ស្ថាបត្យកម្មនៃរចនាបថឃ្លាំងត្រូវបានចាប់ផ្ដើមសាងសង់នៅចុងស.វ.ទី១០ និង ដើមស.វ.១១ តាមរយៈការសាងសង់ប្រាសាទតាកែវ ប្រាសាទវិមានអាកាស (នៅក្នុងព្រះបរមរាជវាំង) ប្រាសាទឃ្លាំង និង ប្រាសាទព្រះវិហារ ។ ស្ថាបត្យកម្មនៃរចនាបថឃ្លាំងមានការរីកចម្រើន ក្នុងការសាងសង់ប្រាសាទ-ភ្នំ ដែលមានលក្ខណៈពេញលេញ ដោយដកស្រង់នូវបទពិសោធន៍ក្នុងសាងសង់សាលវែង នៅក្នុងរចនាបថ ដើម្បីឆ្នៃឱ្យក្លាយទៅជាកំពែងថែវមានដំបូលជារូតប្រក់ឥដ្ឋ ឬ ថ្មភក់ រត់ពីលើព្រលាននៃខឿនព័ទ្ធជុំវិញប្រាង្គកណ្ដាល ។ នៅប្រាសាទតាកែវ ស្ថាបត្យករបុរាណខ្មែរសង់ជាលើកដំបូង នូវថែវព័ទ្ធជុំវិញនៅលើខឿនរាងសាជី ដែលមានដំបូលរូតប្រក់ឥដ្ឋ ។ តែឥដ្ឋនេះបែកបាក់ខូចអស់ហើយ ។ នៅប្រាសាទវិមានអាកាស ស្ថាបត្យករបុរាណបានសង់ថែវព័ទ្ធជុំវិញ លើខឿនខ្ពស់ជាងគេនៃសាជី ។ នេះជាប្រាសាទខ្មែរទីមួយ ដែលមានថែវមានដំបូលប្រក់រូតធ្វើពីថ្មភក់ ។ ប្រាសាទតាកែវ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទព្រះវិហារ គឺជាស្នាដៃកំពូលក្នុងចំណោមប្រាសាទបុរាណខ្មែរ ។



***ប្រាសាទឃ្លាំងខាងជើង***



***ផ្តែរនៃប្រាសាទឃ្លាំងខាងជើង***



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



*ផ្តែរនៃប្រាសាទឃ្លាំងខាងត្បូង*

ចំពោះផ្តែទ្វារវិញ យើងមិនឃើញមានការប្រែប្រួលអ្វីប្លែកឡើយ ហើយថែមទាំងមានសម្រស់អន់ជាងមុន ដោយសារតែមានលក្ខណៈដដែលៗ ។ នៅចំកណ្តាលផ្តែរ គេឃើញមានរាហ៊ូខ្ទាក់ស្លឹកឈើដែលធ្លាប់បានជួបប្រទះ នៅលើប្រាសាទបន្ទាយស្រីរួចមកហើយ ។ ផ្តែរនៃរចនាបថឃ្លាំងផ្តោតការយកចិត្តទុកដាក់លើមនុស្ស ជាពិសេស លម្អស្រ្តី ជីវិតក្នុងគ្រួសារ និងធម្មជាតិ ដូចជាចម្លាក់សត្វស្រុក ស្លឹកឈើ ទងឈើ និងសត្វស្លាប ។ រូបបដិមាករទទួល នូវឥទ្ធិពលពីរចនាបថប្រែរូប និងបន្ទាយស្រី មានដងខ្លួនស្រទ្បូន និងទឹកមុខស្លូតបូត ហើយសំពត់មានហោប៉ៅពីរ នៅលើភ្លៅទាំងពីរ ។



ហោជាងនៃរចនាបថឃ្លាំង ដូចជាហោជាងនៃប្រាសាទព្រះវិហារមានរាងត្រីកោណ ដែលជាហោជាងដែលឃើញមានចុងក្រោយគេបង្អស់នៃរចនាបថប្រាសាទខ្មែរ ។

## ១.៤.១៣. រចនាបថ បាពួន

ស្ថាបត្យកម្មខ្មែរនៅពាក់កណ្តាល និងចុងសតវត្សរ៍ទី ១១ ដែលជារចនាបថ **បាពួន** បានឈានដល់កម្រិតកំពូលនៃការសាងសង់ប្រាសាទ-ភ្នំដែលខ្ពស់ចោត ។ ដោយសារតែប្រាសាទនេះសង់ខ្ពស់ និងចោតពេក ទើបបានជារលំដួលខ្ទេចយ៉ាងខ្លាំង ។ នាពេលបច្ចុប្បន្ននេះ សាលាបារាំងចុងបូព៌ាកំពុងជួសជុលឡើងវិញអស់រយៈពេល ១០ កន្លងទៅហើយ ។



**ប្រាសាទបាពួន** មានថែវធ្វើពីថ្មភក់ព័ទ្ធជុំវិញប្រាង្គកណ្តាល មានកំផែង និងគោបុរះជាច្រើន និងមានវិមានដែលសង់នៅតាមជ្រុង ។ យើងសង្កេតឃើញថាមិនសូវមានការវិវត្តនៃក្បូរក្បាច់រចនាប៉ុន្មានទេ ។ នៅក្នុងរចនាបថ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



**បាពួន** លែងមានរាហ៊ូខ្ជាក់ស្លឹកឈើទៀតហើយ ។

ក៏ប៉ុន្តែអ្វីដែលថ្មីនោះ គឺ ផ្តែរទ្វារនៃរចនាបថបាពួនបង្ហាញពីទេវកថាឥណ្ឌា ដូចជារឿងរាមកេរ្តិ៍ជាដើម ចំណែកឯលើផ្ទៃហោជាងវិញ មានរចនាក្បូរក្បាច់ស្លឹកឈើយ៉ាងស្រស់បំព្រង ហើយលែងមានក្បាលរាហ៊ូទៀតហើយ ដែលឆ្លុះបញ្ចាំងពីការត្រឡប់ទៅរកធម្មជាតិវិញ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ហោជាងនៃប្រាសាទ **បាពួន** មានពីរជាន់ ។ ជាន់ខាងមុខលម្អដោយនាគរាជក្បាលប្រាំ ដែលធ្លាក់នៅគែមហោជាង ដែលមានកន្ទុយជាប់គ្នានៅត្រង់កំពូលជ្រុងលើនៃហោជាង ។ នៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗ ។ នៅកណ្ដាលហោជាងមានលម្អដោយក្បាច់ភ្ញីរុក្ខជាតិដ៏ស្រស់បំព្រង ។ ហោជាងជាន់ទីពីរលម្អដោយនាគរាជផងដែរ ហើយនៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗផងដែរ ។ រចនាបថហោជាងនេះ យើងហៅថាជារចនាបថ **បាពួន** ។ នៅពេលដែលយើងសិក្សាពីប្រាសាទព្រះវិហារនៅក្នុងជំពូកខាងក្រោយ យើងនឹងឃើញថា ប្រាសាទនៅក្នុងគោបុរៈទី ៤ នៃប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើងតាមរចនាបថ **បាពួន** នេះ ។

នៅលើជញ្ជាំងប្រាសាទមានចម្លាក់លិប (Bas-relief) លើផ្ទាំងថ្មតម្រួតលើគ្នា ។ ចំណែកឯសិល្បៈស្និតរបស់ខ្មែរធ្វើពីសំរិទ្ធបានឈានដល់កម្រិតកំពូល នៅចុងសតវត្សរ៍ទី ១១ នេះ ដូចមានតឹកតាងនៃរូបចម្លាក់ «**វិស្ណុផ្ទំ**» នៅសារមន្ទីរជាតិជាភស្តុតាងស្រាប់ ។ ប្រាសាទនៃរចនាបទ **បាពួន** មាន ÷ ប្រាសាទបាពួន ប្រាសាទមេបុណ្យខាងលិច និងប្រាសាទខ្នាសែនកែវ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## ១.៤.១៤. រចនាបថ អង្គរវត្ត

នៅចុងសតវត្សរ៍ទី ១១ និងពាក់កណ្ដាលទីមួយនៃសតវត្សរ៍ទី ១២ ស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ ។ យើងឃើញថា បន្ទាប់ពីមានការវិវត្តក្នុងរយៈពេល ៥០០ ឆ្នាំមក ទើបពីសិល្បៈ និងស្ថាបត្យកម្មខ្មែរជាពិសេស ក្បូរក្បាច់រចនានៅលើប្រាសាទ បានឈានដល់កម្រិតកំពូលយ៉ាងសុក្រឹតមួយដ៏ល្អស្ងប់ស្ងែងដែលជាបេតិភ័ណ្ឌរបស់មនុស្សជាតិទាំងមូល និងជាមោទនភាពជាតិខ្មែរ ។ ទាំងប្រាសាទអង្គរវត្ត ទាំងបារាយណ៍ព័ទ្ធជុំវិញប្រាសាទ គឺជាស្នាដៃស្ថាបត្យកម្ម និងសំណង់ ដែលគួរឱ្យរំភើបស្ងប់ស្ងែងក្រៃលែង ។ ប្រាសាទទាំងអស់នៃរចនាបថអង្គរវត្តសុទ្ធតែសាងសង់ឡើងដោយប្រើថ្មភក់ទាំងអស់ ពី គ. ស. ១.១០០ ដល់ គ. ស. ១.១៧៥ ។

នៅប្រាសាទអង្គរវត្ត ទីព្រលាន សាជី គោបុរៈ និង ក្លោងទ្វារចូល កំពូលប្រាង្គប្រាសាទកណ្ដាល កំពែងថែវ និង បណ្ណាល័យបង្ហាញពីស្នាដៃដ៏អស្ចារ្យនៃស្ថាត្យកម្មខ្មែរបុរាណនិយម ដោយមានការបូកផ្សំគ្នារវាងប្រាសាទសាជី និងប្រាសាទសង់ផ្ទាល់ដី ។ បុព្វបុរសខ្មែរបានប្រើប្រាស់នូវបទពិសោធន៍ក្នុងការកសាងប្រាសាទបុរាណពីពេលមុនដើម្បីរចនាលម្អផ្តែរទ្វារ សសរពេជ្រ ហោជាង សសរទ្រូ និង ទ្វារបញ្ឆោតឱ្យដល់កម្រិតកំពូល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ផ្តែរទ្វារ និង រូបចម្លាក់សម័យអង្គរវត្តបានផ្តល់តម្លៃទៅលើមនុស្ស និងភាពសុខុដុមរមនារវាងមនុស្សធម៌ និងវប្បធម៌ ។ ផ្តែរទ្វារនៃរចនាបថអង្គរវត្តមានពីរប្រភេទ គឺផ្តែរដែលគ្មានក្បាច់មែកឈើផ្តេក និង ផ្តែរដែលមានក្បាច់មែកឈើបាក់ជាកំណាត់ ៗ (រូបខាងក្រោម) ។





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



សសរពេជ្រនៃរចនាបថអង្គរវត្តបានវិវត្តទៅមុខ ដោយមានឆ្លាក់ក្បាច់ចិញ្ចៀនរហូតដល់ ១០ ឬ ១២ ។ ហោជាងនៃរចនាបថអង្គរវត្តរក្សានូវរាងធ្នូរកំប៉ោង ដូចរចនាបថមុនដែរ (រូបខាងលើ) តែលើផ្ទៃហោជាងក្បាច់ក្បូរស្លឹកឈើត្រូវបានជំនួសដោយរឿងទេវកថា **មហាភារតៈ** និង **រាមកេរ្តិ៍** វិញ ។ ម៉្យាងវិញទៀត នៅលើជញ្ជាំងប្រាសាទអង្គរវត្តមានឆ្លាក់ចម្លាក់លិប (Bas-relief) លើផ្ទាំងថ្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសនៅលើជញ្ជាំងនៃថែវប្រាសាទ ដែលដកស្រង់ពីឈុតល្បីៗនៃទេវកថា **មហាភារតៈ** និង **រាមកេរ្តិ៍** ដូចជា **កូរសមុទ្រទឹកដោះ** ជាដើម ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



នៅប្រាសាទអង្គរវត្តមានចម្លាក់លៀន (Haut-relief) ជាច្រើននៅលើសសរពេជ្រ និងលើជញ្ជាំង ជារូបស្រីទេពអប្សរជាង ១.៧០០ ដែលមានម៉ូតសក់ គ្រឿងអលង្ការ និង របៀបតុបតែងលម្អខុសៗគ្នា ។ រូបបដិមាករជាចម្លាក់លោត (Ronde-bosse) នៃរចនាបថអង្គរវត្តក៏បានឈានដល់កម្រិតកំពូលដែរ ។ ប្រាសាទនៃរចនាបទ **អង្គរវត្ត** មាន ÷ ប្រាសាទបឹងមាលា ព្រះបាលិល័យ ប្រាសាទភីម៉ៃ ព្រះពិធុ ចៅសាយទេវតា ធម្មានន្ត បន្ទាយសំរែ អង្គរវត្ត វត្តអាធ្វា ព្រះខ័នកំពង់ស្វាយ ប្រាសាទសូភាព និង ប្រាសាទទោល (បាគង) ។

## III-ស្ថាបត្យកម្មក្រោយសម័យអង្គរ

រចនាបថក្រោយសម័យអង្គរ គឺជារចនាបថ **បាយ័ន** ពីចុងសតវត្សរ៍ទី ១២ ដល់ ដើមសតវត្សរ៍ទី ១៣ (ពី គ.ស. ១.១៧៧ ដល់ គ.ស. ១.២៣០) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.៤.១៥. រចនាបថ បាយ័ន

នៅគ.ស. ១១៦៥ ចាមបានលើកទ័ពជើងទឹកវាយចូលអាណាចក្រខ្មែរ ចូលតាមដងទន្លេមេគង្គ ឡើងរហូតដល់បឹងទន្លេសាប និង វាយយករាជធានីអង្គរបាន ។ ព្រះបាទ **ជ័យវរ្ម័នទី ៧** គឺជាព្រះរាជាដែលបានរំដោះអាណាចក្រខ្មែរឱ្យមានឥស្សរភាពឡើងវិញ ។ ព្រះអង្គទទួលរាជាភិសេក និង ឡើងសោយរាជ្យនៅ **យសោធរបុរ** នៅ គ.ស. ១.១៨១ នៅពេលដែលព្រះអង្គមានព្រះជន្មាយុ ៥៦ ព្រះវស្សា ។ បន្ទាប់ពីឡើងសោយរាជ្យ ព្រះអង្គបានចាត់ចែងឱ្យសាងសង់ **អង្គរធំ ៣** ដែលមានកំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញ មានគោបុរៈចំនួន ៥ និងមាន **ប្រាសាទបាយ័ន** នៅចំកណ្តាល ។ ព្រះអង្គមានព្រះមហេសីពីរអង្គ ដោយព្រះបាទ **ជ័យវរ្ម័នទី ៧** បានរៀបអភិសេកជាមួយព្រះនាង **ឥន្ទ្រទេវី** ដែលជាបងបង្កើតរបស់ព្រះនាង **ជ័យរាជទេវី** ដែលបានសោយទិវង្គតទៅនោះ ។ ព្រះអង្គជាព្រះមហាក្សត្រជំនាន់អង្គរទី១ ដែលគោរពព្រះពុទ្ធសាសនាមហាយាន ។

ព្រះបាទ **ជ័យវរ្ម័នទី ៧** បានសាងសង់ប្រាសាទជាច្រើនសន្ធឹកសន្ធាប់ ដែលមានរចនាបថ **បាយ័ន** ។ ប្រាសាទទាំងនោះមាន ប្រាសាទបាយ័ន ស្រះស្រង់ តាព្រហ្ម តាសោម បន្ទាយក្តី ព្រះខ័ន នាគព័ន្ធ បន្ទាយឆ្មា ប្រាសាទជ្រុង ប្រាសាទប្រជល់ដីរ តាព្រហ្មបាទី ប្រាសាទបាណន់ វត្តនគរ តាណី ក្រោលគោ បន្ទាយព្រៃ ប្រាសាទព្រៃ




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និង ព្រះថុល ។ល។ ដែលជាប្រាសាទនៃរចនាបថ **បាយ័ន** សាងសង់ឡើងពី គ.ស. ១.១៧៧ ដល់ គស.១.២៣០។ ក្រៅពីនេះ ព្រះអង្គបានសាងសង់ ធម្មសាលាចំនួន ១២១ និង មន្ទីរពេទ្យចំនួន ១០២ ។ អ្នកស្រាវជ្រាវខ្លះសឹងតែមិនជឿថា ក្នុងរយៈនេះ មានប្រាសាទដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានសាងសង់ឡើង នៅក្នុងអាណាចក្រខ្មែរ ។ ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ច្រើនលើសលុបនេះ ស្ថាបត្យករបុរាណខ្មែរបានកៀងគរប្រជាពលរដ្ឋប្រុស- ស្រី ទោះមាន ឬ គ្មានជំនាញក្តី ដើម្បីចូលរួមសាងសង់ប្រាសាទ ។ ដោយសារតែបញ្ហានេះហើយ និងគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្មចម្រុះគុណភាព និង ការសាងសង់ដោយប្រញាប់ប្រញាល់នេះហើយ ទើបប្រាសាទមួយចំនួនឆាប់បាក់បែកទ្រុឌទ្រោមជាងប្រាសាទនៃរចនាបថមុនៗ ។



លោក **ហ្វីលីព ស្ទែន** នៅក្នុងអត្ថបទរបស់លោកដែលមានចំណងជើងថា «វិមានខ្មែរនៃរចនាបថ **បាយ័ន** និង ព្រះបាទ **ជ័យវរ្ម័នទី ៧**» ដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៦៥ បានបែងចែកប្រាសាទនៃរចនាបថ **បាយ័ន** នេះ ជាបីដំណាក់កាលទៀត ដែលឆ្លុះបញ្ចាំងការវិវត្តផ្ទៃក្នុងនៃរចនាបថ **បាយ័ន** នេះ កាលបរិច្ឆេទនៃការសាងសង់ប្រាសាទ និងតួនាទីនៃប្រាសាទទាំងនេះ នៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី ៧** ៖

**ដំណាក់កាលទី១**- ប្រាសាទលម្អដោយ ទេវតាមានសក់រាងសាជី ដៃច្រត់ចង្កេះ ស្លៀកសំពត់វែកតូច ដោយគ្មានគ្រឿងអលង្ការមួយចំនួន គ្មានមុខញញឹម អង្គចបញ្ឆោតមានចម្រឹងខ្ពស់ ខ្លោងទ្វារតូចចង្អៀត និង អវត្តមាននៃកំពូលប្រាសាទដែលមានមុខបួន ។ នៅដំណាក់កាលទី១ ពីគ.ស. ១.១៧៧ ដល់ គស.១.១៩១ ព្រះបាទ **ជ័យវរ្ម័នទី ៧** បានសាងសង់ប្រាសាទ **តាព្រហ្ម** ដើម្បីឧទ្ទិសដល់ព្រះមាតារបស់ព្រះអង្គ (ដែលប្រៀបបានទៅនឹង **បញ្ញាបរមីតា**) និងសង់ប្រាសាទ **ព្រះខ័ន** ដើម្បីឧទ្ទិសដល់ព្រះបិតារបស់ព្រះអង្គ (ដែលប្រៀបបានទៅនឹង **លោកិស្វរៈ**) ។ បន្ទាប់មកព្រះអង្គសាងប្រាសាទ **បន្ទាយក្តី** ដើម្បីឧទ្ទិសដល់ **ព្រះពុទ្ធ** ដែលជា **ត្រីមូរ្តិ** ទាំងបីនៃពុទ្ធសាសនាមហាយាន (**បញ្ញាបរមីតា- លោកិស្វរៈ- ព្រះពុទ្ធ**) ។

**ដំណាក់កាលអន្តរកាល**- ការលេចឡើងនូវបង្អួចបញ្ឆោតមានសន្លឹកបិទ រូបពុទ្ធរូបលម្អព្រំដំបូល ទ្រីស្តី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ស្ដីពីទេវរូប និង អសុរៈកាន់ពស់ និង លោកិស្វរៈ ។ នៅដំណាក់កាលនេះព្រះបាទ **ជ័យវរ្ម័នទី ៧** បានដាក់ចេញនូវកំណែទម្រង់សាសនាយ៉ាងធំធេង ១០ ឆ្នាំក្រោយពេលព្រះអង្គឡើងគ្រងរាជ្យ ដោយលើកដម្កើង **លោកិស្វរៈ**។




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដំណាក់កាលទី២**- ប្រាសាទដែលលម្អដោយលក្ខណៈពិសេសនៅក្នុងសម័យអន្តរកាល និងមានការលេចឡើងនូវកំពូលប្រាសាទដែលមានមុខបួន សត្វឆ្លាក់នៅតាមមុម (ដំរី ហង្ស គ្រុឌ) ទេវតាវែកសក់ភ្ជិបីមានរាងជាកំប៉ោយរាងត្រីកោណ តាក់តែងលម្អដោយខ្សែក ខ្សែក្រវាត់ និងមានទឹកមុខញញឹម ។

**ដំណាក់កាលទី៣**- ប្រាសាទដែលមានទេវតាមានកំប៉ោយសក់រាងត្រីកោណ សំពត់ផែករាងត្រីកោណ សក់លម្អដោយស្លឹកឈើ គ្រឿងអលង្ការជាខ្សែក និងខ្សែក្រវ៉ាត់ និងពាក់កម្រងផ្ការាងដូចពស់ ។ល។

លក្ខណៈពិសេសនៃរចនាបថ **បាយ័ន** នៅសតវត្សរ៍ទី ១៣ គឺការសាងសង់ប្រាសាទដែលកំពូលមានមុខបួនដែលជាតំណាង **លោកិស្វរៈ** ដែលជាតក្កកម្មខាងផ្នែកស្ថាបត្យកម្មផង និង ខាងផ្នែកសំណង់ផង ដែលយើងអាចចាត់ទុកថាជារូបចម្លាក់ដ៏ធំធេងនៅក្នុងសិល្បៈខ្មែរ ដែលផ្សាភ្ជាប់ទៅនឹងជំនឿសាសនា ។ សមិទ្ធផលដ៏ធំធេងមួយទៀតនៃរចនាបថ **បាយ័ន** គឺការសង់កំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញរាជធានីអង្គរធំ មានគោបុរៈចំនួន ៥ ដែលមានទទឹង ៣ គីឡូម៉ែត្រ និង បណ្តោយ ១២ គីឡូម៉ែត្រ ។ ប្រការនេះ គឺជាលើកទីមួយហើយដែលព្រះមហាក្សត្រខ្មែរសង់កំពែងដើម្បីការពារក្រុងពីសត្រូវឈ្លានពាន ។

តក្កកម្មទី ៣ នៃរចនាបថ **បាយ័ន** គឺការសង់ប្រាង្គ **ប្រាសាទបាយ័ន** ដែលជាស្នាដៃដ៏វិសេសវិសាលនៃបុព្វបុរសខ្មែរ ។ ប្រាង្គកណ្តាលនៃប្រាសាទបាយ័នមានរាងមូល សម្រាប់ដម្កល់បដិមាពុទ្ធរាជ្យមួយអង្គ ដែលមានកំពស់ជិត ៤ ម៉ែត្រ ហើយឆ្លុះបញ្ចាំងពីការចម្រើនលូតលាស់ និង ភាពល្បីល្បាញខ្ទរខ្ទារសុសសាយនៃ **លោកិស្វរៈ** ដែលបែរមុខទៅទិសទាំង ៨ ដើម្បីសំដែងនូវមេត្តាធម៌ដល់រាជធានី អាណាចក្រ ពិភពលោក និង ចក្រវាឡទាំងមូល ។ ប្រាសាទនៃរចនាបថ **បាយ័ន** ឆ្លុះបញ្ចាំងពីតម្លៃបែបអរូបិកម្មរបស់សិល្បៈខ្មែរ ដោយឈរលើមូលដ្ឋាននៃគម្រូតែមួយ ដោយរក្សានូវសមតាបានល្អឥតខ្ចោះ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២

# ទីតាំងភូមិសាស្ត្រ សាសនា និង ព្រះមហាក្សត្រខ្មែរដែលកសាងប្រាសាទព្រះវិហារ

## ២.១. ទីតាំងភូមិសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្នុងអាស៊ីភាគអគ្នេយ៍ នៅចន្លោះខ្សែស្របទី ១០ និង ទី ១៥ នៃរយៈទទឹងខាងជើង និង ចន្លោះខ្សែបណ្ដោយទី ១០២ និង ទី ១០៨ នៃរយៈបណ្ដោយខាងកើត ដែលស្ថិតក្រោមឥទ្ធិពលខ្យល់មូសុង ។ កម្ពុជាមានផ្ទៃក្រឡាចំនួន ១៨១.០៣៥ គីឡូម៉ែត្រក្រឡា និង មានរាងជា **ពហុកោណ** ដែលមានចំណុចកណ្ដាលស្ថិតនៅត្រង់ខេត្តកំពង់ធំ ។ កម្ពុជាមានព្រំប្រទល់ ខាងជើងជាប់នឹងព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ខាងកើត ជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងត្បូងជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម និង ឈូងសមុទ្រថៃ និង ខាងលិច ជាប់នឹងព្រះរាជាណាចក្រថៃឡង់ ។ កម្ពុជាមានព្រំដែនប្រវែង ២.៦០០ គីឡូម៉ែត្រ ដែលក្នុងនោះប្រាំភាគប្រាំមួយ គឺជាព្រំដែនគោក ។ ប្រជាជនកម្ពុជាមានចំនួន ១៣, ៣៨ លាននាក់នៅក្នុងឆ្នាំ ២០០៨ ។

កម្ពុជាសម្បូណ៌ទៅដោយធនធានធម្មជាតិ ជាពិសេស ធនធានព្រៃឈើ មច្ឆជាតិទឹកប្រៃ និងទឹកសាបជីវចម្រុះសម្បូណ៌បែប និងតំបន់កសិកម្មដែលមានដំណាំដាំដុះផ្សេងៗជាច្រើនប្រភេទ និងមានសត្វពាហនៈទៀតផង ។ សណ្ឋានដីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃផតកណ្ដាល ដែលនៅចំណុចកណ្ដាល គឺជាបឹងទន្លេសាប ហើយមានជាយជុំវិញជា ភ្នំ ជាកូនភ្នំ និង ជាខ្ពង់រាប ។ ផ្ទៃនេះចុះទេរពីភ្នំក្រវាញសំដៅទៅឈូងសមុទ្រថៃ ដែលជាទីសម្បូណ៌កូនកោះ ។ ទន្លេមេគង្គ និង បឹងទន្លេសាបផ្គត់ផ្គង់នូវប្រភពទឹកដ៏ច្រើនលើសលុប ដែលចាំបាច់សម្រាប់ការដាំដុះនៅរដូវប្រាំង និងជាប្រភពមិនចេះរីងស្ងួតដ៏សំខាន់នៃត្រីទឹកសាប ។ យើងអាចបែងចែកភូមិភាគធម្មជាតិជាបីតំបន់ធំៗគឺៈ តំបន់ខ្ពង់រាប តំបន់ទំនាប និងតំបន់មាត់សមុទ្រ ។

**តំបន់ខ្ពង់រាប** ចែកចេញជាតំបន់ខ្ពង់រាបខាងជើង គឺតំបន់ភ្នំដងរែក និង តំបន់ខ្ពង់រាបព្រំសាន្ត គឺខ្ពង់រាបរតនគីរី និង ខ្ពង់រាបមណ្ឌលគីរី ។ **តំបន់ភ្នំដងរែក** គឺជាគែមនៃខ្ពង់រាប **នគររាជ** ដែលស្ថិតនៅក្នុងប្រទេសថៃ ។ គែមនេះមានច្រាំងចោត ដែលមានកំពូលខ្ពស់បំផុត គឺ ភ្នំ **ដងរែក** (៧៥៦ ម.) ហើយមានរយៈកំពស់មធ្យមពី ៣០០


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទៅ ៥០០ ម. ។ គឺនៅ លើជួរភ្នំដងរែកនេះហើយ ដែលបុព្វបុរសខ្មែរបានកសាងនូវប្រាសាទបុរាណ ដើម្បីគោរពបូជាដល់ព្រហ្មញ្ញសាសនា ហើយប្រាសាទដែលល្បីល្បាញជាងគេ គឺ **ប្រាសាទព្រះវិហារ** ដែលស្ថិតនៅនាជិតតំបន់មុមបីដែលជាព្រំប្រទល់នៃប្រទេសកម្ពុជា ឡាវ និង ថៃឡង់ ។ នៅតាមជួរភ្នំដងរែកនេះ យើងនៅមាន **ប្រាសាទតាមាន់** និង **ប្រាសាទតាក្របី** ផងដែរ ។

ប្រាសាទ **ព្រះវិហារ** ស្ថិតនៅក្នុងខេត្តព្រះវិហារនៃព្រះរាជាណាចក្រកម្ពុជា ដែលមានក្រុងឈ្មោះ **ត្បែងមានជ័យ** មានប្រជាជនប្រមាណជា ១៦១.៥៤៣ នាក់ មានស្រុកចំនួន ៧ ក្រុងចំនួន ១ ឃុំ- សង្កាត់ចំនួន ៤៩ និង ភូមិចំនួន ២០៨ ។ តំបន់នេះមានដង់ស៊ីតេប្រជាជនទាប និង មានព្រៃក្រាស់ ហើយអ្នកស្រុកមួយចំនួនធ្វើដំណាំព្រៃដុត បេះផ្លែឈើព្រៃ និង បរបាញ់សត្វ ។

នៅពេលដែលស្តេចខ្មែរផ្តើមសាងសង់ប្រាសាទព្រះវិហារនោះឡើង នៅក្នុងខេត្តព្រះវិហារនៃដែនដីព្រះរាជាណាចក្រកម្ពុជា កាលពីបុរាណសម័យនោះគឺពុំទាន់មានប្រទេសសៀមនៅឡើយទេ ។ កាលពីបុរាណសម័យអាណាចក្រខ្មែរមានផ្ទៃដីធំធេងផ្នែកខាងលិចគឺលាតសន្ធឹងពីខេត្តព្រះវិហារ ហួសប្រទេសថៃសព្វថ្ងៃ និងរហូតទៅដល់ប្រទេសភូមា ។ ចំណែកផ្នែកខាងជើងគឺលាតសន្ធឹងរាប់បញ្ចូល ទាំងក្រុងឈៀងម៉ៃនោះផង ។ ដីខ្មែរនៅវាតតាំងពីដែនដីកម្ពុជាក្រោមកូសាំងស៊ីនរហូតទៅដល់ខាងជើងនោះ គឺរហូត ទៅដល់វៀងចន្ទន៍ណោះ ។

ដូច្នេះគេយកដីនេះយកមកធ្វើជាប្រាសាទដែលវាលទំនាបដែលឡើងមកសព្វថ្ងៃ គឺឡើងមកពីខាងជើង ហើយគេធ្វើប្រាសាទហ្នឹងបែរមុខទៅទិសខាងជើង ។ ប្រាសាទនេះមិនមានលក្ខណៈ ដូចប្រាសាទឯទៀតៗឡើយ ។ ការសាងសង់ប្រាសាទព្រះវិហារនៅត្រង់ល្បាក់ជញ្ជាំងភ្នំធ្វើឱ្យប្រាសាទនេះកាន់តែមានមហិទ្ធិឫទ្ធិថែមទៀត សម្រាប់គោរពបូជាព្រះសិវៈលិង្គ ។

## ២.២. សាសនានៅក្នុងសិល្បៈវប្បធម៌ខ្មែរបុរាណ

ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ជាសាសនាជំនាន់ដើម ហើយដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការឥណ្ឌាភាវូបនីយកម្មនៃអាណាចក្រខ្មែរបុរាណ និងការចម្រើនលូតលាស់នៃសិល្បៈវប្បធម៌ខ្មែរ ។

### ២.២.១. ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌា នៅសតវត្សទី ១០ មុន គ.ស. ។ ជនជាតិខ្មែរចាប់ផ្តើមគោរពព្រហ្មញ្ញសាសនាចាប់តាំងពី គ.ស. ទី ១ តាមរយៈការផ្សព្វផ្សាយរបស់ឈ្មួញសំពៅជាតិឥណ្ឌាដែលបានមកធ្វើជំនួញនៅអាណាចក្រខ្មែរ និងបានប្រាស្រ័យទាក់ទង លក់ដូរទំនិញជាមួយអ្នកស្រុក ។ ឈ្មួញទាំង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នោះភាគច្រើនជាព្រាហ្មណ៍ ដែលជាអ្នកមានចំណេះដឹងជ្រៅជ្រះខាងផ្នែកព្រហ្មញ្ញសាសនា ។ ដូច្នេះ ពាណិជ្ជកម្មមិនគ្រាន់តែមានតួនាទីផ្លាស់ប្តូរទំនិញរវាងជនជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយមួយដ៏សំខាន់ក្នុងការផ្សព្វផ្សាយភាសា អារ្យធម៌ និង ទំនៀមទំលាប់រវាងជនជាតិផ្សេងៗផងដែរ ។ ម្ល៉ោះហើយ ឥទ្ធិពលសាសនាព្រាហ្មណ៍ក៏បានជ្រួតជ្រាបចូលក្នុងសង្គមខ្មែរ ជាពិសេសក្នុងស្រទាប់បញ្ញវ័ន្ត និងមន្ត្រីរាជការក្នុងប្រទេស ។

រឿងនិទានខ្មែរបានរៀបរាប់ពីការចងស្ពានមានមេត្រីរវាងព្រះមហាក្សត្រិយ៍ខ្មែរជំនាន់ដើម នៅពាក់កណ្តាលទី១ នៃ គ.ស. គឺព្រះនាងលិវយី ដែលលើកទ័ពទៅទប់ទល់នឹងទ័ពសំពៅឥណ្ឌា ក្រោមបញ្ជាការរបស់ព្រះបាទហ៊ុនទៀន ដែលជាព្រាហ្មណ៍ ដែលបានចូលមកក្នុងទឹកដីខ្មែរដំបូង ។ បន្ទាប់ពីទទួលបានជ័យជំនះរួចមកព្រះបាទហ៊ុនទៀនបានប្រកាសខ្លួនជាស្តេចផែនដី និងបានរៀបព្រះរាជាពាហ៍ពិពាហ៍ជាមួយព្រះនាងលិវយី ។ ចាប់ពីពេលនោះមក ព្រះបាទហ៊ុនទៀនបានរៀបចំប្រព័ន្ធគ្រប់គ្រងទឹកដី ទៅតាមទស្សនៈរាជាធិបតេយ្យបែបព្រាហ្មណ៍ ។

ព្រះបាទហ៊ុនទៀន បានលើកដម្កើងព្រាហ្មណ៍ជាច្រើនរូប ឱ្យកាន់កិច្ចការរាជការ និង ទទួលបាននូវឋានៈខ្ពង់ខ្ពស់ទៀតផង ។ ប្រការនេះបានពង្រីកឥទ្ធិពលនៃលទ្ធិព្រហ្មញ្ញសាសនាឱ្យរីកដុះដាលកាន់តែខ្លាំងឡើងថែមទៀត ជាពិសេស ក្នុងចំណោមសិល្បៈករ បញ្ញវ័ន្ត មន្ត្រីរាជការជាន់ខ្ពស់ ។ ម៉្យាងវិញទៀត ដោយសារព្រះរាជាច្រើនអង្គនៅអាណាចក្រខ្មែរបុរាណគោរពបូជាយ៉ាងខ្ជាប់ខ្ជួននូវព្រហ្មញ្ញសាសនា ធ្វើឱ្យសាសនានេះមានការរីកចម្រើនលូតលាស់យ៉ាងខ្លាំងក្លា ។

### ២.២.២. ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាមានដើមកំណើតនៅឥណ្ឌា តែក្រោយព្រហ្មញ្ញសាសនា គឺនៅក្នុង ស.វ.ទី ៦ មុនគ.ស. ។ នៅក្នុងរជ្ជកាលព្រះបាទអសោក (ឆ្នាំ ២៧៣-២៣២ មុន គ.ស.) ព្រះពុទ្ធសាសនាត្រូវបានរីកផ្សព្វផ្សាយ ទាំងនៅប្រទេសឥណ្ឌា ទាំងនៅក្រៅប្រទេស តាមរយៈឈ្មួញឥណ្ឌា ដែលធ្វើពាណិជ្ជកម្ម និង ផ្សព្វផ្សាយវប្បធម៌ និង អារ្យធម៌ឥណ្ឌានៅកន្លែងផ្សេងៗក្នុងពិភពលោក ជាពិសេសនៅអាណាចក្រភ្នំ ។ នៅឆ្នាំ ២៥៣ មុន គ.ស. ព្រះថេរមហិន្ទៈជាបុត្រ ឬ ជាអនុជរបស់ព្រះបាទអសោក បាននាំយកព្រះពុទ្ធសាសនា **ថេរវាទ** ទៅផ្សព្វផ្សាយនៅកោះលង្កា ។ ឯកសារប្រវត្តិសាស្ត្រមិនបានកំណត់ច្បាស់ថា ព្រះពុទ្ធសាសនា **ថេរវាទ** នេះបានចូលមកប្រតិស្ឋានក្នុងអាណាចក្រខ្មែរឱ្យច្បាស់តាមណាទេ ។ ប្រភពខ្លះបាននិយាយថា ព្រះពុទ្ធសាសនាថេរវាទ ត្រូវបានផ្សព្វផ្សាយជាដំបូងនៅកោះលង្កា បន្ទាប់មកទើបគេយកមកផ្សព្វផ្សាយនៅអាណាចក្រភ្នំ ។ ប្រភពខ្លះបានអះអាងថា ព្រះពុទ្ធសាសនាត្រូវបានព្រះសោណត្ថេរ និង ព្រះឧត្តរត្ថេរជាបឋមសមណទូតនៃព្រះមហាថេរមោគ្គល្លីបុត្ត បានផ្សព្វផ្សាយនៅដែនសុវណ្ណភូមិនេះ ក្នុងឆ្នាំ ៣០៦ មុន គ.ស. ក្រោមសាសនូបត្ថម្ភរបស់ព្រះបាទអសោក ។ មានប្រភពខ្លះបានលើកឡើងថាព្រះពុទ្ធសាសនាចូលមកដែនដីខ្មែរ ក្នុងរជ្ជកាលព្រះបាទស្រីមារៈ ឬ ព្រះបាទហ្វាន់ចេម៉ុន ក្នុងគ្រិស្តសតវត្សទី ២ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| លទ្ធិ | ហីនយាន | មហាយាន |
|---|---|---|
| **បំណងប្រាថ្នាមនុស្ស** | យកព្រះអរហត្ត និងព្រះនិព្វាន | ទៅជាព្រះពោធិសត្វ ដែលមានពោធិញ្ញាណជាទីបំផុត |
| **ព្រះនិព្វាន** | បានដោយបុញ្ញកិរិយាវត្ថុ គឺសីលទាន និងការភាវនា | ដោយសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា |
| **ការសម្រេចគោលដៅ** | មានតែភិក្ខុទេ ដែលអាចទៅដល់ព្រះអរហត្ត | នៅជាឃរាវាស ក៏បានដល់ទីពោធិសត្វដែរ |
| **កុសល** | ខ្លួនទីពឹងខ្លួនៈ កុសលដែលអ្នកណាបានធ្វើនឹងនាំអ្នកនោះឱ្យរួចចាកទុក្ខ | កុសលរបស់ខ្លួនអាចនឹងផ្សព្វផ្សាយដល់អ្នកដទៃ |

នៅក្នុងរជ្ជកាលព្រះបាទកនិស្កៈ (ឆ្នាំ ៧៨ ដល់ ១០៥ ក្រោយ គ.ស.) ពុទ្ធសាសនាបានបែកជាពីរនិកាយ គឺ **ហីនយាន** និង **មហាយាន** ។ បុព្វហេតុចម្បងនៃការបែកជានិកាយពីរនេះ គឺបណ្តាលមកពីការប៉ះទង្គិចគ្នារវាងព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា ។ ពុទ្ធសាសនាដើម គឺ **ហីនយាន** មានវិន័យតឹងរ៉ឹង ធ្វើឱ្យអ្នកបួសកម្រសម្រេចបានដូចបំណង បើប្រៀបធៀបនឹងព្រហ្មញ្ញសាសនាដែលឆាប់សម្រេចជាង ។ ដូច្នេះ គណៈសង្ឃខ្លះបានបែកចេញពីពុទ្ធសាសនាដើម ក្នុងគោលដៅកែប្រែលទ្ធិខ្លះដើម្បីសម្រេចបានតាមគោលដៅឱ្យលឿនកុំឱ្យចាញ់ព្រាហ្មញ្ញសាសនា ដែលគេហៅថា **មហាយាន** (រទេះធំ) ។ លទ្ធិពុទ្ធសាសនាមហាយាន មានអាទិទេព គឺព្រះពោធិសត្វនៅជួយគ្រប់គ្រង ។

### ២.២.៣. ការគោរពបូជាសាសនាតាមសម័យកាល

នៅសម័យអាណាចក្រភ្នំ ប្រជាជនខ្មែរខ្លះគោរពបូជាព្រហ្មញ្ញសាសនា និង ខ្លះទៀតព្រះពុទ្ធសាសនា ។ នៅក្នុងព្រហ្មញ្ញសាសនា អ្នកខ្លះគោរពព្រះឥសូរ អ្នកខ្លះគោរពព្រះវិស្ណុ ។ ដល់ក្រោយសតវត្សទី ៨ ប្រជាជនខ្មែរគោរព **ព្រះហរិហរៈ** ដែលម្ខាងជាឥសូរ និងម្ខាងទៀតជាវិស្ណុ ដែលរូបចម្លាក់ច្រើនធ្វើអំពីសំរិទ្ធិ និង ថ្ម ។

នៅសម័យអាណាចក្រភ្នំ ព្រះពុទ្ធសាសនាមានការរុងរឿងក្រៃលែង ហើយអ្នកស្រុកច្រើនគោរពនិកាយហីនយាន ។ គេបានរកឃើញពុទ្ធរូបជាច្រើនអង្គធ្វើពីសំរិទ្ធិ ពីថ្ម ឬ ពីឈើ ជារចនាបថភ្នំដារ នៅអង្គរបុរី ដែលជាមជ្ឈមណ្ឌលផលិតបដិមាករទាំងនោះ ។ ព្រះពុទ្ធរូបសម័យនោះដែលរកឃើញ គឺ ព្រះពុទ្ធរូបថ្មនៅវត្តរំលកស្រុកព្រៃកប្បាស ខេត្តតាកែវ ព្រះពុទ្ធរូបសំរិទ្ធិនៅបាណន់ ខេត្តបាត់ដំបង និង ព្រះពុទ្ធរូបនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ ។

នៅសម័យចេនឡា លទ្ធិព្រហ្មញ្ញសាសនាមានការរីកចម្រើន ដោយសារប្រជាជនគោរពនូវទេវរូបទាំងបី គឺ ព្រះឥសូរ ព្រះវិស្ណុ និងហរិហរៈ ។

ព្រះពុទ្ធសាសនាមហាយាននៅសម័យចេនឡារុងរឿងណាស់ តែគេពុំសូវឃើញមានបដិមាពោធិសត្វ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អវលោកិស្វរៈទេ មានមួយនៅខេត្តក្រមួនស និងមួយទៀតនៅប្រាសាទសាកៀម ខេត្តសៀមរាប ។ ចំណែកលទ្ធិហីនយានក៏មិនសាបសូន្យដែរ ។

### ២.២.៤. លទ្ធិទេវរាជ និង ការគោរពបូជាសាសនានៅប្រាសាទព្រះវិហារ

យើងបានដឹងយ៉ាងច្បាស់ពីលទ្ធិទេវរាជពីសិលាចារឹក **ស្តុកកក់ធំ** ដែលអ្នកប្រាជ្ញជាតិបារាំងឈ្មោះ **ហ្សក សឺដែស** និង **ឱុយម៉ុង** បានសិក្សាយ៉ាងលម្អិតនៅក្នុងអត្ថបទមួយក្រោមចំណងជើងថា «**សិលាចារឹកស្តុកកក់ធំ ត្នុំសណ្តក និង ព្រះវិហារ**» ។ លទ្ធិទេវរាជនេះត្រូវបានបង្កើតឡើងដោយព្រាហ្មណ៍ **ហិរណ្យទាម** ដែលបានចងក្រងនូវគម្ពីបួនគឺ **វិនាសិខ- នយោត្តរ- សម្មោហ** និង **សិរច្ឆេទ** ដែលរៀបរាប់ពីរបៀបប្រារព្ធធ្វើពិធីទេវរាជ ។

នៅឆ្នាំ ៨០២ ព្រះបាទ **ជ័យវរ្ម័នទី ២** បានរៀបចំពិធី **ទេវរាជ** ដើម្បីប្រកាសឯករាជ្យដល់អាណាចក្រខ្មែរ ហើយធ្វើឱ្យព្រះរាជាទៅជា **ចក្រវាតិន** (អាទិទេពនៃស្តេច) លើភ្នំគូលែន (**មហេន្ទ្របវ៌ត**) ។ ក៏ប៉ុន្តែ មិនមែនមានន័យថា លទ្ធិទេវរាជនេះត្រូវតែរៀបចំឡើងនៅទីកន្លែងខ្ពស់ ឬ នៅលើប្រាសាទភ្នំឡើយ ។

ពិធីទេវរាជនេះត្រូវមានព្រាហ្មណ៍ជាអ្នករៀបចំ ។ ព្រាហ្មណ៍ដែលរៀបចំពិធីទេវរាជសម្រាប់ព្រះបាទ **ជ័យវរ្ម័នទី ២** គឺ **សិវកៃវល្យ** ដែលជា **រាជបុរោហិត** និង **រាជគ្រូ** របស់ព្រះអង្គ ។ បន្ទាប់ពីពិធីអភិសេកនេះ ព្រះបាទ **ជ័យវរ្ម័នទី ២** មានឋានៈជា **ទេវរាជ** ដែលពាក្យខ្មែរបុរាណហៅថា **កម្រតេងជគតតរាជ្យ** (*kamraten jagat ta raja*) ដែលមានន័យថា **ស្តេចដែលជាម្ចាស់នៃចក្រវាល** ។ បន្ទាប់ពីប្រសិទ្ធិហើយ ព្រះសិវលិង្គនេះក៏ក្លាយទៅជា **ទេវរូប** ដែលមានឋានៈជា **កម្រតេងជគតតរាជ្យ** ដែរ ។ ព្រះបាទ **ជ័យវរ្ម័នទី ២** និង ព្រាហ្មណ៍ **ហិរណ្យទាម** បានសច្ចាថា មានតែសមាជិកគ្រួសារព្រាហ្មណ៍ **សិវកៃវល្យ** ទេ ដែលអាចប្រារព្ធធ្វើពិធីទេវរាជបាន ។

បន្ទាប់ពីរៀបចំពិធីទេវរាជ ព្រះសិវលិង្គទទួលប្រសិទ្ធិ ហើយក្លាយទៅជាទេវរូបដែលគេរាល់គ្នាត្រូវគោរពបូជា ។ ព្រះសិវលិង្គនេះមានតែមួយទេ ហើយអាចយកទៅដម្កល់ទុកនៅកន្លែងជាទីសក្ការ និងអាចយកពីមួយកន្លែងទៅដម្កល់នៅមួយកន្លែងទៀត ។

ប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើងដើម្បីរក្សាទុកសិវលិង្គ សម្រាប់ជាទីសក្ការបូជាតាមលទ្ធិព្រហ្មញ្ញសាសនា និង លទ្ធិទេវរាជនេះ ។ ក៏ប៉ុន្តែ ប្រជាជននៅតាមតំបន់នោះក៏គោរពនូវព្រះពុទ្ធសាសនា និង លទ្ធិជីវចលផងដែរ ។ **លទ្ធិជីវចល** គឺជំនឿលើព្រលឹង វត្ថុស័ក្តសិទ្ធិ អ្នកតាព្រៃភ្នំ ឬ ដើមឈើដែលតែងតែការពារដល់មនុស្សលោក ។ នៅសម័យនោះ ព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងលទ្ធិជីវចលឥតមានបៀតបៀនគ្នាទេ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏ប៉ុន្តែ ចាប់តាំងពីសតវត្សទី ១០ មក គេឃើញ ព្រះរាជា និង មន្ត្រីធំៗកាន់សាសនាមិនសូវស្របគ្នាទេ ។ ប្រសិនបើព្រះរាជាកាន់ព្រហ្មញ្ញសាសនា មន្ត្រីធំៗច្រើនកាន់ព្រះពុទ្ធសាសនា ។ ហើយប្រសិនបើព្រះរាជាកាន់ព្រះពុទ្ធសាសនា មន្ត្រីធំៗកាន់ព្រហ្មញ្ញសាសនាវិញ ។

នៅពេលដែលអាណាចក្រខ្មែរស្គាល់នូវភាពរុងរឿង សាសនាទាំងពីរព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ចេះរួមរស់ជាមួយគ្នាប្រកបដោយសុខដុមរម្យនាអស់រយៈកាលដ៏យូរលង់ ។ លុះដល់សតវត្សទី ១៣ ពុទ្ធសាសនាមហាយានបានបាត់បង់ ។ ដល់សតវត្សទី ១៤ ព្រហ្មញ្ញសាសនាក៏បាត់បង់ទៀត ដោយសារពុទ្ធសាសនាហីនយានបានចូលមកដល់ ។ នៅពេលនោះ គេចាប់ឃើញថាប្រជាជនខ្មែរភាគច្រើនគោរពនូវព្រះពុទ្ធសាសនាហីនយាន តែមន្ត្រីធំៗនៅគោរពសាសនាព្រាហ្មណ៍ ។ សង្គ្រាមសាសនានៅសម័យក្រោយអង្គរ គឺជាមូលហេតុមួយដែលធ្វើឱ្យខ្មែរចុះខ្សោយ និងបាត់បង់នូវឯកភាពជាតិ ដែលបើកលទ្ធភាពឱ្យប្រទេសជិតខាងគេចូលមកឈ្លានពាន និងដណ្តើមយកអង្គរ តួយ៉ាងដូចជាទ័ពសៀមដែលចូលមកវាយអង្គរលើកដំបូង បានប្រើលេសថាមកជួយការពារព្រះពុទ្ធសាសនា ។

## ២.៣. ព្រះមហាក្សត្រខ្មែរដែលកសាងប្រាសាទព្រះវិហារ

ប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនឹងប្រាសាទព្រះវិហារ និងព្រះមហាក្សត្រខ្មែរជំនាន់នោះ ត្រូវបានចារទុកនៅលើសិលាចារឹក ដែលអ្នកប្រាជ្ញបារាំងឆ្នើមបំផុត ខាងសិក្សាសិលាចារឹកកម្ពុជា គឺលោក **ហ្សក សឺដេស** បានបកប្រែពីភាសាសំស្ក្រឹត និង ភាសាខ្មែរបុរាណ ហើយបោះពុម្ពផ្សាយនៅក្នុងកម្រងសៀវភៅរបស់លោកឈ្មោះថា «**សិលាចារឹកនៃកម្ពុជា**» ក្នុងភាគទី ៦ ។ សិលាចារឹកទាំងនេះត្រូវបានលោក **អាអ៊ីម៉ូនីញេ** និង លោក **ដឺឡាហ្សុងគែរ** រកឃើញនៅប្រាសាទព្រះវិហារ ឬ ឆ្លាក់លើទ្វារចូលតែម្តង ។ ដើម្បីងាយស្រួលក្នុងការសិក្សា គេបានចុះលេខបញ្ជីសារពើភ័ណ្ឌយ៉ាងត្រឹមត្រូវ ។ សិលាចារឹក «**ព្រះវិហារ**» មានលេខរៀងពី K380, K381, K382, K383 ។ សិលាចារឹកពី K380-K382 ពាក់ព័ន្ធនឹងព្រះបាទ **សូរ្យវរ្ម័នទី ១** ហើយសិលាចារឹក K83 ពាក់ព័ន្ធនឹងព្រះបាទ **សូរ្យវរ្ម័នទី ២** ។

ក្រៅពីនេះ មានសិលាចារឹកផ្សេងទៀត ដែលពាក់ព័ន្ធនឹងប្រាសាទ **ព្រះវិហារ** គឺ K542, K583 និង សិលាចារឹក **ស្តុកកក់ធំ** ។ លោក **ហ្សក សឺដេស** និង លោក **ឌុយម៉ុង** បានសរសេរអត្ថបទ «**សិលាចារឹកស្តុកកក់ធំ ត្លំសណ្តក និងព្រះវិហារ**» ដែល **សាលាបារាំងចុងបូព៌ា** បានបោះពុម្ពឡើងវិញក្នុងឆ្នាំ ១៩៩២ ក្នុងសៀវភៅ **ហ្សក សឺដេស-អត្ថបទស្តីពីប្រទេសខ្មែរ** ។ លោក **ក្លូដ ហ្សាក់** បានសរសេរអត្ថបទ «**ការសិក្សាស្តីពីសិលាចារឹកកម្ពុជា-សិលាចារឹកបាពួន**-K583» ដែលជាប្រភពមួយយ៉ាងសំខាន់នៃការសិក្សាដើមកំណើតរបស់ប្រាសាទ **ព្រះវិហារ** ។ ម៉្យាងវិញទៀត លោក **ហង់រី ប៉ារម៉ង់ទីយេ** បានសរសេរយ៉ាងលម្អិតពីប្រាសាទ **ព្រះវិហារ**


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅក្នុងស្នាដៃរបស់លោកដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៣៩ ក្រោមចំណងជើងថា «**សិល្បៈបុរាណខ្មែរ-វិមាននៅខាងជ្រែកភ្នំសាន្ត**» ព្រមទាំងមានគូរគំនូរទៀតផង ។

ឆ្លងតាមការសិក្សាសិលាចារឹកទាំងនេះ យើងឃើញថាព្រះមហាក្សត្រខ្មែរព្រះអង្គមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសាងសង់ប្រាសាទបុរាណនានា ដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធគំនិតខ្មែរ និង សាសនានាសម័យបុរាណ ។ យើងអាចរៀបចំជាបញ្ជីឈ្មោះនៃព្រះមហាក្សត្រដែលកសាង ឬ មានជាប់ពាក់ព័ន្ធនឹងប្រាសាទព្រះវិហារ ដូចតទៅ÷

ទី១- ព្រះបាទ **ជ័យវរ្ម័នទី២** (គ.ស.៨០២- គ.ស.៨៥០ បុត្ររបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ **ឥន្ទ្រាយុធ** បានយកសិវលិង្គ **ស្រីសិខរិស្វរ** ពី **លិង្គបុរី** (វត្តភូ) មកតម្កល់លើភ្នំព្រះវិហារ- សិលាចារឹកបាពួន-K583)

ទី២- ព្រះបាទ **យសោវរ្ម័នទី១** (គ.ស.៨៨៩- គ.ស.៩០០ តាមប្រភពសិលាចារឹក K382)

ទី៣- ព្រះបាទ **សូរ្យវរ្ម័នទី ១** (គ.ស.១០១០- គ.ស.១០៥០ តាមប្រភពសិលាចារឹក K380)

ទី៤- ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** (១០៥០-១០៦៦)

ទី៥- ព្រះបាទ **ហសិវរ្ម័នទី ៣** (១០៦៦-១០៧៩)

ទី៦- ព្រះបាទ **ជ័យវរ្ម័នទី ៦** (១០៨០-១១០៦)

ទី៧- ព្រះបាទ **ធរណីន្ទ្រវរ្ម័នទី ១** (១១០៧-១១១២) ដែលជាបងរបស់ព្រះបាទ **ជ័យវរ្ម័នទី ៦**

ទី៨- ព្រះបាទ **សូរ្យវរ្ម័នទី ២** (១១១៣-១១៤៩)

សិលាចារឹកលេខ K383 បញ្ជាក់ថា នៅឆ្នាំ ១១២១ ព្រះរាជគ្រូ **ទិវាករបណ្ឌិត** បានចាររៀបរាប់ពីប្រវត្តិសាស្ត្រនៃប្រាសាទព្រះវិហារ ដែលពាក់ព័ន្ធនឹងមហាក្សត្រ ៥ អង្គខាងលើដែលបានសោយរាជ្យជាបន្តបន្ទាប់ ។

ទន្ទឹមនឹងនេះ យើងក៏ដឹងដែរថា រាជបុរោហិត ឬ រាជគ្រូរបស់ព្រះមហាក្សត្រ ដែលជាព្រាហ្មណ៍ ឬ បណ្ឌិតដើរតួនាទីយ៉ាងសំខាន់នៅក្នុងសាសនា និង នយោបាយរបស់អាណាចក្រខ្មែរ ។ ព្រាហ្មណ៍ខ្លះមានដើមកំណើតពីប្រទេសឥណ្ឌា តែខ្លះទៀតគឺជាខ្មែរដែលបានសិក្សានៅប្រទេសឥណ្ឌា ហើយបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការពារនូវប្រពៃណីហិណ្ឌូ និង វប្បធម៌សំស្ក្រឹតនៅក្នុងអាណាចក្រខ្មែរ ។ ពួកព្រាហ្មណ៍ទាំងនេះក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងប្រទេស និងចូលរួមវិភាគទានក្នុងការអភិវឌ្ឍសិល្បៈខ្មែរ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការតែងតាំងរាជបុរោហិតមានលក្ខណៈតពូជពង្សវង្សត្រកូលតែម្តង ។ ឧទាហរណ៍ សមាជិកគ្រួសារព្រាហ្មណ៍ **សិវកៃវល្យ** ត្រូវបានព្រះបាទ **ជ័យវរ្ម័នទី ២** និង ព្រាហ្មណ៍ **ហិរណ្យទាម** បានតែងតាំងជា **រាជបុរោហិត** សម្រាប់ការប្រារព្ធធ្វើពិធីទេវរាជ ។ តាមប្រភពឯកសាររបស់លោក **ឡូរ៉ែនស៍ ប៉ាលម័រ ប្រ៊ីគ្គស៍** គ្រួសារ **ប្រាណាទតម្ម័ន** មានសិទ្ធិតពូជក្នុងការតែងតាំងជា **អាចារ្យព្រាហ្មណ៍** (*Hotar*) ។ គ្រួសារ **ហរិបុរ** មានសិទ្ធិតពូជជាព្រះសង្ឃសម្រាប់ពិធីបូជាសពជាដើម ។

ប្រាសាទ**ព្រះវិហារ**ត្រូវបានសាងសង់ឡើង ដោយមហាក្សត្រជាច្រើនអង្គ ។ ដូច្នេះហើយទើបយើងឃើញថាប្រាសាទ**ព្រះវិហារ**សាងសង់ឡើងតាមរចនាបថខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលសាងសង់ផ្សេងៗគ្នា ។

### ២.៣.១. ព្រះបាទជ័យវរ្ម័ន ទី ២ (គ.ស.៨០២-គ.ស.៨៥០)

សិលាចារឹក **បាពួន** (K583) ដែលបកប្រែដោយលោក **ត្លង់ ហ្សាក់** នៅក្នុងអត្ថបទរបស់លោក «**ការសិក្សាស្តីពីសិលាចារឹកកម្ពុជា-សិលាចារឹកបាពួន**-K583» រៀបរាប់ជាភាសាសំស្រ្កឹតពីព្រះបាទ **ជ័យវរ្ម័នទី ២** ដែលជា អាទិទេពនៃក្សត្រលើគ្រប់ទ្វីបបានគ្រប់គ្រងប្រទេសប្រកបដោយទសពិធរាជធម៌ និងការពារប្រជាជនរបស់ព្រះអង្គ ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម **ស្រី ឥន្ទ្រាយុទ្ធ** មានថាមពលខ្លាំងក្លាតាំងពីវ័យក្មេង ដោយច្បាំងឈ្នះស្តេចចម្ប៉ា ។ ព្រះអង្គបានយាងទៅធ្វើធម៌នៅ **លិង្គបុរី** (*វត្តភូ*) ។ តាមបញ្ជារបស់ព្រះសិវៈ ព្រះអង្គបានកសាងលិង្គមួយពីបំណែកលិង្គធំមួយទៀតឈ្មោះ **លិង្គនិសកល** ហើយព្រះអង្គបានតម្កល់លិង្គនេះនៅវត្តសន្ទ ដោយប្រគេនថ្វាយព្រះចៅ **លិង្គបុរី** នូវទេវរូប **ស្រី សិខរិស្វរៈ** ហើយបន្ទាប់មកព្រះអង្គបានយកលិង្គនេះមកទុកនៅប្រាសាទព្រះវិហារ ។ សិលាចារឹកបាពួនបានបញ្ជាក់យ៉ាងច្បាស់ ពីដើមកំណើតនៃទីសក្ការបូជាចំពោះ **សិខរិស្វរៈ** តាំងពីជំនាន់ព្រះបាទ **ជ័យវរ្ម័នទី ២** មកម្លេះ ។ ដូច្នេះ យើងអាចសន្និដ្ឋានបានពីវត្តមាននៃប្រាសាទ**ព្រះវិហារ** ដែលអាចមិនទាន់ជាសំណង់ថ្មនៅឡើយ នៅក្នុងរជ្ជកាលព្រះបាទ **ជ័យវរ្ម័នទី ២** ។

### ២.៣.២. ព្រះបាទយសោវរ្ម័ន ទី ១ (គ.ស.៨៨៩-គ.ស.៩០០)

ព្រះបាទ **យសោវរ្ម័នទី១** គឺជាបុត្ររបស់ព្រះបាទ **ឥន្ទ្រវរ្ម័នទី ១** ដែលជាស្តេចកសាងប្រាសាទ **បាគង** ដែលជាប្រាសាទភ្នំទី ១ សាងពីថ្មភក់ ។ លុះបានទទួលរាជសម្បត្តិភ្លាម ព្រះអង្គបានកសាងនៅគ្រប់ខេត្តនូវអាស្រម ចំនួន ១០០ (យសោធរាស្រម) ។ នៅគ.ស. ៨៩៣ ព្រះបាទ **យសោវរ្ម័នទី ១** បានសាងសង់នៅកណ្តាលបារាយណ៍ **ឥន្ទ្រតដាក** នូវប្រាសាទ **លលៃ** ដើម្បីឧទ្ទិសចំពោះព្រះមាតាបិតា និងជីដូនជីតាខាងព្រះមាតារបស់ព្រះអង្គព្រះនាម **ឥន្ទ្រទេវី** ។ ព្រះអង្គបានកសាងក្រុង **យសោធរបុរ** ដែលមានភ្នំបាខែងនៅចំកណ្តាល ហើយទ្រង់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាននាំយកទេវរាជពី **ហរិហរាល័យ** ទៅតម្កល់នៅក្រុងថ្មីនេះនៅក្នុងឆ្នាំ ៨៩៣ ។

ព្រះអង្គបានកសាងប្រាសាទពីរដើម្បីឧទ្ទិសចំពោះព្រះឥសូរ គឺ បន្តសាងសង់ប្រាសាទ **សិខរិស្វរៈ** ដែលជាប្រាសាទ **ព្រះវិហារ** និងប្រាសាទ **តត្រៃស្វរៈ** នៅ **សិវបុរៈ** (ភ្នំសណ្តក) ។ ចំណែកឯនៅភ្នំបូក និង ភ្នំក្រោម ព្រះអង្គបានសាងប្រាសាទមានប្រាង្គ ៣ សម្រាប់ឧទ្ទិសចំពោះត្រីមូិតិ (ព្រះព្រហ្ម- ព្រះវិស្ណុ- ព្រះឥសូរ) ។ សិលាចារឹកភាសាសំស្ក្រឹត K382 ដែលប្រភពខ្លះហៅថាសិលាចារឹក **សិវសត្តិ** (Çivaçakti) ដោយយកតាមឈ្មោះអ្នកនិពន្ធនៃសិលាចារឹកបានលើកឡើងពីបញ្ជារបស់ព្រះសិវៈ ដើម្បីតម្កល់ទេវរូបនៅ **យសោធរគិរី** (ភ្នំបាក់ខែង) គឺនៅក្នុងរជ្ជកាលព្រះបាទ **យសោវរ្ម័នទី១** ។ សិលាចារឹកនេះក៏បានបញ្ជាក់ពីវត្តមាននៃ **សិខរិស្វរៈ** ដែលមានន័យថាមានប្រាសាទ **ព្រះវិហារ** ក្នុងរជ្ជកាលព្រះបាទ **យសោវរ្ម័នទី១**។

ទឹកដីខ្មែរនៅពេលនោះ ខាងលិចទល់នឹងដែន **សុវណ្ណភូមិ្មរាតាស** (ប្រទេសភូមា) ខាងត្បូងទល់នឹងសមុទ្រខាងកើតទល់នឹងចម្ប៉ា ខាងជើងទល់នឹងប្រទេសប្រទេសចិន ។

### ២.៣.៣. ព្រះបាទសូរ្យវរ្ម័ន ទី ១ (គ.ស.១០១០-គ.ស.១០៥០)

ក្រោយពីព្រះបាទ **ជ័យវរ្ម័នទី ៥** សោយទិវង្គតទៅ ក្មួយរបស់ព្រះអង្គគឺព្រះបាទ **ឧទយាទិត្យវរ្ម័នទី ១** បានឡើងសោយរាជ្យក្នុង គ.ស. ១០០១ ។ នៅពេលនោះ សង្គ្រាមក្នុងស្រុកបានកើតមានឡើងនៅក្នុងអាណាចក្រខ្មែរ ដោយសារចម្បាំងដណ្តើមរាជសម្បត្តិ ។ យ៉ាងហោចណាស់ ក៏ប្រហែលជាមានព្រះរាជាបីព្រះអង្គដែលបានចូលរួមក្នុងការដណ្តើមរាជសម្បត្តិនេះ គឺ ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ១** ព្រះបាទ **ជ័យវីរវរ្ម័ន** និង ព្រះបាទ **សូរ្យវរ្ម័នទី ១** ។ អ្នកប្រវត្តិសាស្ត្របានផ្តល់នូវពតិមានចម្រូងចម្រាស់គ្នាពីដើមកំណើតរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** ។ សិលាចារឹកបានបង្ហាញថាព្រះអង្គមានព្រះគោរម្យងារជាច្រើនខុសៗគ្នា ដោយសារតែប្រហែលជាសិលាចារឹកទាំងនោះភាគច្រើនចារឹកដោយមន្ត្រីដែលគាំទ្រព្រះអង្គ ។ ម៉្យាងវិញទៀត ប្រហែលជាគោរម្យងារទាំងនេះចារឹកឡើងមុនពេលព្រះអង្គឈ្នះសង្គ្រាម និងមុនពេលព្រះអង្គឡើងគ្រងរាជ្យជាស្តេចកំពូល គឺមិនមែនកំណត់ហេតុពីព្រះអង្គផ្ទាល់ទេ ។ សិលាចារឹក K153 នៅក្នុង គ.ស. ១០០១ ព្រះអង្គមានព្រះគោរម្យងារជា ***ព្រះករុណា ប្រាសាទ ត ធូលី ព្រះបាទ កម្រតេង អញ ស្រី សូរ្យបរមទេព*** ។ សិលាចារឹក K125 នៅជិតក្រចេះបញ្ជាក់ថាព្រះអង្គមានព្រះគោរម្យងារជា ***ធូលី វ្រះបាទធូលី ជើង វ្រះ កម្រតេង អញ ត បរមវិត្រ*** តែនៅក្នុងឃ្លាមួយទៀតសិលាចារឹកនេះហៅព្រះអង្គថា ***កម្រតេង កំតួន អញ*** ។ សិលាចារឹក K292 បញ្ជាក់ថាព្រះអង្គមានព្រះគោរម្យងារជា ***វ្រះបាទ កម្រតេង អញ កំតួន អញ ស្រី សូរ្យវម៌ទេវត សកលលោ្វយ វ្រះ ធម៌រាជ្យ*** (**មួន សក្ខណារី**-២០០៦ ទំព័រ ៣) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិលាចារឹក **ស្តុកកក់ធំ** បានបញ្ជាក់ថានៅក្នុង គ.ស. ១០០២ ព្រះបាទ **សូរ្យវរ្ម័នទី ១** ដែលមានទីតាំងនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា ប្រហែលជានៅម៉ុងដងទន្លេមេណាមផ្នែកកណ្តាល បានចាប់ផ្តើមប្រតិបត្តិការសឹកប្រឆាំងនឹងគូបដិបក្សរបស់ព្រះអង្គ ។ នៅក្នុង គ.ស. ១០០៤ ព្រះអង្គបានកាន់កាប់នូវទឹកដីផ្នែកខាងជើងនៃភ្នំដងរែក ។ នៅពេលនោះ ព្រះបាទ **ជ័យវីរវរ្ម័ន** នៅសោយរាជ្យនៅអង្គរនៅឡើយ ។ បន្ទាប់ពីបានពង្រឹងមូលដ្ឋាននៅទីនោះហើយ នៅចន្លោះឆ្នាំ ១០០៥ និង ១០០៧ ព្រះបាទ **សូរ្យវរ្ម័ន** បានលើកទ័ពវាយចូលវាយអង្គរ ហើយបានទទួលជោគជ័យជាស្ថាពរនៅឆ្នាំ ១០១០ ។ បន្ទាប់មកព្រះអង្គបានខិតខំពង្រឹងសណ្តាប់ធ្នាប់សង្គម និង ស្តារព្រះរាជាណាចក្រ ពង្រឹងក្បាលម៉ាស៊ីនរដ្ឋបាល និងកសាងប្រាសាទឡើងវិញ ដើម្បីឱ្យប្រជាពលរដ្ឋអាចរស់នៅក្នុងសុខសន្តិភាព ។ ព្រះបាទ **សូរ្យវរ្ម័នទី ១** បានសោយរាជ្យរហូតដល់ ឆ្នាំ ១០៥០ ។ ព្រះអង្គបានពង្រីកទឹកដីនៃអាណាចក្រខ្មែរដល់ត្រើយខាងស្តាំនៃទន្លេមេណាំ និង បន្ទាប់មកដល់ម៉ាឡេស៊ីភាគកណ្តាល ។

ប្រវត្តិវិទូមានទស្សនខុសៗគ្នាពីជំនឿសាសនារបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** ។ លោកស្រី **ហ្ស៊ីត្វ** និង លោក **ស៊ីដែស** ជឿជាក់ថា ព្រះអង្គជាព្រះរាជាទី១ ដែលកាន់ព្រះពុទ្ធសាសនាមហាយាន ហើយមរណនាមរបស់ព្រះអង្គ **និវានបទ** គឺជាសក្ខីភាពនៃជំនឿលើព្រះពុទ្ធសាសនារបស់ព្រះអង្គ ។ ក៏ប៉ុន្តែ នៅក្នុងសៀវភៅចុងក្រោយដែលមានចំណងជើងថា «**ប្រវត្តិសាស្ត្រអង្គរ**» លោកស្រី **ហ្ស៊ីត្វ** បានលើកឡើងនូវទស្សនមួយដែលថា ព្រះបាទ **សូរ្យវរ្ម័នទី ១** អាចជាស្តេចដែលគោរពព្រហ្មញ្ញសាសនា ដោយសារតែប្រាសាទដែលត្រូវបានសាងសង់នៅក្នុងរាជ្យរបស់ព្រះអង្គ គឺសុទ្ធសឹងតែជាប្រាសាទសិវនិយមទាំងអស់ ។ ម្យ៉ាងវិញទៀត ប្រវត្តិវិទូបារាំង លោក **ហ្វីឡូហ្សា** បានអះអាងថា **និវានបទ** ក៏ជាមរណនាមនៃស្តេចដែលគោរពបូជាព្រះសិវផងដែរ ។

នៅដែលពេលស្រុកកើតសង្គ្រាមក្នុងស្រុក មន្ត្រីជាន់ខ្ពស់ខ្លះបានគាំទ្រដល់ពួកបះបោរ ដើម្បីរក្សានូវទ្រព្យសម្បត្តិរបស់ខ្លួន ។ ដូច្នេះហើយ អាទិភាពមួយទៀតរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** គឺធានាឱ្យបាននូវភាពស្មោះត្រង់របស់មន្ត្រីជាន់ខ្ពស់ដែលបម្រើព្រះអង្គ ។ នៅលើសិលាចារឹកនៃគោបុរៈព្រះបរមរាជវាំង ព្រះអង្គបានចារឹកនូវសម្បថដែលមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវធ្វើសច្ចាប្រណិធាន ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់ពួកគេចំពោះព្រះអង្គ ។

នៅក្នុងរាជ្យរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** ព្រាហ្មណ៍ **សទាសិវ** ត្រូវបានតែងតាំងជា **ជយេន្ទ្របណ្ឌិត** និងបានរៀបអភិសេកជាមួយប្អូនស្រីរបស់ព្រះមហាក្សត្រីយ៍ **វីរលក្ស្មី** ដែលជាប្អូនថ្លៃរបស់ព្រះអង្គ ។ បន្ទាប់មក **សទាសិវ** ត្រូវបានព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** តែងតាំងជារាជគ្រូ និងមានឋានៈជា **ធូលីជើង** ។

ព្រះបាទ **សូរ្យវរ្ម័នទី ១** មិនបានសាងសង់អ្វីសំខាន់នៅអង្គរទេ តែព្រះអង្គក៏មិនបានបញ្ឈប់ការសាងសង់ដែរ ដោយបានស្ថាបនាបង្ហើយប្រាសាទវិមានអាកាស និងគោបុរៈនៃរាជវាំង ។ ព្រះអង្គបានបញ្ជាឱ្យមន្ត្រីជាន់ខ្ពស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង់បង្ហើយប្រាសាទតាកែវ ។

អាទិភាពរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** គឺការផ្សះផ្សាជាតិ និងការពង្រឹងសន្តិភាពនៅក្នុងអាណាចក្រខ្មែរ បន្ទាប់ពីសង្គ្រាមក្នុងស្រុកអស់រយៈពេល ៩ ឆ្នាំមក ។ ដើម្បីពង្រឹងអំណាចរបស់ព្រះរាជានៅតាមខេត្ត ព្រះអង្គបានផ្តោតជាសំខាន់លើការសាងសង់ប្រាសាទបុរាណនៅក្រៅអង្គរ ។ ដូច្នេះហើយ ទើបព្រះអង្គបានបញ្ជាឱ្យព្រាហ្មណ៍ និងមន្ត្រីជាន់ខ្ពស់សាងប្រាសាទភ្នំជីសូរ **ប្រាសាទព្រះវិហារ** និង **ព្រះខ័ន** កំពង់ស្វាយ ។

សិលាចារឹកលេខ K381 ដែលឆ្លាក់លើសរសក្លោងទ្វារខាងត្បូងនៃថែវខាងត្បូង ដែលស្ថិតនៅខាងកើតគោបុរៈទី៣ បានបញ្ជាក់ពីការឡើងសោយរាជ្យរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** នៅក្នុង គ. ស. ១០០២ ។

សិលាចារឹក K380 ដែលឆ្លាក់លើសរសក្លោងទ្វារខាងត្បូងនៃគោបុរៈទី ២ បានបញ្ជាក់ថា នៅក្នុងរជ្ជកាលរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** មានការគោរពយ៉ាងខ្លាំងក្លាចំពោះ **លទ្ធិសិវៈនិយម** នៅលើកំពូលភ្នំព្រះវិហារ ។ ព្រះអង្គបានបញ្ជាឱ្យតម្កល់ព្រះសិវលិង្គឈ្មោះ **សូរ្យវរមេស្វរ** តំបូងនៅ **ជ័យក្សេត្រ** (បាសិត) ហើយបន្ទាប់មក នៅក្នុង គ. ស. ១០១៨ ព្រះអង្គបានបញ្ជាឱ្យយកព្រះសិវលិង្គ **សូរ្យវរមេស្វរ** នេះទៅតម្កល់នៅទីសក្ការៈបីទៀត គឺ **សិខរិស្វរ** (ព្រះវិហារ) **ឥសាន្តទិត** (Içantirtha) និង **សូរ្យាទ្រ** (ភ្នំជីសូរ) ។ លិង្គ **សូរ្យវរមេស្វរ** នេះត្រូវបានគេដម្កល់នៅក្នុងគោបុរៈទី២ នៃប្រាសាទ **ព្រះវិហារ** ។

សិលាចារឹកនេះបានរំលឹកថាទេវរូប **ភទ្រេស្វរ** (Bhadreçvara) ត្រូវបានយកមកពី **លិង្គបុរ** (វត្តភូ) ដើម្បីតម្កល់នៅភ្នំព្រះវិហារ ។ គឺនៅក្នុងរជ្ជកាលរបស់ព្រះបាទ **សូរ្យវរ្ម័នទី ១** ហើយ ដែលមានការសាងសង់នូវប្រាសាទជាច្រើនធ្វើពីថ្មភក់ នៅតាមគោបុរៈផ្សេងៗនៃប្រាសាទ **ព្រះវិហារ** ។ ប្រាង្គកណ្តាល គឺជានិវាសនដ្ឋាននៃមហាក្សត្ររបស់អាទិទេព ដែលតំណាងដោយព្រះសិវលិង្គ ។

សិលាចារឹកលេខ K381 បានបញ្ជាក់ថា ព្រះបាទ **សូរ្យវរ្ម័នទី ១** បានប្រទានដល់ឥសីឈ្មោះ **តាបសវិន្ទ្រាបណ្ឌិត** (Devatapasvindrapandita) នូវក្លស់មាសមួយ និង វិរស្រេម (រាជរាំង) ដើម្បីតបស្នងសងគុណក្នុងការថែរក្សាលិង្គ **សិខរិស្វរ** ។ ដូច្នេះហើយ ទើបឥសីនេះបានដាក់ឈ្មោះអាស្រមនេះថាជា **តាបសវិន្ទ្រាបណ្ឌិតអាស្រម** ។ សិលាចារឹកនេះបានបញ្ជាក់ថា **តាបសវិន្ទ្រាបណ្ឌិត** មានសិទ្ធិផ្តាច់មុខលើខ្ញុំបម្រើ និងរបស់សព្វសារពើនៅក្នុងប្រាសាទ **ព្រះវិហារ** ។ សិលាចារឹក K381 បានពិពណ៌នាថា នៅក្នុង គ. ស. ១០២៦ **តាបសវិន្ទ្រាបណ្ឌិត** បានធ្វើអំណោយដល់ **ស្រី សិខរិស្វរ** នៅពេលបុណ្យចូលឆ្នាំ នូវគ្រឿងអលង្ការ វត្ថុសម្រាប់រៀបចំពិធីផ្សេងៗ គោ ក្របី ដំរី ភូមិ ដីធ្លី និងខ្ញុំបម្រើជាដើម ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាសាទព្រះវិហារត្រូវបានពង្រីកជាបន្តបន្ទាប់ ។ សិលាចារឹកលេខ K380 បានបញ្ជាក់ថា នៅក្នុង គ.ស. ១០៣៧ ព្រះបាទ **សូរ្យវរ្ម័នទី ១** បានផ្តល់អំណោយដល់ព្រាហ្មណ៍ **សុកាមិរ** ដែលមានដើមកំណើតនៅ **គុរុក្សេត្រ** ស្រុក **ទិបជ** ហើយផ្លាស់ឈ្មោះស្រុកនេះទៅជា **គុរុក្សេត្រ** វិញ ដើម្បីតបស្នងសងគុណចំពោះការគ្រប់គ្រងប្រាសាទព្រះវិហារ ។ ព្រាហ្មណ៍ **សុកាមិរ** ដែលជាអ្នកកត់ត្រាប្រវត្តិប្រាសាទព្រះវិហារ និង អ្នកកាន់បណ្ណាសារជាតិ ។ ព្រាហ្មណ៍ **សុកាមិរ** បានពង្រីកប្រាសាទ **ព្រះវិហារ** ឱ្យកាន់តែធំជាងមុនទៅទៀត ។ អត្ថបទជាភាសាខ្មែរបុរាណបានលើកឡើងថា មន្ត្រីជាន់ខ្ពស់បានទទួលពាក្យសម្បថស្វាមីភក្តិចំពោះព្រះបាទ **សូរ្យវរ្ម័នទី ១** នៅក្នុងប្រាសាទ **ព្រះវិហារ** ជាពិសេសស្វាមីភក្តិចំពោះអាទិទេព **កម្រតេងស្វេរ** នៃ **លិង្គប៉ុរី** ដែលបានមកចាប់ជាតិជាថ្មីជា **សិខរិស្វេរ** ។ ពាក្យសម្បថរួមមាន កាតព្វកិច្ចក្នុងការថែរក្សា ជួសជុល និង ការពារប្រាសាទ **ព្រះវិហារ** ដើម្បីទប់ទល់នឹងខ្មាំងសត្រូវឈ្លានពាន និង ពួកបះបោរ ។

សិលាចារឹកភាសាសំស្រ្កឹត K382 បានបញ្ជាក់ ពីព្រះរាជបញ្ជារបស់ព្រះសិវៈ ឱ្យយកទេវរូបទៅតម្កល់នៅ **ស្រី សិខរិស្វេរ** ។ នៅក្នុងគ្រឹស្តសករាជ ១០៤៧ **តាបស ទិវាករបណ្ឌិត** បានបង្គំទូលថ្វាយព្រះបាទ **សូរ្យវរ្ម័នទី ១** នូវបញ្ជារបស់ព្រះសិវៈនេះ ។

សិលាចារឹកលេខ K542 ដែលសរសេរដោយ **តាបសវិស្វេរបណ្ឌិត** (Tapasvisvara pandita) នៅលើប្រាសាទឃ្លាំងខាងជើង បានបញ្ជាក់ថាលោកបានកសាងសំណង់សាសនា ហើយបានលើកថ្វាយដល់ព្រះបាទ **សូរ្យវរ្ម័នទី ១** ។ ព្រះអង្គក៏បានប្រទានវត្ថុមានតម្លៃដល់គាត់វិញ ។ តាបសនេះបានគូរប្លង់ចំនួនពីរគឺ ÷

ទីមួយ- ឡូត៍ដីទី១ ថ្វាយដល់ទេពឈ្មោះ **សិខរិស្វេរ** (ព្រះវិហារនេះឯង) ។

ទីពីរ- ឡូត៍ដីទី២ បង្ហាញពីខណ្ឌសីមានៃឡូត៍ដីទាំងពីរនេះ ។ ប្លង់ដីនេះមានទម្រង់ដូចផែនទីសព្វថ្ងៃដោយទិសខាងជើងនៅខាងលើ ឯទិសខាងកើតនៅខាងស្តាំដៃ ។ ប្លង់ដីនេះបង្ហាញពីខណ្ឌសីមារវាង **សិខរិស្វេរ** និង ប្រាសាទ **សិវបដបស្ចិម** (Sivapadapascima) (ប្រាសាទតាមន្តធំ) ។

## ២.៣.៤. ព្រះបាទជ័យវរ្ម័ន ទី ៦ (គ.ស.១០៨០-គ.ស.១១០៧)

តាមឯកសាររបស់លោកសាស្ត្រាចារ្យ **ត្រឹង ងារ** បានឱ្យដឹងថា ព្រះបាទជ័យវរ្ម័នទី ៦ ដែលជាបុត្រស្តេច **ហិរណ្យវរ្ម័ន** និង ព្រះនាង **ហិរណ្យលក្ស្មី** បានបន្តកសាងប្រាសាទព្រះវិហារ និង ប្រាសាទដ៏ទៃទៀត ដូចជាប្រាសាទនៅភ្នំសណ្តក នៅវត្តភូ និងនៅភិម៉ៃ (ខាងពុទ្ធសាសនា) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣.៥. ព្រះបាទសូរ្យវរ្ម័ន ទី ២ (គ.ស.១១១២-គ.ស. ១១៥២)

ព្រះបាទ **សូរ្យវរ្ម័នទី ២** បានឡើងសោយរាជ្យ ដោយបង្រួបបង្រួមអាណាចក្រពីរ ÷ ទីមួយ ជារបស់ **ធរណីន្ទ្រវរ្ម័នទី១** និង ទីពីរ របស់ **នព្វបតីន្ទ្រវរ្ម័ន** ដែលបានសោយរាជ្យនៅអង្គរតាំងតែពី ១០៨០ មកម្ល៉េះ ។ ព្រះបាទ **សូរ្យវរ្ម័នទី ២** ត្រូវបានរៀបចំអភិសេក ដោយព្រាហ្មណ៍ទិវាករ នៅឆ្នាំ ១១១៣ ។ ព្រះបាទ **សូរ្យវរ្ម័នទី ២** បានបន្តការស្ថាបនា **ប្រាសាទព្រះវិហារ** ប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសណ្ដក និង ប្រាសាទវត្តភូ ។ ចំណែកសំណង់ថ្មី ព្រះអង្គបានកសាងប្រាសាទព្រះពិធូរ ប្រាសាទចៅសាយទេវតា ប្រាសាទធម្មានន្ទ ប្រាសាទបន្ទាយសំរែ និង **ប្រាសាទអង្គរវត្ត** ដែលជាស្នាដៃឯកនៃស្ថាបត្យកម្មខ្មែរ សម្រាប់តម្កល់ព្រះវិស្ណុបដិមា ដែលមានមរណនាមថា **បរមវិស្ណុលោក** ។ នេះជាលើកដំបូងហើយ ដែលសាសនាព្រាហ្មណ៍គណៈវិស្ណុត្រូវបានលើកតម្កើងជាសាសនារដ្ឋ ហើយបដិមាករតំណាងព្រះរាជាលែងជាសិវលិង្គទៀតហើយ តែជាវិស្ណុបដិមាវិញ ។

ព្រាហ្មណ៍ **ទេវករ** ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសាសនានៅក្នុងសតវត្សទី ១១ និង ផ្នែកទី ១ នៃសតវត្សទី ១២ ។ ព្រាហ្មណ៍ **ទេវករ** បានម្រើព្រះមហាក្សត្រខ្មែរចំនួនប្រាំអង្គ គឺព្រះបាទព្រះបាទ **ឧទយាទិត្យ-វរ្ម័នទី ២** ព្រះបាទ **ហសិវរ្ម័នទី ៣** ព្រះបាទ **ជ័យវរ្ម័នទី ៦** ព្រះបាទ **សូរ្យវរ្ម័នទី ២** ។ សិលាចារឹកលេខ K383 ដែលចម្លងទាំងស្រុងពីសិលាចារឹក **ភ្នំសណ្ដក** បញ្ជាក់ថា **ទិវាករបណ្ឌិត** (Divakara pandita) បានដឹកនាំការធ្វើគម្រោងដ៏ច្រើននៅប្រាសាទ **ព្រះវិហារ** ។ នៅ គ.ស. ១១១៩ ព្រះបាទ **សូរ្យវរ្ម័នទី ២** បានត្រាស់បង្គាប់ឱ្យយកសិលាចារឹកនេះមកតម្កល់ទុកនៅប្រាសាទ **ព្រះវិហារ** ។

សិលាចារឹក **ភ្នំសណ្ដក** (K194) ដែលបកស្រាយដោយលោក **សឺដែស** បានរៀបរាប់ថា÷ នៅក្នុងគ្រឹស្តសករាជ ១១១៩ ព្រះបាទ **សូរ្យវរ្ម័នទី ២** បានបញ្ជាឱ្យគេកត់ត្រានៅលើសិលាចារឹកនេះ នូវប្រវត្តិរូបរបស់ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ដែលមានគោរម្យងារជា **ឥគវត្តិបត្តិ កម្រតេង អញ ឋា ភ្ន** ដែលព្រះបាទ **ជ័យវរ្ម័នទី៦** បានផ្ដល់ជូននៅពេលព្រះអង្គឡើងសោយរាជ្យ តែត្រូវបានប្ដូរនឹងគោរម្យងារមួយទៀតដែលខ្ពស់ ជាង គឺ **ធូលីជើង កម្រតេង អញ** ។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** មានដើមកំណើតនៅប្រទេស Vnur Dnan ក្នុងស្រុក Sadya ដែលអាចជារដ្ឋតូចមួយនៃអាណាចក្រខ្មែរ ។ ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** បានបញ្ជាឱ្យព្រាហ្មណ៍ **ទិវាករបណ្ឌិត** កសាងប្រាសាទ **បាពួន** ដើម្បីតម្កល់ព្រះសិវៈលិង្គមាស នៅចំកណ្ដាលរាជធានីរបស់ព្រះអង្គ ។ ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** បានសោយរាជ្យពីឆ្នាំ ១០៥០ ដល់ ឆ្នាំ ១០៦០ តែពិធីតម្កល់ព្រះសិវៈលិង្គមាសត្រូវបានប្រារព្ធនៅចុងរាជ្យរបស់


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ព្រះអង្គ ប្រហែលជានៅក្នុងឆ្នាំ ១០៦០ ឬ ក្រោយនេះបន្តិច ។

នៅក្នុងរាជ្យរបស់ព្រះបាទ **ហរ្សវរ្ម័នទី ៣** ដែលជាព្រះរាមរបស់ព្រះបាទ **ឧទយាទិត្យវរ្ម័នទី ២** ព្រាហ្មណ៍ **ទិវាករបណ្ឌិត** បានបំពេញតួនាទីជា ***អាចារ្យ*** (Acāryapradhāna) នៅប្រាសាទ **ព្រះវិហារ** ។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ត្រូវបានព្រះបាទ **ជ័យវរ្ម័នទី ៦** ជ្រើសរើសជាព្រះគ្រូ ដើម្បីអភិសេកព្រះអង្គ។ ព្រាហ្មណ៍ **ទិវាករបណ្ឌិត** បានផ្សាភ្ជាប់ជាមួយសន្តិវង្សថ្មីនេះ ហើយបានក្លាយជាទីប្រឹក្សាក្នុងរយៈពេល ៤០ ឆ្នាំ ។ ក្រៅពីតួនាទីជា ព្រះគ្រូ ព្រះបាទ **ជ័យវរ្ម័នទី ៦** បានផ្តល់គោរមងារដល់ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ជា **ឥតទេវត្តិបត្តិ កម្រតេង អញ ជា គ្រូ ស្រី ទិវាករបណ្ឌិត** ។ ព្រាហ្មណ៍នេះមានតួនាទីជាអ្នកចែកអំណោយដល់ប្រាសាទជាទីសក្ការនានា ដើម្បីទ្រទ្រង់ និងជួសជុលប្រាសាទទាំងនេះ និងបំពេញការងារសាងសង់នានាខាងផ្នែកសាសនា ។ បន្ទាប់ពីព្រះបាទ **ជ័យវរ្ម័នទី ៦** បានសោយទិវង្គត ព្រះរាមច្បងរបស់ព្រះអង្គ គឺព្រះបាទ **ធរណីន្ទ្រវរ្ម័នទី ១** បានឡើងសោយរាជ្យ ។ ព្រះបាទ **ធរណីន្ទ្រវរ្ម័នទី ១** បានបញ្ជាឱ្យព្រាហ្មណ៍ **ទិវាករបណ្ឌិត** ចែកអំណោយនៅតាមបណ្តាប្រាសាទនានា ។ នៅក្នុងឆ្នាំ ១១១៣ ព្រះអង្គត្រូវចៅមីងព្រះអង្គធ្វើគត់ ដើម្បីដណ្តើមរាជ្យ ។

ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ត្រូវបានគេជ្រើសរើសដើម្បីអភិសេកព្រះមហាក្សត្រថ្មី ដោយយកព្រះបរមនាមថាព្រះបាទ **សូរ្យវរ្ម័នទី ២** ។ សិលាចារឹកលេខ K383 បានរៀបរាប់ថា **ទិវាករបណ្ឌិត** បានជីកស្រះ និងជីកប្រឡាយទឹក ដោយចំណាយទ្រព្យធនរបស់លោកផ្ទាល់ និងបានធ្វើអំណោយជាវត្ថុមានតម្លៃទៅប្រាសាទ **ព្រះវិហារ** តាមព្រះរាជបញ្ជារបស់ព្រះបាទ **សូរ្យវរ្ម័នទី ២** ។

សរុបមក ប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើងជាបីដំណាក់កាល៖ ដំណាក់កាលទី១ ជំនាន់ព្រះអង្គម្ចាស់ **ឥន្ទ្រាយុទ្ធ** និងព្រះបាទ **យសោវរ្ម័នទី១** ដំណាក់កាលទី២ ក្នុងរជ្ជកាលព្រះបាទ **សូរ្យវរ្ម័នទី ១** នៅពេលដែលប្រាសាទត្រូវបានស្ថាបនាឡើងជាថ្ម និង ដំណាក់កាលទី ៣ ក្នុងរជ្ជកាល **សូរ្យវរ្ម័នទី ២** ។ ការខិតខំប្រឹងប្រែងរបស់ព្រះមហាក្សត្រខ្មែរជាច្រើនជំនាន់ និង ការសាងសង់របស់ព្រះរាជគ្រូ ដែលមានចំណេះដឹង និងចំណេះធ្វើយ៉ាងជ្រៅជ្រះនេះបានធ្វើឱ្យប្រាសាទព្រះវិហារមានតម្លៃជាសកលលេចធ្លោ ដែលឆ្លុះបញ្ចាំងពីភាពពេញលេញរបស់ប្រាសាទ សភាពដើមរបស់ប្រាសាទ ស្នាដៃឯកកើតចេញពីទេពកោសល្យឆ្នៃប្រឌិតរបស់មនុស្សខ្មែរ តម្លៃស្ថាបត្យកម្មរបស់ប្រាសាទ និង ការតុបតែងលម្អ ដូចជាចម្លាក់ និងទេវកថាដែលពាក់ព័ន្ធ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៣

# ប្រាសាទព្រះវិហារ

## ៣.១. ការទស្សនាប្រាសាទព្រះវិហារ

ដើម្បីទៅទស្សនាប្រាសាទព្រះវិហារ យើងអាចធ្វើដំណើរពីភ្នំពេញទៅដល់ស្គួន តាមផ្លូវជាតិលេខ ៦ ដែលមានប្រវែង ៧៥ គម. បន្ទាប់មកបត់ទៅទីរួមខេត្តកំពង់ធំ (១៦៨ គម) ។ ដើម្បីទៅប្រាសាទព្រះវិហារ យើងអាចធ្វើដំណើរតាមផ្លូវពីរ ÷

**ផ្លូវទីមួយ**- ធ្វើដំណើរតាមផ្លូវជាតិលេខ ៦២ ពីទីរួមខេត្តកំពង់ធំ ទៅទីរួមខេត្តព្រះវិហារ **ត្បែងមានជ័យ** (ចម្ងាយ ១៥៧ គម) ។ ពីភ្នំពេញដល់ត្បែងមានជ័យត្រូវធ្វើដំណើរអស់រយៈពេល ៦ ម៉ោង ។ យើងអាចសម្រាកមួយយប់នៅត្បែងមានជ័យ ។ បន្ទាប់មកនៅពេលព្រឹកព្រលឹម ត្រូវធ្វើដំណើរពី **ត្បែងមានជ័យ** ទៅដល់ **ស្រាអែម** ត្រូវធ្វើដំណើរអស់ពីរម៉ោងទៀត ។ ហើយពី **ស្រាអែម** ទៅដល់ប្រាសាទព្រះវិហារត្រូវចំណាយ ពេលអស់ ៤៥ នាទី ។

**ផ្លូវទីពីរ**- បន្តធ្វើដំណើរតាមផ្លូវជាតិលេខ ៦ ពីទីរួមខេត្តកំពង់ធំ ទៅទីរួមខេត្ត **សៀមរាប** (ចម្ងាយ ១៤៦ គម) ត្រូវចំណាយពេលអស់ ២ ម៉ោង ។ ពីសៀមរាបត្រូវធ្វើដំណើរទីរួមស្រុក **អន្លង់វែង** ត្រូវចំណាយពេលអស់ ២ ម៉ោង ។ យើងត្រូវសម្រាកពេលយប់នៅ **អន្លង់វែង** ។ នៅពេលព្រឹកត្រូវចេញដំណើរពី **អន្លង់វែង** ទៅដល់ **ស្រាអែម** ត្រូវចំណាយពេលអស់ជិត ២ ម៉ោង ។ ហើយពី **ស្រាអែម** ទៅដល់ប្រាសាទព្រះវិហារត្រូវចំណាយពេលអស់ ៤៥ នាទី ។

### ៣.១.១. ប្លង់ប្រាសាទព្រះវិហារ

**ប្រាសាទព្រះវិហារ** គឺជាប្រាសាទខ្មែរដែលសាងសង់យ៉ាងស្កឹមស្កៃលើកំពូលភ្នំដងរែក មានកំពស់ ៥២៥





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia




ប្រភព: *Henri Parmentier, L'art khmer classique, Monument du quadrant nord-est, Texte et Planche, Les éditions d'art et d'histoire, Paris, 1939; Khun Samen, Prasat Preah Vihear, Phnom Penh, 2008.*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ម៉ែត្រ និង ស្ថិតនៅក្នុងខេត្តព្រះវិហារ នាទិសពាយ័ព្យនៃ **ព្រះរាជាណាចក្រកម្ពុជា** ។ បុព្វបុរសខ្មែរបុរាណបានជ្រើសរើសយកទីតាំងដែលស្ថិតនៅចុងពយនៃកំពូលភ្នំ ដើម្បីបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងបរិស្ថានធម្មជាតិ មនុស្ស និង វត្ថុស័ក្តិសិទ្ធិនៅក្នុងលោកនេះ ។ ការជ្រើសរើសយកកំពូលភ្នំដងរែក ដើម្បីសាងសង់ប្រាសាទព្រះវិហារនេះ មិនមែនជាការចៃដន្យទេ ដោយសារតែប្រាសាទព្រះវិហារ ដូចប្រាសាទ-ភ្នំដ៏ទៃទៀតដែរ គឺសាងសង់ឡើងដើម្បីឧទ្ទិសដល់ **ព្រះសិវៈ** ដែលមាន **ព្រះសិវៈលិង្គ** ជាតំណាង ។ បើមើលពីចំហៀង ឬ បើមើលពីក្រោម យើងឃើញប្រាសាទព្រះវិហារអណ្តែតលើព្វដ៏វេហាស៍ ដែលរឹតតែញ៉ាំងឱ្យប្រាសាទព្រះវិហារនេះកាន់តែមានភាពសក្ការថែមទៀត ។ ប្រាសាទនេះសាងសង់ជាដំណាក់ៗ ហើយប្រសិនបើសាសនិកជនដើរឡើងពីដំណាក់មួយទៅដំណាក់មួយទៀត ធ្វើឱ្យគេមានអារម្មណ៍ថា កំពុងដើរឆ្លងពីភពមនុស្សលោក ទៅកាន់ភពព្រាហ្មណ៍ បន្ទាប់មកទៅកាន់ភពក្សត្រ និង ទីបំផុតទៅដល់ស្ថានត្រៃត្រឹង ដែលជា **លំនៅដ្ឋានរបស់អាទិទេព** គឺ **ព្រះសិវៈ** ហើយ **ប្រាសាទព្រះវិហារ** កំពុងអណ្តែតលើអាកាសវេហាស៍ ដូចជាវត្ថុស័ក្តិសិទ្ធិដែលជួយថែរក្សាអាណាចក្រខ្មែរឱ្យរួចផុតពីឧបទ្រពចង្រៃទាំងអស់លើលោកនេះ ។

ប្រសិនបើយើងមើលពីលើទៅក្រោម យើងឃើញវាលវែងដាច់កន្ទុយភ្នែក ហើយអ្នកទស្សនាមានអារម្មណ៍ថាកំពុងឈរលើអាកាសព័ទ្ធជុំវិញដោយដុំពពក ហើយនៅចំហៀងមានជួរភ្នំសងខាងដែលអមប្រាសាទព្រះវិហារនេះបីដូចជានិមិត្តរូបនៃ **ព្រះសិវៈ** ដែលអមដោយ **ព្រះព្រហ្មណ៍** និង **ព្រះវិស្ណុ** ដែលជា**ត្រីមូរ្តិ** នៃសាសនាព្រាហ្មណ៍-និយម ។ នៅពីក្រោម គឺជាវាលទំនាបខ្មែរដែលមានទន្លេបឹងបួរហូរចាក់ស្រែះបីដូចជាសរសៃឈាមចាក់ស្រែះអស់សព្វសពាង្គកាយ ដែលក្នុងនោះមានស្ទឹងសែនខ្មែរដែលមានប្រភពពីភ្នំដងរែកហូរពត់ពែនតាមព្រៃព្រឹក្សាលតាវល្លិចាក់ចូលដល់បឹងទន្លេសាប ។ បើយើងក្រឡេកមើលទៅទិសខាងត្បូង យើងនឹងឃើញវាលរាបលាតសន្ធឹងរហូតដល់ភ្នំគូលែន ដែលជាបូជនីយដ្ឋានមួយទៀតរបស់ព្រះមហាក្សត្រខ្មែរ និងទីក្រុងបុរាណខ្មែរ **យសោធរបុរៈ** ឬ **ទីក្រុងអង្គរ** ដែលជាបូជនីយដ្ឋានដ៏សំខាន់របស់បុព្វបុរសខ្មែរសម័យដើម ។

ប្រាសាទព្រះវិហារខុសពីប្រាសាទខ្មែរដ៏ទីទៀតដែលបែរមុខទៅទិសខាងកើត និង មានរាងបួនជ្រុងទ្រវែង ។ ប្រាសាទព្រះវិហារត្រូវបានសង់ឡើងបែរមុខឆ្ពោះទៅទិសខាងជើង តាមបណ្តោយអ័ក្សជើង-ត្បូង មានប្រវែងសរុបប្រមាណជា ១.៨០០ ម៉ែត្រ រៀបចំជាបីថ្នាក់ ពីក្រោមរហូតដល់កំពូលភ្នំ ដែលមានប្រាង្គប្រាសាទកណ្តាល ជានិមិត្តរូបនៃភ្នំ **ព្រះសុមេរុ** ដើម្បីជាបូជនីយដ្ឋានខាងផ្នែកសាសនា ។ ទីកន្លែងនេះត្រូវបានជ្រើសរើស ដោយសារបរិស្ថានធម្មជាតិគ្មានពីរនៃកំពូលភ្នំដងរែកនេះ ហើយស្ថាបត្យករបុរាណខ្មែរបានសម្របសម្រួលប្លង់ប្រាសាទទៅនឹងស្ថានភាពភូមិសាស្ត្រជាក់ស្តែងតែម្តង ដោយប្រហែលជាឈរលើមូលហេតុ **ប្រាង្គប្រាសាទកណ្តាល** ត្រូវស្ថិតនៅលើកំពូលភ្នំ ។ ដូច្នេះ មានតែសង់ប្រាសាទនេះតាមបណ្តោយអ័ក្សជើង-ត្បូងប៉ុណ្ណោះទើបបាន ពីព្រោះនៅតំបន់ជិត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះគ្មានទីតាំងឯណាឱ្យល្អជាងនេះទេ ហើយក៏គេមិនអាចមានទីតាំងដើម្បីសង់ប្រាសាទភ្នំនេះតាមបណ្ដោយអ័ក្សលិច- កើតដែរ ។

ប្រាសាទព្រះវិហារត្រូវបានសាងសង់ជាបីជាន់ ដែលដំណាងឱ្យស្ថានមនុស្សលោក ស្ថានក្សត្រ និង ស្ថានអាទិទេព និងមានប្រវែងជាង ១.៨០០ ម៉ែត្រ តាមបណ្ដោយអ័ក្សជើង- ត្បូង ដែលមានកាំជណ្ដើរឡើងវិថីដែលនាំឡើងទៅកាន់គោបុរៈ ហើយនាំទៅដល់ប្រាង្គកណ្ដាលតែម្ដង ដែលជាទីគោរពបូជា ។ ប្រាង្គកណ្ដាលនេះស្ថិតនៅចុងកំពូលភ្នំផ្នែកខាងត្បូង ដែលមានកំពស់ចំនួន ១២០ ម៉ែត្រខ្ពស់ជាងប្រាសាទនៅទិសខាងជើង មានកំពស់ ៥២៥ ម៉ែត្រខ្ពស់ជាងវាលទំនាបខ្មែរខាងក្រោម និង មានរយៈកំពស់ចំនួន ៦២៥ ម៉ែត្រខ្ពស់ជាងកម្រិតទឹកសមុទ្រ ។ ប្រសិនបើយើងដើរពីក្រោមឡើងទៅលើ យើងមានអារម្មណ៍រំភើបញាប់ញ័រ ជាងយើងដើរពីលើចុះក្រោម ។

លក្ខណៈរួមនៃប្រាសាទព្រះវិហារ គឺ ប្រាសាទនេះមានគោបុរៈចំនួន ៥ ដែលសាងសង់តាមរចនាបថផ្សេងៗគ្នា ។ មុននឹងទៅដល់គោបុរៈនីមួយៗ ត្រូវមានវិថី ឬ ព្រះលាន ដែលមានតួនាទីចម្លងអ្នកធ្វើបូជនីយកិច្ចពីភពមួយ ទៅភពមួយទៀត ។ នៅចុងវិថីនីមួយៗមានជណ្ដើរថ្មចោត ដើម្បីទៅដល់គោបុរៈមួយទៀត ។ វត្តមាននៃជណ្ដើរថ្មនេះដែលមានកំពស់ជាងពីរម៉ែត្រ បានធ្វើឱ្យគោបុរៈនីមួយៗកាន់តែមានភាពស្ងប់ស្ងែងថែមទៀត ដែលហាក់បីដូចជានិមិត្តរូបនៃការឆ្លងឡើងភពមួយផ្សេងទៀត ។ គោបុរៈនីមួយៗច្រើនសាងសង់ជារាងកាកបាទ និងមានទ្វារបែទៅកាន់គ្រប់ទិស គឺខាងជើង ខាងត្បូង ខាងកើត និង ខាងលិច ។ នៅមាត់ទ្វារមានតែមទ្វារ មានសសរពេជ្រមានផ្ដែរ និង ហោជាង ។ គោបុរៈច្រើនសាងសង់ឡើងដោយមានដំបូលឈើប្រក់ក្បឿង ។

ប្រសិនបើទេសចរដើរឡើងប្រាសាទព្រះវិហារ គេត្រូវឡើង ជណ្ដើរកណ្ដាល ឆ្លងកាត់តាម **ព្រះលាននាគរាជ** ហើយត្រូវដើរឆ្លងកាត់គោបុរៈចំនួនប្រាំ (គឺគេត្រូវទៅដល់គោបុរៈទី ៥ មុនគេ ដោយសារតែគេចង់ឱ្យប្រាង្គកណ្ដាលត្រូវនៅជាប់នឹងគោបុរៈទី ១ តែម្ដង) ទើបទៅដល់ប្រាង្គកណ្ដាល ។ មុននឹងឆ្លងកាត់គោបុរៈនីមួយៗ ទេសចរត្រូវដើរតាមដងវិថីក្រាលថ្មភក់ជាមុនសិន ។ វិថីនេះមានលម្អដោយបង្គោលសីមាអមសងខាង ហើយពេលខ្លះមាននាគរាជអមខាងក្រៅបង្គោលសីមាទៀតផង ។ នៅខាងចុងវិថីក្រាលថ្ម គេត្រូវឡើងជណ្ដើរមួយដ៏ខ្ពស់ ដែលធ្វើឱ្យគោបុរៈនីមួយៗកាន់តែមានភាពស្កឹកស្កៃ និង ធ្វើឱ្យទេសចរកាន់តែចាប់អារម្មណ៍លើប្រាសាទថែមទៀត ។ នៅខាងក្រោយគោបុរៈនីមួយៗ ច្រើនមានព្រះលាន និងមានអាគារផ្សេងៗទៀត ដូចជាព្រះបរមរាជវាំង ឬ បន្ទប់ផ្សេងៗសម្រាប់ឱ្យបូជនីយជនស្នាក់នៅ ។ ការសាងសង់ប្រាសាទតាមដំណាក់ៗ និងមានកំពស់ខុសៗគ្នានេះ ធ្វើឱ្យទេសចរមិនអាចមើលឃើញនូវប្រាសាទដែលស្ថិតនៅក្នុងគោបុរៈខាងក្រោយទៀតបាន ដែលមានគោលដៅធ្វើឱ្យមានការកាត់ផ្ដាច់ខាងផ្នែកអារម្មណ៍រវាងភពមួយ ពីភពមួយទៀត និងធ្វើឱ្យទេសចរកាន់តែចង់ដឹង ពីប្រាសាទនៅខាងមុខថែមទៀតផង ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បន្ទាប់ពីឆ្លងផុតគោបុរៈទី ១ យើងនឹងទៅដល់ **ច្រាខ្លកណ្តាល** ឬ **ភទល័យ** ដែលជាទីសក្ការដ៏ស័ក្តិសិទ្ធិ និងដ៏ខ្ពង់ខ្ពស់បំផុតនៃប្រាសាទព្រះវិហារ ។ ផ្តែរ និង ហោជាងនៃប្រាសាទព្រះវិហាលម្អដោយក្បូរក្បាច់រចនា និងរូបចម្លាក់ដែលដកស្រង់ចេញមកពីទេវកថាឥណ្ឌាបុរាណ ហើយជាពិសេសគឺដកស្រង់មកពីរឿង **ភគវត្ត បុរាណ** (Bhagavata Puranas) និង រឿង **មហាភារតៈ** និង រឿង **រាមកេរ្តិ៍** ជាដើម ។

## ៣.១.២. ជណ្តើរកណ្តាល

ដើម្បីឡើងប្រាសាទព្រះវិហារ អ្នកទេសចរត្រូវឡើងតាម **ជណ្តើរកណ្តាល** ធ្វើពីថ្មភក់ ដែលចោតឡើងខ្ពស់យ៉ាងស្តឹមស្តៃបីដូចជាផ្លូវឡើងទៅកាន់ភ្នំ **ព្រះសុមេរុ** ដូច្នេះដែរ ។ នៅសងខាងជណ្តើរមានដាក់គែមថ្មអមសងខាងបីដូចជាបង្កាន់ដៃដ៏ធំដូច្នេះដែរ ។ **ជណ្តើរកណ្តាល** ត្រូវបានសាងសង់ឡើងជាពីរថ្នាក់ ។ នៅដើមថ្នាក់នីមួយៗមានគោថ្មពីរឈរអមសងខាង ដើម្បីយាមប្រាសាទ ។






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



តោថ្មយាមប្រាសាទព្រះវិហារ



ជណ្ដើរកណ្ដាល

## ៣.១.៣. ព្រះលានន‌ាគរាជ



លុះអ្នកទេសចរឡើងផុតជណ្ដើរទីពីរ គេនឹងទៅដល់ **ព្រះលាននាគរាជ** ដែលជាវិថីដ៏ធំមួយដែលមាននាគរាជញី- ឈ្មោលក្បាល ៧ មួយគូអមសងខាងដែលចាំការពារប្រាសាទ មុននឹងទៅដល់ណ្ដើរឡើងគោបុរះដំបូង។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្បាលនាគរាជនៃប្រាសាទព្រះវិហារមានលក្ខណៈខុសពីក្បាលនាគរាជនៃប្រាសាទផ្សេងៗទៀតរបស់ខ្មែរ ដូចជាប្រាសាទអង្គរវត្តជាដើម ។ ផុតពីព្រះលាននាគរាជនេះ ទេសចរនឹងទៅដល់គោបុរៈទី ៥ ដែលនៅពីមុខមានតោថ្មចំនួនពីរកំពុងឈរយាមសងខាង ។

### ៣.១.៤. គោបុរៈ

នៅប្រាសាទព្រះវិហារមានគោបុរៈទាំងអស់ចំនួនប្រាំ ។ ប្រាសាទ និងគោបុរៈទាំងនេះត្រូវបានសាងសង់ឡើងដោយព្រះមហាក្សត្រផ្សេងៗគ្នា ។ លោក **ឆាម៉ង់ទីយេ** បានរាប់គោបុរៈដំបូងថាជាគោបុរៈទី៥ ហើយគោបុរៈចុងក្រោយដែលមាន **ប្រាង្គកណ្តាល** គឺជាគោបុរៈទី ១ ដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃគោបុរៈដែលមានប្រាង្គកណ្តាលនេះនៅក្នុងប្រព័ន្ធជំនឿរបស់ខ្មែរ ។ លោក **ឆាម៉ង់ទីយេ** បានសន្និដ្ឋានថា ជណ្តើរកណ្តាល គោបុរៈទី ៥ និង គោបុរៈទី ៤ ក៏ដូចជាវិថីនៅចន្លោះគោបុរៈទាំងពីរនេះ ត្រូវបានសាងសង់ឡើងដោយព្រះបាទ **យសោវរ្ម័នទី១** ។

នៅចន្លោះគោបុរៈនីមួយៗមានវិថី ដែលជានិមិត្តរូបនៃការដើរឆ្លងពីភពមួយ ទៅភពមួយទៀត ហើយគោបុរៈនីមួយៗមានតួនាទីជាព្រំប្រទល់បាំងភពទាំងអស់នេះ ។ ប្រាសាទព្រះវិហារដែលសាងសង់ឡើងជាបីថ្នាក់ប្រហែលជាឆ្លុះបញ្ចាំងនូវប្រព័ន្ធជំនឿសម័យនោះ ។ ថ្នាក់ទី១ ជាទីបូជនីយដ្ឋានរបស់ប្រជាជនធម្មតា ។ ថ្នាក់ទី២ ជាទីបូជនីយដ្ឋានរបស់បព្វជិតព្រាហ្មណ៍ ។ ថ្នាក់ទី ៣ ជាទីបូជនីយដ្ឋានរបស់ព្រះមហាក្សត្រ ។ ប្រាង្គប្រាសាទកណ្តាលដែលនៅលើកំពូលភ្នំ សម្រាប់ជា **និវាសនដ្ឋានអាទិទេព** គឺ **ព្រះសិវ** ដែលតំណាងដោយ **ព្រះសិវលិង្គ** ។

#### ៣.១.៤.១. គោបុរៈទី ៥

នៅខាងចុងព្រះលាននាគរាជ មានជណ្តើរថ្មមួយ កំពស់ប្រមាណជា ៣,៥ ម៉ែត្រ មានតោថ្មមួយគូរអមសងខាង ។ នៅពេលដែលយើងឡើងជណ្តើរនេះផុតទៅ យើងនឹងទៅដល់ **គោបុរៈទី ៥** ដែលមានរាងជាកាកបាទសង់លើខឿនខ្ពស់ពីដី និង មានក្លោងទ្វារបែមុខទៅទិសទាំងបួន ។

**គោបុរៈទី ៥** គឺជាគោបុរៈទោល ដូចជាអាគារតែមួយដាច់ពីគេ ដែលសាងសង់ឡើងតាមរចនាបថ **កោះកេរ្តិ៍** ។ យើងដឹងហើយថា នៅក្នុង គ.ស.៩២៧ ព្រះបាទ **ជ័យវរ្ម័នទី ៤** បានលើករាជធានីពី **ហរិហរាល័យ** ទៅកាន់ **កោះកេរ្តិ៍** ។ កាលពីដើមឡើយ គោបុរៈនេះសាងសង់ពីថ្មភក់មានដំបូលប្រក់ក្បឿង ដែលជាគ្រឿងសំណង់ដែលមិនអាចនៅសល់បានយូរលង់បានឡើយ ។ គោបុរៈនេះសាងសង់លើព្រះលានថ្មដែលមានកំពស់ប្រមាណ ៣,៥ ម៉ែត្រ ដោយរៀបចំដុំថ្មបួនជ្រុងបន្តុបពីលើគ្នា ដើម្បីជាទម្រទប់ និងជាខឿនដើម្បីសាងសង់គោបុរៈ ។ ចំណែកឯនៅខាងៗ ស្ថាបត្យករបានរៀបដុំថ្មបួនជ្រុងជាជម្រេលរាងទ្រេត ដើម្បីទប់ពីជ្រុងខាងជើង ខាងកើត និង ខាងលិច។ ជណ្តើរឡើងទៅកាន់គោបុរៈទី ៥ ត្រូវបានសាងសង់ជាបីគន្លាក់ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



មានតែមាត់ទ្វារខាងកើតនៃគោបុរៈទី ៥ ទេដែលនៅរក្សាសភាពដូចដើម ។ ជើងសសរ និង មាត់ទ្វារនៅចុងខាងលើ និង ចុងខាងក្រោម មានលម្អដោយក្បាច់ភ្ញីបង្ហាញពីធម្មជាតិ និង រុក្ខជាតិ ។ ក្បាច់ **រខស្សូទ** ដែលដាក់បន្ទុបពីលើហោជាង លម្អដោយក្បាច់រុក្ខជាតិ ដែលចម្លាក់ផ្កាឈូកក្រពុំដាកបញ្ឈរ និង ក្បាច់ផ្កាចំប៉ីដាក់ចន្លោះ ហើយនៅខាងចុងមានដើមឈើរុំព័ទ្ធ ជាក្រញុំដូចហោជាងនៃរចនាបថកោះកេរ្តិ៍ និង នៅប្រាសាទបន្ទាយស្រីដែរ ។ ដុំថ្មនីមួយៗមានចោះរន្ធតូចៗ ដើម្បីងាយស្រួលលើកចុះឡើងនៅពេលសាងសង់ ។ គោបុរៈទី ៥ នេះមានដំបូលប្រក់ក្បឿងធ្វើពីដីឥដ្ឋដុត ដែលប្រក់ពីលើដែរណែងឈើ។

**ហោជាង** នៃគោបុរៈទី ៥ មានលម្អនាគរាជក្បាលប្រាំ ដែលឆ្លាក់នៅតាមគែមហោជាង ដែលមានកន្ទុយជាប់គ្នានៅត្រង់កំពូលជ្រុងលើនៃហោជាង ។ នៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិ ។ នៅកណ្តាលហោជាង គេឃើញមានរាហ៊ូ ឬ កល កំពុងបញ្ចេញឫទ្ធិឱ្យគេស្ញប់ស្ញែង ។ នៅជុំវិញរាហ៊ូលម្អដោយក្បាច់រចនាឆ្លុះបញ្ចាំងពីរុក្ខជាតិ ។ រាហ៊ូត្រូវបានស្ថាបត្យករ នៃប្រាសាទព្រះវិហារយកមកឆ្លាក់លម្អស្ទើតែនៅគ្រប់ទីកន្លែងទាំងអស់។ រាហ៊ូនេះ គឺជានិមិត្តរូបនៃនិរន្តរភាពពេលវេលា ដែលសិល្បៈករខ្មែរចង់បង្ហាញពីនិរន្តភាពនៃសិល្បៈ និង វប្បធម៌ខ្មែរយើង ។ **ផ្តែរ** ដែលនៅពីក្រោមហោជាងមានលម្អដោយក្បាច់ពីរុក្ខជាតិ ។ តាមប្រពៃណីនៃប្រាសាទខ្មែរ គោបុរៈ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ខាងក្រៅគេបង្អស់ គឺជាគោបុរះដែលសំខាន់ជាងគេ ។ នៅប្រាសាទព្រះវិហារ គោបុរះខាងក្រៅគេថ្មីត្បិតតែមានទំហំតូចជាងគេមែន តែមានសម្រស់ល្អឆើតឆាយជាងគេ ដោយសារតែក្បូរក្បាច់រចនាលម្អគោបុរះទី ៥ នេះធ្វើឡើង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



តាមរចនាបទកោះកេរ្តិ៍ ហើយគឺក្លោងទ្វារខាងកើតនៃគោបុរៈទី ៥ នេះហើយ ដែលគេច្រើនថតយកជាតំណាងប្រាសាទព្រះវិហារទាំងមូល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia


ហាមចូល គ្រោះថ្នាក់
NO ENTRY DANGER





### ៣.១.៤.១.១. វិថីឆ្ពោះទៅកាន់គោបុរៈទី ៤



គោបុរៈទី៤ នៅឆ្ងាយពីគោបុរៈទី ៥ ប្រមាណជា ៣៤០ ម៉ែត្រ ។ ដូចគោបុរៈទី ៥ ដែរ មុនទៅដល់គោបុរៈទី ៤ ត្រូវឆ្លងកាត់នូវវិថីក្រាលថ្មភក់ ដែលមានបង្គោលសីមាដែលមានកំពស់ជាងពីរម៉ែត្រ និងមានកំពូលរាងផ្កាឈូកក្រពុំអមសងខាង ។ បង្គោលសីមាភាគច្រើនត្រូវរលំបែកបាក់ និងបាត់បង់ស្ទើរតែទាំងស្រុង ។ នៅដើមវិថីនេះពីខាងស្តាំដៃ គឺផ្លូវរថយន្តដែលឡើងមកប្រាសាទព្រះវិហារពីខាង **ព្រះរាជាណាចក្រកម្ពុជា** ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



### ៣.១.៤.១.២. ផ្លូវឡើងប្រាសាទព្រះវិហារពីកម្ពុជា

ផ្លូវដែលឡើងប្រាសាទព្រះវិហារពីចំហៀង ពីខាងព្រះរាជាណាចក្រកម្ពុជា គឺជាផ្លូវមួយចោតខ្លាំង ។ យើងត្រូវឡើងបត់បែនតាមចង្កេះភ្នំ រហូតបានទៅដល់កំពូលភ្នំ ។ ប្រការនេះ ធ្វើឱ្យការឡើងទស្សនាប្រាសាទព្រះវិហាររឹត




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែមានភាពរន្ធត់ញាប់ញ័រ និង មានអត្ថន័យខ្លាំងឡើងថែមទៀត ។

### ៣.១.៤.១.៣. វត្ត កែវសិក្ខាគិរីស្វរៈ

នៅពេលដែលឡើងជិតដល់កំពូល គេឃើញមានវត្តមួយធ្វើពីឈើ ដែលមានឈ្មោះថាវត្ត **កែវសិក្ខាគិរីស្វរៈ** ។ នៅពីក្រោយវត្តនេះ មានស្រះទឹកធម្មជាតិមួយដែលត្រងទឹកភ្លៀងហូរចុះពីលើកំពូលភ្នំ ។ យើងត្រូវជិះរថយន្តបន្តទៀត ទើបទៅដល់គោបុរៈទី ៥ និង វិថីពីគោបុរៈទី ៥ ឆ្ពោះទៅកាន់ គោបុរៈទី ៤ ។

### ៣.១.៤.១.៤. ស្រះទឹកធំ

នៅពេលយើងដើរតាមវិថីឆ្ពោះទៅកាន់គោបុរៈទី ៤ នៅខាងឆ្វេងដៃ មានស្រះមួយមានរាងចតុកោណ ។ ស្រះនេះមានជម្រៅប្រមាណជា ៧ ម៉ែត្រ បណ្តោយ ម៉ែត្រ និង ទទឹង ម៉ែត្រ ដោយមានរៀបថ្មជាជួរៗ ដើម្បីទប់ទឹកកុំឱ្យជ្រាបអស់ក្នុងដីផង និងដើម្បីធ្វើជាជណ្តើរសម្រាប់ចុះទៅក្រោមផង ។




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia




### ៣.១.៤.២. គោបុរៈទី ៤





គោបុរះទី ៤ នេះសង់លើជម្រាលភ្នំ ។ ដើម្បីសាងសង់ព្រះលានសម្រាប់គោបុរះទី ៤ គេត្រូវយកថ្មមកតម្រៀប ដើម្បីទប់ជាដំណាក់ៗធ្វើជាជញ្ជាំងទប់ដីកុំឱ្យបាក់ចុះមកក្រោម ។ គោបុរះទី ៤ មានរាងជាកាកបាទ និងមានទំហំធំជាងគោបុរះទី៤ ហើយដែលមានមាត់ទ្វារបួន ពីទិសខាងជើង ខាងត្បូង ខាងកើត និង ខាងលិច ។




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



នៅផ្នែកខាងត្បូងនៃគោបុរៈគេរៀបជញ្ជាំង ចំណែកឯផ្នែកខាងជើងមានរៀបជាសសរ ដែលមានដំបូលប្រក់ក្បឿង ។ សសរ និង រងស្បូវមានលម្អដោយក្បាច់ភ្ញីរុក្ខជាតិដូចនៅគោបុរៈទី ៥ ដែរ ហើយផ្ទៃខាងក្រោមមានក្រាលថ្មពាសពេញ ។

នៅមាត់ទ្វារខាងជើង គេមានដាក់តោថ្មឱ្យអង្គុយយាមទ្វារគោបុរៈ ត្រង់មាត់ជណ្តើរ ។ នៅលើផ្តែរមានរូបចម្លាក់ថ្ម ប្រកបដោយក្បូរក្បាច់ភ្ញីរុក្ខជាតិ និងមានទេវរូបអង្គុយលើក្បាលតោបឈ្សរក្បាលជង្គង់ម្ខាង ។ ទេវរូបដែលមាននាគរាជក្បាលប្រាំនៅអមសងខាង កំពុងអង្គុយបឈ្សរជង្គង់ម្ខាងដោយកាន់ព្រះខ័ននៅដៃស្តាំចង្អុលឡើងលើ ។ នៅលើហោជាងនៃទ្វារខាងក្នុង មានចម្លាក់ទេវរូបអង្គុយពីលើក្បាលរាហ៊ូ ដោយដៃស្តាំកាន់ព្រះខ័ន ។ នៅជុំវិញទេវរូបមានរូបចម្លាក់ក្បាច់ភ្ញីរុក្ខជាតិ ហើយនៅតាមគែមនៃហោជាងលម្អដោយនាគរាជក្បាលប្រាំ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



នៅលើផ្តែរទ្វារបែមុខទៅទិសខាងកើតមានរូបចម្លាក់ «**ព្រះគ្រិស្នៈបង្ក្រាបនាគរាជកលិយ**»។ ទេវកថានេះមានប្រភពមកពី **ភគវត្ត បុរាណ** (Bhagavata Purana) ។ នៅពេលដែល **ព្រះគ្រិស្នៈ**ឃើញសត្វពាហណៈ និងក្មេងគង្វាលគោឈឺ ដោយសារផឹកទឹកទន្លេ **កលិណ្ឌ** ដែលមានពិសពស់នាគរាជ **កលិយ** ព្រះគ្រិស្នៈ ក៏លោតឈរលើក្បាលពស់ ហើយរាំចាក់ក្បាច់ទន្ទ្រាំជើងយ៉ាងខ្លាំងរហូតដល់នាគរាជជិតស្លាប់ ។ ព្រះគ្រិស្នៈបានប្រាប់នាគរាជឱ្យចាកចេញឆ្ពោះទៅកាន់សមុទ្រ ។ នៅលើរូបចម្លាក់ «**ព្រះគ្រិស្នៈបង្ក្រាបនាគរាជ កលិយ**»នេះ យើងឃើញព្រះគ្រិស្នៈកំពុងរាំរែកទន្ទ្រាំលើក្បាលនាគរាជ ហើយយកដៃទាំងពីរហែកក្បាលនាគរាជជាពីរ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia





រូបចម្លាក់ដែលគួរឱ្យស្ញប់ស្ញែងជាងគេ នៅគោបុរៈទី ៤ នេះ គឺ ទេវកថា «**កូរសមុទ្រទឹកដោះ**» ដែលឆ្លាក់នៅលើផ្តែរនៃមាត់ទ្វារខាងត្បូង តាមរចនាបថ **ឃ្លាំង** និង **បាពួន** ។ ទេវកថា «**កូរសមុទ្រទឹកដោះ**» គឺជាវគ្គមួយនៃរឿង **មហាភារតៈ** និង នៅក្នុងរឿង **ភគវត្ត បុរាណ** ដែលរៀបរាប់ពីវីរៈភាពរបស់ព្រះវិស្ណុ នៅក្នុងការរៀបចំឡើងវិញនូវសណ្តាប់ធ្នាប់លើផែនដី តាមរយៈការចូលរួមកូរសមុទ្រទឹកដោះ ។ ដើម្បីស្វែងរកសន្តិភាព និង រៀបចំឡើងវិញនូវសណ្តាប់ធ្នាប់ ពពួកទេវៈចាំបាច់ត្រូវពង្រឹងឡើងវិញនូវព្រះធម៌ ដែលពពួកអសុរៈបានធ្វើឱ្យខូចខាតខ្ទេចខ្ទីអស់ តាមរយៈការស្វែងរកទឹកអម្រិត ដែលអាចឱ្យពួកទេវៈមានជីវិតអមតៈ ។ ហេតុដូច្នេះ ពួកទេវៈបានសហការជាមួយពួកអសុរៈ ដើម្បីកូរសមុទ្រទឹកដោះក្នុងគោលបំណងស្វែងរកទឹកអម្រឹត ដោយយកស្តេចពស់ **វ៉ាសុគី** ធ្វើជាខ្សែពួរសម្រាប់ទាញបង្វិលកូរសមុទ្រទឹកដោះ យកភ្នំ **មន្ទរៈ** ធ្វើជាស្នូល ។ ពួកគេបានកូរសមុទ្រទឹកដោះរាប់ពាន់ឆ្នាំ តែមិនបានទទួលជោគជ័យសោះ ។ ពេលនោះពួកគេបានសុំឱ្យ **ព្រះវិស្ណុ** ជួយ ។ ព្រះវិស្ណុបានឱ្យយោបល់ថាពួកទេវៈ និង ពួកអសុរៈត្រូវសហការគ្នា និង រៀបចំការកូរសមុទ្រទឹកដោះជាមួយគ្នា ។ ក៏ប៉ុន្តែ នៅពេលនោះ ស្រាប់តែភ្នំ **មន្ទរៈ** ចាប់ផ្តើមលិចចូលទៅក្នុងទឹកបន្តិចម្តងៗ ។ ព្រះវិស្ណុបានបែងភាគធ្វើជាសត្វអណ្តើក **កូម៌** ហើយមុជចុះក្នុងទឹកដោយយកស្នូកអណ្តើកទ្រភ្នំ **មន្ទរៈ** ពីក្រោម ហើយព្រះឥន្ទក៏បានយកជើងមកទប់កំពូលភ្នំឱ្យនៅនឹង (**មហាភារតៈ** ១៥.១.១១) ។ ពួកទេវៈ និង ពួកអសុរៈបានកូរសមុទ្រទឹកដោះអស់រយៈពេលរាប់ពាន់ឆ្នាំទៀត ទើបបានទទួលទឹកអម្រឹត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia







ការពិពណ៌នាទេវកថានៅលើហោជាងប្រាសាទនេះ ហាក់បីដូចជាលាយឡំ ផងដែរជាមួយនឹងទេវកថាពី **«កំណើតព្រះព្រហ្ម»** ។ សិល្បៈករខ្មែរបានគូសបង្គោលត្រង់មួយ ជានិមិត្តរូបនៃភ្នំ ដែលជាអ័ក្សនៃចក្រវាល ដែលដាក់បញ្ឈរចូលទៅក្នុងក្អមមួយសម្រាប់ត្រងទឹកអម្រឹត ។ នៅពីលើបង្គោលគេឃើញមានទេវរូបមួយអង្គកំពុងលូន ដែលតំណាងឱ្យព្រះវិស្ណុ ។ នៅម្ខាងទៀត គេឃើញមានព្រះអាទិត្យ និង ព្រះច័ន្ទ ។ មូលហេតុដែលទេវកថានេះមានរូបព្រះអាទិត្យ និង ព្រះចន្ទ ផងដែរនោះ គឺដោយសារតែនៅពេលដែលទទួលបានទឹកអម្រឹតរួចហើយ ព្រះវិស្ណុទ្រង់គង់ជាអាជ្ញាកណ្តាល ដើម្បីចែកទឹកអម្រឹត ។ ទ្រង់បានបន្លំភ្នែកពួកអសុរៈ ហើយលួចចែកទឹកអម្រឹតឱ្យតែពួកទេវៈប៉ុណ្ណោះ ។ យក្ស **សុក្រាចារ្យ** ដែលជាគ្រូនៃពពួកអសុរៈ ឃើញដូច្នោះក៏បានប្រែក្រឡាខ្លែងខ្លួនធ្វើជាទេវៈ ហើយទទួលបានទឹកអម្រឹតដូចប្រាថ្នា ។ ព្រះច័ន្ទ និង ព្រះអាទិត្យដឹងភ្លាមក៏ទូលព្រះវិស្ណុភ្លាម ។ ព្រះវិស្ណុក្រោធយ៉ាងខ្លាំង ក៏គប់កងចក្រត្រូវ **សុក្រាចារ្យ** ដាច់ជាពីរកំណាត់ ហើយក្លាយជាអាទិទេពពីរអង្គ ។ ក្បាលរបស់ **សុក្រាចារ្យ** បានក្លាយជា **រាហ៊ូ** ចំណែកឯខ្លួនវិញបានក្លាយជា **កេតុ** ។ ដូច្នេះហើយ ទើបរាហ៊ូតែងតែសងសឹកវិញដោយលេបព្រះច័ន្ទ ដែលយើងហៅថាច័ន្ទគ្រាស និង លេបព្រះអាទិត្យ ដែលយើងហៅថាសូរ្យគ្រាស ។



ផ្តែរដែលនៅខាងក្រោមហោជាងនេះ មានឆ្លាក់ទេវកថានៃការបង្កើតលោក គឺ **«វិស្ណុផ្ទំលើពស់អនន្ត»** និង **«កំណើតព្រះព្រហ្ម»** ។ ទេវកថាដែលព្រះវិស្ណុបង្កើតព្រះព្រហ្មណ៍ពីទងឈូក ដែលចេញពីទងផ្ចិតរបស់ព្រះអង្គត្រូវបានគេដាក់ឈ្មោះឱ្យថាជា **«កំណើតព្រះព្រហ្ម»** ។ នៅពេលព្រលប់បានចូលមកដល់ **ព្រះវិស្ណុ - ព្រះនារាយណ៍** កំពុងផ្ទុំលើរលកសមុទ្រនៃមហាសាគរដ៏ធំធេង ។ រលក គឺជានិមិត្តរូបនៃភាពច្របូកច្របល់ ។ ព្រះវិស្ណុទម្រេតខ្លួនលើពស់ **អនន្ត** ដែលបណ្តែតខ្លួនលើផ្ទៃមហាសាគរ ដែលជាតំណាងឱ្យ «ភាពអរូបី» បន្ទាប់ពីចក្រវាលទាំងមូលបានធ្លាក់ចុះទៅក្នុងសភាពច្របូកច្របល់ ។ **ព្រះវិស្ណុ - ព្រះនារាយណ៍** យកព្រះហស្តទ្រព្រះកេសរបស់ព្រះអង្គ ។ ព្រះមហេសីទាំងពីរអង្គរបស់ព្រះអង្គ គឺព្រះនាង **លក្ស្មី** និង ព្រះនាង **ភូមីទេវី** កំពុងកាន់ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្កែលព្រះបាទរបស់ព្រះអង្គ។ នៅពេលដែលព្រះវិស្ណុក្រោកពីផ្ទុំ ហើយចាប់ផ្តើម គិតពីការបង្កើត ស្រាប់តែមានផ្កាឈូកចេញពីផ្ចិតរបស់ព្រះអង្គ ហើយ**ព្រះព្រហ្ម** ក៏លេចចេញឡើង មានព្រះភក្រ្តបួននៅក្នុងផ្កាឈូក ។ **ព្រះព្រហ្ម** ក៏បានជប់បង្កើតឫសីចំនួន ៩ ដើម្បីបញ្ចប់ដំណើរការបង្កើតសត្វលោក ។ នៅពេលដែល **ព្រះវិស្ណុ - ព្រះនារាយណ៍** ទម្រេតខ្លួនលើពស់អនន្ត ដែលកំពុងអណ្តែតលើផ្ទៃសមុទ្រទឹកដោះ ហើយកំពុងធ្វើវិបស្សនា គេឱ្យឈ្មោះទេវកថានេះថាជា «**វិស្ណុផ្ទំពស់ អនន្ត**» ។











### ៣.១.៤.២.១. វិថីឆ្ពោះទៅកាន់គោបុរៈទី ៣

បន្ទាប់ពីចេញពីគោបុរៈទី ៤ យើងឃើញមានវិថីក្រាលថ្មភក់ ដែលមានទទឹងប្រមាណជា ១០ ម៉ែត្រ បណ្ដោយប្រវែងជិត ១៥០ ម៉ែត្រ និងបង្គោលសីមាអមសងខាង តម្រង់ឆ្ពោះទៅកាន់គោបុរៈទី ៣ និង ទៅកាន់ព្រះលាននៃប្រាសាទ ។





### ៣.១.៤.២.២. ស្រះទឹកតូច

នៅពេលដើរចេញបន្តិច នៅខាងឆ្វេងដៃមានស្រះទឹកតូចមួយ ដែលគេហៅថា **ស្រះស្រង់** ដែលមានរាងជាចតុកោណកែងស្មើ ដែលជ្រុងនីមួយៗមានប្រវែង ៩ ម៉ែត្រ ។ គែមសងខាងស្រះគ្រប់ជ្រុងទាំងអស់មានថ្មតម្រៀបជាជួរដើម្បីទប់ទឹកផង និង ងាយស្រួលក្នុងការចុះដងទឹកផង ។ ប្រជាជនខ្មែរតាំងពីសម័យបុរាណមានជំនឿថាស្រះស្រង់នេះមានឫទ្ធិបារមី ហើយទឹកស្រះនេះត្រូវបានព្រះមហាក្សត្រខ្មែរដងយកទៅរៀបចំពិធីអភិសេក ។ ព្រះមហាក្សត្រថៃក៏មានជំនឿដូចគ្នាដែរ ។ ដូច្នេះហើយទើបនៅក្នុងឱកាសធ្វើរាជាភិសេកព្រះបាទ **ភូមិបុល អាឌុលយ៉ាដេត** នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ១៩៤៦ គេបានដងយកទឹកស្រះស្រង់នេះដើម្បីយកទៅរៀបចំពិធីរាជាភិសេក ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia









fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



### ៣.១.៤.៣. គោបុរៈទី ៣






នៅចុងវិថីដែលនៅចន្លោះគោបុរៈទី ៤ និង គោបុរៈទី ៣ មានជណ្តើរថ្មឡើងទៅកាន់គោបុរៈទី ៣ ដែលមានគោថ្មមួយគូរអមសងខាង និងមានរាងជាកាកបាទ ។ គោបុរៈទី ៣ ត្រូវបានសាងសង់លើព្រះលាន ដែលមានថ្មភក់ទប់ជាជញ្ជាំងយ៉ាងមាំមួយ ដូចនៅគោបុរៈទី ៤ ដែរ ។ គោបុរៈទី ៣ នេះមានគោបុរៈកណ្តាល ថែវខាងឆ្វេង និង ថែវខាងស្តាំ និងមានបន្ទប់ ខាងឆ្វេង និង បន្ទប់ខាងស្តាំ ។





គោបុរៈទី ៣ គឺជាគោបុរៈដែលធំជាងគេ ដែលជា **ព្រះបរមរាជវាំង** សម្រាប់ព្រះរាជាស្នាក់នៅ នៅពេលដែលព្រះអង្គយាងមកប្រាសាទព្រះវិហារដើម្បីថ្វាយបង្គំព្រះអាទិទេព ។ នៅអមសងខាងគោបុរៈទី ៣ នេះមានអាគារចំនួន ២ ខ្នងប្រក់ក្បឿង ដែលជាកន្លែងសម្រាប់បូជនីយជនស្នាក់នៅ ។

គោបុរៈកណ្តាល មានឆ្លាក់ចម្លាក់យ៉ាងស្រស់បំព្រង ដែលឆ្លាក់លើផ្តែរ និង លើហោជាងប្រាសាទ ដែលក្នុងនោះគេឃើញមានរូបចម្លាក់ដូចតទៅ ÷

ទេវកថា «**ព្រះក្រឹស្ណៈសម្លាប់ដំរី គុវល្លយពីដ និង សត្វសិង្ហ**» ឆ្លាក់នៅចំកណ្តាលហោជាងនៃទ្វារដែលបែមុខទៅជើង ។ តាមរឿងដែលដំណាលនៅក្នុង **ភគវត្ត បុរាណ** បានឱ្យដឹងថា ថ្ងៃមួយនៅពេលដែល **ព្រះក្រឹស្ណៈ** និង **បលរម** ទៅកំសាន្តនៅភ្នំ **មធុរៈ** ហើយមុននឹងចូលប្រកួតចម្បាប់ ព្រះទាំងពីរព្រះអង្គបានឮសូរសម្លេងគង និងសម្រែកសត្វចេញមកពីទីលានប្រកួត ។ នៅពេលដែលពួកគេទាំងពីរស្ទុះចេញទៅមើល គេឃើញមានស្តេចដំរី **គុវល្លយពីដ** ដ៏ធំមួយកំពុងរារាំងផ្លូវចូល ។ ទ្រមាក់ដំរីបាន អុជអាលឱ្យដំរីឈ្លោះជាមួយព្រះក្រិស្ណៈ ហើយបន្ទាប់មកក៏ចាប់ផ្តើមមានជម្លោះយ៉ាងគគ្រឹកគគ្រេង ។ ដំរីបានយកប្រមោយរបស់វាមកចាប់ព្រះគ្រិស្ណៈ ក៏ប៉ុន្តែព្រះគ្រិស្ណៈបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេចរួចឱ្យផុតពីដំរី ។ បន្ទាប់មកព្រះក្រិស្ណៈបានយកដៃទៅចាប់កន្ទុយ ហើយបានអូសទាញដំរីនេះឱ្យឃ្លាតទៅឆ្ងាយ ។ នៅពេលដែលដំរីនេះចាប់ផ្ដើមសម្រុកចូលសារជាថ្មី ព្រះក្រិស្ណៈបានចាប់ភ្លុកដំរី ឬ ចាប់កន្ទុយ ដំរី ចាប់បោកទៅដី ហើយយកជើងរបស់ព្រះអង្គទៅកំទេចឧបស័គ្គទាំងនោះ ។ បន្ទាប់ពីគេដកភ្លុកដំរីនេះចេញមក ព្រះអង្គក៏សម្រេចចិត្តចូលទៅក្នុងឆាកដើម្បីប្រយុទ្ធ ។




នៅលើហោជាងនេះ គេឃើញមានព្រះក្រិស្ណៈ ដែលដៃខាងស្ដាំកាន់ជើងក្រោយរបស់ដំរី ហើយដៃឆ្វេងកាន់សត្វសឹង្ហមួយទៀត ។ ដំរី **គូវ្លយពីដ** ត្រូវបាន **កម្ពស** បញ្ជូនមកដើម្បីសម្លាប់ **ព្រះក្រិស្ណៈ** និង **បលរម** ។ ហើយសត្វមួយទៀត គឺសត្វសឹង្ហ ។ នៅលើផ្ដែរពីក្រោម គេឃើញមានទេវមួយអង្គកំពុងកាន់ព្រះខ័ន ដោយលុតជង្គង់លើក្បាលសឹង្ហមួយទៀត ។ គេឃើញមានសត្វប្រើសមួយងាកក្បាលមកក្រោយ ហើយឈរនៅខាងមុខសឹង្ហ និង ដំរី ។ នៅសងខាងកំពូលដើមឈើ គេឃើញមានទេវរូបកំពុងហោះលើអាកាសវេហាស៍ ។ នៅលើផ្ដែរគេឃើញមានទេវរូបមួយអង្គទៀតអង្គុយលើក្បាលសឹង្ហ ដែលកំពុងឈរលើជើងពីរយ៉ាងសង្ហា ។ ទេវរូបនេះអង្គុយលើកជង្គង់ម្ខាង ហើយដៃស្ដាំលើកព្រះខ័នបឈ្លួរឡើង ។ រូបចម្លាក់នេះ ត្រូវបានលម្អដោយរូបរុក្ខជាតិ ។

នៅចំកណ្ដាលហោជាងនៃទ្វារខាងជើង ផ្នែកខាងក្នុង គេឃើញមានរូប «**ព្រះក្រិស្ណៈគោវធ៌ន**» ដែលនៅចំកណ្ដាលនៃផ្ដែរ ។ តាមរឿងនិទាននៅក្នុង **ភគវត្ត បុរាណ** (X, 25) បានឱ្យដឹងថា បន្ទាប់ពីព្រះគ្រឹស្ណបានឈ្លោះជាមួយព្រះឥន្ទ្រ ព្រះឥន្ទ្រមានការខឹងសម្បារយ៉ាងខ្លាំងដោយសារមានគេមករំខានក្នុងការតាំងសីល ហើយបានជប់ជាពពក ដើម្បីបង្កើតឱ្យមានភ្លៀងផ្គរក្នុងគោលដៅកម្ទេចផែនដី និង ចក្រវាល ។ ព្យុះភ្លៀង និង ព្យុះទឹកកកព្រមទាំងរន្ទះ និងផ្គរលាន់បានធ្វើឱ្យព្រះគោ **នន្ទិ** សត្វគោ និងសត្វពាហនៈដ៏ទៃទៀតមានការភ័យខ្លាចយ៉ាងខ្លាំង ហើយរត់មកឱ្យព្រះគ្រិស្ណៈជួយ ។ ព្រះគ្រិស្ណៈបានប្រើវេទមន្តដើម្បីបឈ្លប់ និង ដាក់ទោសព្រះឥន្ទ្រ ដោយយកដៃម្ខាងដកភ្នំ **គោវធ៌ន** ហើយទ្រភ្នំនេះពីលើក្បាលក្នុងរយៈពេល ៧ យប់ ៧ ថ្ងៃ ដើម្បីការពារសត្វពាហនៈទាំងអស់កុំឱ្យ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រងគ្រោះ ។ នៅពេលនោះ ព្រះឥន្ទ្របានទទួលស្គាល់ថាព្រះអង្គចាញ់ឫទ្ធិ ព្រះក្រិស្ណៈ ហើយបានតែងតាំងព្រះក្រិស្ណៈជា **គោវធិន** ដែលជាអាទិទេពការពារសត្វគោ ។ រូបចម្លាក់នៅលើហោជាងប្រាសាទ បង្ហាញព្រះគ្រិស្ណៈឈរក្រោមដើមឈើមួយយ៉ាងធំ ដៃឆ្វេងលើកឡើងលើកាន់ភ្នំ **គោវធិន** ដើម្បីការពារគោ និង ក្មេងគង្វាល គោឱ្យរួចផុតពីព្យុះភ្លៀង និង រន្ទះបាញ់ ។



ចំណែកឯចម្លាក់លើផ្តែរខាងក្រោមវិញ គឺជារូប «**ព្រះវិស្ណុជិះគ្រុឌ**»។ គ្រុឌឈរលើក្បាលរាហ៊ូ ដោយមានទេវរូបពីរព្រះអង្គលើកដៃឈរអមសងខាង ។ ព្រះវិស្ណុដែលមានដៃបួនឈរលើខ្នងគ្រុឌ ។ រាហ៊ូកាន់កម្រងផ្កានៅដៃទាំងពីរ ។



រូបចម្លាក់នៅលើហោជាងនៃទ្វារខាងកើត គឺ «**ព្រះគ្រិស្ណ:សម្លាប់សេះកេសិន**»។ តាមរឿងនិទាននៅក្នុង **ភគវត្ត បុរាណ** (X, 37) បានឱ្យដឹងថា **កម្ពស** បានពឹងឱ្យអសុរៈ **កេសិន** មកសម្លាប់ព្រះគ្រិស្ណៈ ។ អសុរៈកេសិនបានប្រែក្រឡាជាសេះដ៏ធំ ហើយបានបង្កើតឱ្យមានវិនាសកម្ម និង ភាពជ្រួលច្របល់នៅក្នុងហ្វូងគោ ។ ថ្ងៃមួយ សេះកេសិននេះបានដេញខាំ និង ដេញទាត់ព្រះក្រិស្ណៈ ។ ព្រះក្រិស្ណៈចាប់ជើងអសុរៈគ្រវី ហើយបោះទៅយ៉ាងឆ្ងាយ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រួចព្រះគ្រិស្ណៈបានលូកដៃចូលមាត់សេះកេសិន ហើយពង្រីកដៃនេះឱ្យធំ ធ្វើឱ្យអសុរៈកេសិនថប់ខ្យល់ស្លាប់មួយរំពេច។ ឆាកប្រយុទ្ធនេះឆ្លាក់លើផ្ទៃផ្តែររាងត្រីកោណ ដោយមានព្រះក្រិស្ណៈកំពុងប្រយុទ្ធជាមួយសេះ **កេសិន** ដែល **កម្ពស** បញ្ជូនមកដើម្បីសម្លាប់ព្រះអង្គ ។ នៅជុំវិញរូបនេះ សិល្បៈករខ្មែរលម្អ ដោយក្បាច់ភ្ញីស្លឹកឈើគួរជាទីគយគន់ ។



នៅខាងក្រោមហោជាងនេះ មានផ្តែរដែលមានឆ្លាក់រូប «**ព្រះសិវៈ និង អរជុនកំពុងប្រយុទ្ធគ្នា**» ។ តាមទេវកថា **មហាភារតៈ** បានឱ្យដឹងថា **អរជុន** ត្រូវបាននីរទេសចូលក្នុងព្រៃជ្រៅ និងត្រូវឆ្លងកាត់នូវដំណើរផ្សងព្រេង និងវិញ្ញាសាររាប់មិនអស់ ដើម្បីត្រៀមខ្លួនជួបជាមួយនឹងព្រះសិវៈ ដែលប្រែក្រឡាជា **គតិ** ។ ដូច្នេះហើយទើបទេវកថានេះមានឈ្មោះថា «**អរជុន និង គតិ**» ឬ « **អរជុនគតិ**» ។ បន្ទាប់ពីបានចាកចេញពីបងប្អូនដើម្បីត្រេចចរក្នុងព្រៃ **អរជុន** បានទៅដីទីរហោស្ថាន ហើយបានស្ញឹងស្មាធយ៉ាងហ្មឹងម៉ាត់ ដើម្បីទទួលបាននូវកម្លាំងខ្លាំងក្លា ។ ឫសីឃើញដូច្នេះមានការភិតភ័យយ៉ាងខ្លាំង ហើយបានទូលថ្វាយ **ព្រះសិវៈ** ។ **ព្រះសិវៈ**បានប្រែក្រឡាជាព្រានព្រៃ **គតិ** ដែលរស់នៅតែក្នុងព្រៃបាញ់សត្វជាចំណីអាហារ ។ ពេលនោះ ស្រាប់តែមានខ្លាឃ្មុំមួយ ដែលមានកំណើតពីអសុរៈប្រុងនឹងលោតសង្គ្រប់លើ **អរជុន** ។ ពេលនោះអរជុនទាញព្រួញបាញ់ភ្លាមដើម្បីការពារខ្លួន តែ **គតិ** ក៏បានបាញ់ព្រួញក្នុងពេលតែមួយ ដើម្បីការពារ **អរជុន** ។ **អរជុន** បានប្រកែកជាមួយ **គតិ** ថា គឺ ព្រួញរបស់ខ្លួនដែលបាញ់សត្វខ្លាឃ្មុំនេះស្លាប់ ។ បន្ទាប់ពីការប្រកែកគ្នានេះ **ព្រះសិវៈ** និង **អរជុន** បានចាប់ផ្តើមប្រយុទ្ធគ្នា ហើយ **អរជុន** បានបាញ់អស់ព្រួញទិព្វដែលបាញមិនចេះអស់របស់ខ្លួន ហើយធ្នូក៏ត្រូវ **គតិ** យកបានទៀត ។ គូរបដិបក្សទាំងពីរបានចាប់ផ្តើមប្រយុទ្ធដៃទល់នឹងដៃ ។ ក៏ប៉ុន្តែ នៅពេលដែល **អរជុន** រឹតបំពង់ក **គតិ** គាត់មានអារម្មណ៍ថា មានភាពចុកចាប់ខ្លាំងជាងគូរប្រកួតរបស់ខ្លួនទៅទៀត ។ ការប្រយុទ្ធគ្នាមានសភាពខ្លាំងក្លា បែកផ្សែងបែភ្លើង ហើយអរជុនចាប់ផ្តើមមានអារម្មណ៍ ហាក់បីដូចជាប្រហោងក្នុងលែងមានជីវិត ។ តែអរជុននៅមានកម្លាំងគ្រប់គ្រាន់ ដើម្បីស៊ឹង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្វាធឃើញរូបព្រះសិវៈ (មហាទេវ) ក្នុងគោលដៅគោរពប្រណិប័តន៍ព្រះសិវៈ និង សុំឱ្យព្រះអង្គជួយ ។ **អរជុន** បានបំពាក់កម្រងផ្កាជូនព្រះសិវៈនៅក្នុងអារម្មណ៍របស់ខ្លួន តែស្រាប់កម្រងផ្កានេះធ្លាក់ចុះលើក្បាល់ **គតិ** ទេវិញ ។ នៅពេលនោះទើប **អរជុន** បានដឹងថា **គតិ** នេះ គឺជា **ព្រះសិវៈ** ។ **ព្រះសិវៈ** មានការពេញចិត្តចំពោះ **អរជុន** ដែលមានសេចក្ដីក្លាហាន និង មានការគោរពប្រណិប័តន៍ដល់ព្រះអង្គ ហើយបានប្រគល់ឱ្យអរជុននូវសព្វាវុធទិព្វមួយ ។



នៅកណ្ដាលហោជាងនៃទ្វារខាងជើង មានរូបចម្លាក់ «**ព្រះគ្រិស្ណៈសម្លាប់គោអារិស្តៈ**»។ តាមរឿងនិទាននៅក្នុង **ភគវត្ត បុរាណ** (X, 36) បានឱ្យដឹងថា **ព្រះគ្រិស្ណៈ** និង **បលរាម** បានទៅដល់ **វជៈ** មានអសុរៈដ៏ធំមួយបានប្រែក្រឡាទៅជាគោមួយយ៉ាងធំ និង មានស្នែងស្រួច ។ គោនេះបានជល់គាស់ដី ដែលជានិមិត្តរូបនៃការបំពារបំពានលើព្រះធមិ ដែលធ្វើឱ្យទាំងសត្វ ទាំងមនុស្សបានចាកចេញពីតំបន់នោះ ។ ព្រះគ្រិស្ណៈក៏បង្ខំចិត្តធ្វើអន្តរាគមន៍ ក៏ប៉ុន្តែអសុរៈក៏ងាកមកជល់ព្រះគ្រិស្ណៈ ។ **ព្រះគ្រិស្ណៈ** ក៏ចាប់ស្នែកគោជាប់ កាច់ក្បាលគោជល់ដី ដកស្នែង និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្លាប់គោ **អរិស្ឋ** តែម្តង ។ នៅលើហោជាងបង្ហាញពី ចម្លាក់រាងត្រីកោណ ដែលលម្អដោយក្បូរក្បាច់រចនារុក្ខជាតិ **ព្រះគ្រិស្ណៈ** កំពុងលើកគោ **អរិស្ឋ** បោះក្នុងលំហរអាកាស មុននឹងសម្លាប់គោនេះនៅលើដី ។ នៅក្រោមហោជាងមានផ្តែរដែលឆ្លាក់ទេវរូបដៃម្ខាងកាន់ព្រះខ័ន អង្គុយលើរាហ៊ូ ។




នៅលើទ្វារដែលបែមុខទៅទិសខាងត្បូង មានហោជាងដែលឆ្លាក់រូប «**យមរាជជិះក្របី**» ដែលបង្ហាញពីយមរាជ ដៃកាន់ព្រះខ័នកំពុងជិះក្របីអង្គុយនៅលើក្របី ដែលឆ្លាក់លើក្បាលរាហ៊ូ ។



នៅលើផ្តែរទ្វារខាងក្រោម មានចម្លាក់ «**ព្រះរាម ត្រលប់មកអាយុធ្យាវិញ**»។ តាមរឿង **រាមកេរ្តិ៍** ព្រះរាមបានសម្រេចត្រលប់មកផ្ទះវិញ ដើម្បីមកជួបប្អូនប្រុសរបស់ព្រះអង្គព្រះនាម **ភារតៈ** ។ **វិភិសនា** បានរៀបចំ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រទេះទិព្វ **បុស្បុបក** ដែលអូសដោយសត្វហង្ស សម្រាប់ឱ្យព្រះរាមជិះ ។ **ព្រះរាម** **ព្រះនាងសីតា** និង **ព្រះល័ក្ស** ក៏ឡើងជិះរទេះទាំងអស់គ្នាដោយ មានស្តេចពានរ **សុគ្រីវ** និង កូនទ័ពស្វាឯទៀត **វិភិសនា** និង ទីប្រឹក្សារបស់គាត់មកជាមួយផង ។ នៅពេលដែលទាំងអស់គ្នា ឡើងជិះរទេះហើយ រទេះទិព្វ **បុស្បុបក** បានហោះឡើងកាត់ពពកដោយបញ្ចេញសម្លេងយ៉ាងខ្លាំង ឆ្លងកាត់ពីលើកន្លែងដែលព្រះរាមបានដើរផ្សងព្រេង ។ នៅពេលដែលពួកគេមកដល់អាយុធ្យា **ព្រះរាម** បានចូលទៅក្នុងទីក្រុងដែលព្រះអង្គនឹងត្រូវបានរៀបចំអភិសេកជាព្រះមហាក្សត្រ ។ នៅលើរូបចម្លាក់លើផ្តែរ យើងឃើញ **ព្រះរាម** អង្គុយជាមួយ **ព្រះលក្ស** កាន់ធ្នូ និង **ព្រះនាងសីតា** នៅលើរទេះមួយដែលមានសត្វហង្សបីកំពុងហើរ ។ រូបនេះជានិមិត្តរូបនៃរទេះទិព្វ **បុស្បុបក** ដែលហោះនាំ **ព្រះរាម** ទៅផ្ទះវិញបន្ទាប់ពីបានទទួលជោគជ័យក្នុង **ការប្រយុទ្ធនៅលង្កា** ។ រូបនេះដាក់បន្ទុបលើក្បាលរាហ៊ូ ដែលអមដោយបុរស និង ស្ត្រីម្នាក់ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅលើហោជាងនៃទ្វារខាងក្នុងនៃទ្វារខាងត្បូង មានឆ្លាក់រូប «**ឧមាមហស្វរ**» គឺ រូបភាពនៃ **ព្រះសិវៈ** និង ព្រះនាង **ឧមា** ដែលមានឈ្មោះថា **បិវតី** ឬ **ទេវី** ដែលជាព្រះមហេសី ជិះលើគោ **នន្ទិ** ជាប្រធានបទដែលគេតែងតែជួបប្រទះជាញឹកញាប់ នៅក្នុងចម្លាក់លិបរបស់ខ្មែរ ។ ព្រះសិវៈត្រូវបានសិល្បៈករខ្មែរឆ្លាក់មានតែដៃពីរ ដៃមួយកាន់លំពែងមុខបី ឬ គ្រាប់ផ្គាំ ហើយដៃមួយទៀតកាន់ព្រះមហេសីរបស់ព្រះអង្គ ។ នៅក្នុងចម្លាក់លិបរបស់ខ្មែរ ព្រះនាងឧមាអង្គុយពីចំហៀងនៅលើគោ តែពេលខ្លះគេឃើញព្រះនាងបរគោដែរ ដែលមានដៃម្ខាងកាន់ផ្កាឈូក ។ មានដើមឈើមួយនៅគ្របពីលើព្រះនាង **ឧមា** និង **ព្រះសិវៈ** ដែលកំពុងជិះគោ **នន្ទិ** ។

នៅលើផ្តែរទ្វារខាងក្រោម គេឃើញមានរូបចម្លាក់ទេវរូបឈលើក្បាលសឹង្ហ ។ ទេវរូបអង្គុយលើកជង្គង់ម្ខាង ហើយដៃស្តាំកាន់ព្រះខ័ន ។ នៅសងខាងមានសឹង្ហមួយគូពាក់កម្រងផ្កាឈយ៉ាងសង្ហារ ។ នៅលើគែមទ្វារ គេឆ្លាក់ក្បាច់ផ្កាឈូក ហើយនៅខាងក្រោមមានរូបឫសីអង្គុយសំពះ ។

ថែវខាងឆ្វេង និង ថែវខាងស្តាំមានរាងចតុកោណកែង ហើយចុងរបស់វាចាក់ជិតដល់គោបុរៈតែម្តង ។ ថែវនីមួយៗត្រូវបានចែកចេញជាបន្ទប់បី ។ ជញ្ជាំងខាងក្នុងមានបង្អួចបី ដែលមានចម្រឹងថ្មចំនួន ៧ ។ នៅខាងចុងជញ្ជាំងមានទ្វារសម្រាប់បូនីយជនអាចចូលទៅកាន់បន្ទប់ចុងបំផុត ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia













fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia



















### ៣.១.៤.៣. ១. វិថីឆ្ពោះទៅកាន់គោបុរៈទី ២



នៅទល់មុខព្រះបរមរាជវាំង មានព្រះលានដ៏ធំមួយ ដែលមានលក្ខណៈស្រដៀងនឹងព្រះលាននាគរាជនៅមុខគោបុរៈ ទី ៥ ដែរ ដែលប្រើប្រាស់ជាវិថីឆ្ពោះទៅកាន់គោបុរៈទី ២ ។ នៅខាងអមសងខាងវិថីនេះ នៅខាងក្រៅមាននាគរាជក្បាលប្រាំពីរមួយគូរ សណ្ធូកតាមបណ្ដោយនៃព្រះលាន និង ខាងក្នុងមានដាំបង្គោលសីមា ដូចវិថីដ៏ទៃទៀតដែរ ។



### ៣.១.៤.៤. គោបុរៈទី ២



**រូបគំនូរនៃគោបុរៈទី ២ ដោយលោក ហង់រី ប៉ារម៉ង់ទីយេ**

នៅចុងវិថីនេះ មានជណ្តើរឡើងគោបុរៈទី ២ ដែលមានរាងជាកាកបាទ ។ នៅអមសងខាងគោបុរៈទី ២ មានសាល ដែលមានរាងជាកែង (ឬ អក្សរអ៊ិល (L)) ដែលសាងសង់ឡើងរបៀបជាថែវព័ទ្ធជុំវិញ ។ នៅចំកណ្តាលទីធ្លានៃគោបុរៈទី ២ មានប្រាសាទមួយយ៉ាងធំ ដែលគេហៅថា **ម៉ាន់ដាផា** (Mandapa) ដែលលោក **ហ្សក សឺដែស** យល់ឃើញថាគឺជា «*សិល្បៈនៃរចនាបថដើមសម័យអង្គរ ដែលមានឥទ្ធិពលខ្លះពីសិល្បៈនៃរចនាបថបាពួន*» ។

ក្រុមប្រាសាទទាំងនេះ មាន គោបុរៈកណ្តាល ថែវខាងឆ្វេង និងថែវខាងស្តាំ ប្រាសាទពន្លា **ម៉ាន់ដាផា** និងសាលាធមិខាងឆ្វេង និងខាងស្តាំ ។ ផ្តែរភាគច្រើននៃគោបុរៈនេះ មានលម្អដោយក្បូរក្បាច់រចនាជារុក្ខជាតិ ដែលមានទេវរូបមួយអង្គអង្គុយលើរាហ៊ូ ឬ កល ដៃកាន់ព្រះខ័នលើកឡើងលើ ។

**គោបុរៈខាងមុខ** មានរាងកាកបាទ ដែលមានច្រកទ្វារចំនួន ៤ បែមុខទៅគ្រប់ទិស ។ ទ្វារខាងជើង និងខាងត្បូងមានបង្អួចពីរ ។ ចំណែកឯច្រកទ្វារខាងជើង និង ខាងត្បូងមានទ្វារពីរ និង មានបង្អួចមួយដែលមានចម្រឹងថ្មចំនួន ៥ ។ សាលកណ្តាលមានបង្អួចប្រាំមួយ លើជញ្ជាំងខាងជើង និង បង្អួចចំនួន ៤ ដែលមានចម្រឹងថ្មចំនួន ៥ នៅជញ្ជាំងខាងត្បូង ។ ទ្វារទាំងអស់នេះមានក្បូរក្បាច់រចនារុក្ខជាតិ ដែលមានទេវរូបមួយអង្គអង្គុយលើរាហ៊ូ ដោយដៃកាន់ព្រះខ័នលើកឡើងលើ ។ នៅលើបង្កោលសសរទាំងសងខាងមានសិលាចារឹកខ្មែរជំនាន់ព្រះបាទ**សូរ្យវរ្ម័នទី ១**។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia









**ថែវខាងស្តាំ និង ថែវខាងឆ្វេង**- មានរាងជាចតុកោណជាប់នឹងទ្វារខាងកើត និង ទ្វារខាងលិច នៃគោបុរៈខាងមុខ ដែលមានជញ្ជាំងគ្មានបង្អួច ។



**ប្រាសាទពន្លា ម៉ាន់ដាផា** មានរាងជាចតុកោណកែង ដែលមានទ្វារមុខ ។ ពន្លានេះមានបង្អួចបីនៅសងខាង ដែលមានចម្រឹងថ្ម ចំនួន ៥ ។ នៅកណ្តាលវិហារកណ្តាលមានសសរពីរជួរ ហើយមួយជួរមានសសរចំនួន ៤ ។ កម្រាលខាងក្រោមនៃវិហារកណ្តាលមានសភាពល្អស្អាតជាងកន្លែងដ៏ទៃទៀត ។ រូបចម្លាក់មានក្បូរក្បាច់ជារុក្ខជាតិ និង មានក្បាច់រាងជាផ្កាឈូក ។ **ម៉ាន់ដាផា** គឺជាស្ថាបត្យកម្មឥណ្ឌាបុរាណ ដែលជា **ពន្លា** ដែលមានសសរច្រើន សម្រាប់ជាទីសក្ការៈបូជារបស់សាសនិកជន ហើយដែលតភ្ជាប់ទៅនឹងប្រាង្គប្រាសាទកណ្តាល ។ គេប្រើប្រាស់ **ម៉ាន់ដាផា** សម្រាប់លេងភ្លេង រាំបន់ស្រន់ដល់អាទិទេព ឬ សម្រាប់រៀបចំពិធីខាងផ្នែកសាសនា ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



រូបគំនូរនៃ ម៉ាន់ដាផា ដោយលោក ហង់រី ប៉ារម៉ងទីយេ





### ៣.១.៤.៤.១. បណ្ណាល័យ

នៅខាងឆ្វេង និង ខាងស្តាំនៃប្រាសាទពន្លា **ម៉ាន់ដាផា** តាមផ្លូវចូលគោបុរៈទី ១ មានបណ្ណាល័យចំនួនពីរទល់មុខគ្នា ដែលមានដំបូលប្រក់ក្បឿងបីជាន់ ដែលបុព្វបុរសខ្មែរជំនាន់ដើមប្រើប្រាស់ដើម្បីដម្កល់ទុកនូវគម្ពីរសាសនាសំខាន់ៗ ។ នៅលើហោជាងខាងក្រោម និង នៅលើផ្តែរនៃបណ្តាល័យខាងកើត (នៅខាងស្តាំដៃ) មានរូបចម្លាក់ «**ព្រះឥន្ទ្រជិះដំរីក្បាលបី**» ។ ចំណែកឯរូបចម្លាក់នៅលើហោជាង និងផ្តែរនៃបណ្តាល័យខាងលិច (នៅខាងឆ្វេងដៃ) ក៏មានរូបចម្លាក់ដូចនៅលើហោជាង និង ផ្តែរនៃបណ្តាល័យខាងកើតដែរ ។



### ៣.១.៤.៥. គោបុរៈទី ១

បន្ទាប់ពីចូលទៅក្នុងគោបុរៈទី ១ យើងឃើញមានប្រាង្គប្រាសាទមួយនៅចំកណ្តាលទីធ្លា ដែលនៅខ្ពស់ជាងគេ សម្រាប់ជា **និវេសនដ្ឋានរបស់ព្រះអាទិទេព** ដែលជាកន្លែងសក្ការបំផុតសម្រាប់លទ្ធិទេវរាជ ។ បន្ទាប់ពីការរៀបចំអភិសេក **សិវលិង្គ** រួចមក អាត្មន់ពិសិដ្ឋរបស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុងសិវលិង្គនេះ ដែលជាតំណាងព្រះឥសូរផង និងជាតំណាងព្រះរាជាផង និងត្រូវគេយកទៅតម្កល់លើ ព្រះវិហារនេះឯង ។ ដូច្នេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយទើបព្រះបាទ **យសោវរ្ម័នទី ១** បានរៀបចំកសាងប្រាសាទព្រះវិហារនេះឡើងនៅសតវត្សទី ៩ ដើម្បីឧទ្ទិសថ្វាយដល់ព្រះអាទិទេពភ្នំ គឺ**សិខរិស្វរ** ។ **សេវលិង្គ** នេះត្រូវដម្កល់នៅប្រាង្គកណ្ដាល ដែលគេចាត់ទុកថានៅចំស្នូលនៃចក្រវាល ។ ព្រះមហាក្សត្រខ្មែរ ក្រោយពីការធ្វើពិធីអភិសេក «**ពិធីទេវរាជ**» នេះហើយ ព្រះរាជាក៏មានឋានៈជា**ចក្រវាតិន** (ស្ដេចចក្រវាល) ដែលជាព្រះឥស្សរបែងភាគដែលមានអំណាចអាចគ្រប់គ្រង ទៅលើសព្វសត្វ ហើយបញ្ជារបស់ព្រះរាជា គឺជាបញ្ជារបស់អាទិទេព ។ ទីសក្ការៈបូជាចុងក្រោយនេះ មានគោបុរៈខាងមុខ **គទល័យ** ថែវខាងឆ្វេង ថែវខាងស្ដាំ និងគោបុរៈខាងក្រោយ ។

គោបុរៈខាងមុខមានរាងចតុកោណកែង ដែលមានទ្វារមុខ និង ទ្វារក្រោយ ។ ដំបូលពីមុនមានប្រក់ក្បឿង។ ជញ្ជាំងខាងជើងមានទ្វារបី ។ ទ្វារកណ្ដាលភ្ជាប់ទៅនឹងផ្លូវដែលនាំទៅដល់ផ្លូវខាងក្រោយនៃប្រាសាទកណ្ដាល **ម៉ាន់ដាផា** នៃគោបុរៈទី ២ ។ រូបចម្លាក់នៅលើហោជាង និង នៅលើផ្ដែរនៃទ្វារទាំងពីរ មានរូបទេវរូបលុតជង្គង់លើក្បាលរាហ៊ូ ។ គោបុរៈនេះមានបង្អួច ចំនួន ៤ ដែលមានចម្រឹងថ្ម ។ នៅតាមជញ្ជាំងខាងត្បូង មានទ្វារចំនួន ៤ ដែលអាចឱ្យគេឆ្លងទៅព្រះលាននៃ **គទល័យ** ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



**គទលំយ** គឺជាប្រាង្គប្រាសាទកណ្ដាល ដែលមានថែវព័ទ្ធជុំវិញ ។ ថែវព័ទ្ធប្រាង្គនេះភ្ជាប់ទៅនឹងប្រាសាទពន្លា **ម៉ាន់ដាផា** ដែលនៅខាងមុខទិសខាងជើង ។ ជើងទម្រនៃ **គទលំយ** និង **ម៉ាន់ដាផា** មានឆ្លាក់ក្បូរក្បាច់រចនាដូចគ្នា ។ ប្រាង្គកណ្ដាលនេះនៅមានសភាពល្អ តែពាក់កណ្ដាលប៉ុណ្ណោះ ។ មួយកំណាត់ខាងក្រោយបាក់បែកខ្ទេចខ្ទីអស់ហើយ នៅសល់តែគំនរថ្មកំពស់ជាងបីម៉ែត្រ ។ មួយកំណាត់ខាងមុខដែលនៅល្អមានទ្វារបី គឺទ្វារមុខខាងជើង ទ្វារចំហៀងខាងកើត និងទ្វារចំហៀង ខាងលិច ។ នៅលើហោជាងនៃទ្វារមុខទិសខាងជើងយើងឃើញមានរូបចម្លាក់ «**ព្រះសិវៈរាំ**» យ៉ាងសង្ហារ ។ **ព្រះសិវៈ** នេះ មានដៃចំនួន ១០ ។ ដៃស្ដាំពីរខាងលើលើកដៃសំពះពីលើក្បាល ។ ដៃស្ដាំពីរខាងក្រោមកាន់ដំបងមួយយ៉ាងវែង ដែលអាចជាស្នមុខបី ។ ក្នុងចំណោមដៃឆ្វេងរបស់ព្រះសេវៈ មានតែដៃបីប៉ុណ្ណោះដែលនៅសេសសល់ ចំណែកដៃពីរទៀតបែកបាក់បាត់ទៅហើយ ។ កាយវិការដ៏ចម្លែកនៃរូបចម្លាក់នេះ គឺព្រះសិវៈរាំនៅលើក្បាលដំរីមួយ ដែលមានក្បាលធំ ស្លឹកត្រចៀកឡើងបើកកំប៉ាង ហើយប្រមោយរបស់វាដាក់លើក្បាលរបស់រាហ៊ូ ដែលពាំកម្រងផ្កា ។ រូបចម្លាក់នេះអាចពិពណ៌នាពីទេវកថាពាក់ព័ន្ធនឹងព្រះសិវៈសម្លាប់ **គជសុរៈ** គឺជាអសុរៈដែលប្រែក្រឡាខ្លួនជាដំរី ។ នៅព័ទ្ធជុំវិញព្រះសិវៈ គេឃើញមានក្បូរក្បាច់រចនាតាមលក្ខណៈរុក្ខជាតិសម្រាប់លម្អហោជាង ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



នៅលើផ្តែរខាងក្រោម គេឃើញមានទេវរូបអង្គុយលើក្បាលរាហ៊ូ ដែលចាប់ជើងសត្វមករ ដែលបៀមសំណុំស្លឹកឈើមានមែកសាខា ដែលជាក្បាច់រចនាដ៏ប្រណីតលម្អ **ទវល័យ** នេះ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



ថែវខាងឆ្វេង និង ថែវខាងស្តាំត្រូវបានសាងសង់ឡើង ដើម្បីភ្ជាប់ជញ្ជាំងនៃទ្វារខាងមុខ និង ទ្វារខាងក្រោយនៃគោបុរៈខាងមុខ ជាមួយនឹងជញ្ជាំងនៃទ្វារខាងមុខ និង ទ្វារខាងក្រោយនៃគោបុរៈខាងក្រោយ ។ កំពែងថែវនេះ ម្ខាងមានជញ្ជាំងបិទជិត ហើយម្ខាងទៀតមានទ្វារ សម្រាប់ចេញចូលទៅកាន់ **ភវាល័យ** ។ ហោជាង និងផ្តែរនៃថែវនេះមានរូបចម្លាក់ទេវរូបអង្គុយបឈ្លួជង្គង់ ។ ក៏ប៉ុន្តែ នៅលើទ្វារបញ្ឆោតទាំងបួនខាងនៃជញ្ជាំងខាងក្រៅជាប់នឹងទ្វារខាងមុខ និងទ្វារខាងក្រោយនៃគោបុរៈខាងមុខ និង គោបុរៈខាងក្រោយ ក៏មានរូបចម្លាក់ទេវរូបដែរ តែមានថែមក្បាលរាហ៊ូនៅពីក្រោមទេវរូបទៀត ។ ក៏ប៉ុន្តែ មានករណីលើកលែងចំពោះហោជាងនៃទ្វារជាប់នឹងទ្វារខាងជើងនៃគោបុរៈខាងមុខ គេឃើញមានរូបចម្លាក់នៃទេវរូបរាំកណ្តាលក្បាលនៃនាគរាជចំនួនប្រាំមួយ ។ ជញ្ជាំងខាងក្នុងនីមួយៗមានបង្អួចចំនួន ២០ តែគ្មានទ្វារ ឬ ជណ្តើរឡើយ ។ ដំបូលនៃថែវខាងឆ្វេង និង ថែវខាងស្តាំមានប្រក់ថ្មភក់រាងរួញអង្កាញ់ៗ ដូចជាក្បឿង ។ នៅលើផ្តែរនៃទ្វារបញ្ឆោតខាងក្រៅផ្នែកឥសាន្តនៃថែវ មានចម្លាក់ «**ព្រះគ្រិស្នៈបង្ក្រាបនាគរាជ កលិយ**» ដូចនៅគោបុរៈទី ៤ ដែរ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia















ផ្តែរនៅលើទ្វារខាងលិច នៅមានសភាពល្អដូចដើម ។ នៅលើផ្តែរនេះ គេឃើញមានរូបចម្លាក់ទេវរូបអង្គុយលើកជង្គង់ម្ខាង ដែស្តាំកាន់ព្រះខ័ន ហើយអង្គុយលើក្បាលរាហ៊ូ ដែលកាន់សំណុំផ្កា និងមែកឈើដែលខ្ជាក់ចេញពីមាត់មក ដែលជាក្បាច់លម្អផ្តែរ ដែលយើងឃើញជាញឹកញាប់ ។





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia















fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia











fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia





















## ៣.២. ពយតាឌី



នៅខាងក្រៅកំពែងថែវព័ទ្ធជុំវិញ **ឥចល័យ** គេឃើញមានប្រាសាទពីរទៀតនៅអម ។ នៅពីក្រោយកំពែងថែវ **ឥចល័យ** មានព្រះលានថ្ម ដែលមានទំហំ ៤៤ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ដែលមានជម្រាលឡើងលើ ។ គឺនៅកន្លែងនេះហើយដែលគេឃើញមានរានទេវតា និងកន្លែងសម្រាប់បន់ស្រន់ដល់តាឌី ដែលប្រជាជនយើងមានជំនឿថាមានអំណាចស័ក្តិសិទ្ធិក្រៃលែង ។ បើមើលទៅក្រោម យើងឃើញនូវវាលទំនាបខ្មែរយ៉ាងស្រស់បំព្រងគួរជាទីបេតី។ ទេសចរដែលឈរនៅលើថ្មត្រង់ **ពយតាឌី** មានអារម្មណ៍ថាហាក់បីដូចជាហោះនៅលើអាកាសវេហាស៍ដូច្នេះដែរ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia















# ឯកសារពិគ្រោះ

## ១- ឯកសារជាស្នាដៃនិពន្ធ

### ក. ឯកសារជាភាសាខ្មែរ

**១- ត្រឹង ងា (លោក):** ***ប្រវត្តិសាស្ត្រខ្មែរ (ពីដើមដល់ការបោះបង់ក្រុងអង្គរ)*** ភាគទី ១ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ភ្នំពេញ ឆ្នាំ ២០០៨

**២- ត្រឹង ងា (លោក):** ***ប្រវត្តិសាស្ត្រខ្មែរ (ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស)*** ភាគទី ២ គ្រឹះស្ថាន បោះពុម្ពផ្សាយអង្គរ ភ្នំពេញ ឆ្នាំ ២០០៨

**៣- ត្រឹង ងា (អ្នកស្រី):** ***អរិយធម៌ខ្មែរ*** គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ ភ្នំពេញ ឆ្នាំ ២០០៨

**៤- ដេវិឌ ឆាណ្ឌលឺរ:** ***ប្រវត្តិសាស្ត្រខ្មែរ*** ចេញផ្សាយលើកទី២ ភ្នំពេញ ឆ្នាំ ២០០៥

**៥- ម៉ៃណារ ហ្វីលីប ហ្វ្រេឌ្គ្លាសលីយេ:** ***ទីក្រុងអង្គរ ជំហរអារ្យធម៌ខ្មែរ*** មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ភ្នំពេញ ឆ្នាំ ២០០៣

**៦- មីសែល ត្រាណេ:** ***វប្បធម៌ អារ្យធម៌ អង្គរបុរី ពីស.វ.ទី១ ដល់ ស.វ.ទី ៦ នៃ គ.ស.*** ភ្នំពេញ ឆ្នាំ

**៧- មីសែល ត្រាណេ:** ***ប្រវត្តិសាស្ត្រនៃកម្ពុជា: អាណាចក្រចេនឡា (ស.វ.ទី៦ ដល់ ទី៨)*** ភ្នំពេញ ឆ្នាំ ១៩៩៨

**៨- មីសែល ត្រាណេ:** ***ប្រវត្តិសាស្ត្រនៃកម្ពុជា: អាណាចក្រភ្នំ (ស.វ.ទី១ ដល់ ទី៦)*** ភ្នំពេញ ឆ្នាំ ២០០២

**៩- មីសែល ត្រាណេ:** ***ប្រវត្តិសាស្ត្រនៃកម្ពុជា: សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧*** ភ្នំពេញ ឆ្នាំ ២០០៣

**១០- មីសែល ត្រាណេ:** ***វប្បធម៌ អារ្យធម៌ខ្មែរ: អំពីសាសនាខ្មែរតាំងពីសម័យបុរេប្រវត្តិសាស្ត្រ (សង្ខេប)*** ភ្នំពេញ ឆ្នាំ ២០០៤



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**១១- មីសែល ត្រានេ:** ***ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា: ចក្រភពកម្ពុជទេស ពីស.វ.ទី ៩ ដល់ ស.វ.ទី ១៣ នៃគ.ស.*** ភ្នំពេញ ឆ្នាំ ២០០៦

**១២- មីសែល ត្រានេ:** ***មតិកវប្បធម៌មន- ខ្មែរ: តាមរយ:សិល្ប: និងបុរាណវិទ្យា ភាគ ១*** ភ្នំពេញ ឆ្នាំ ២០០៦

**១៣- មីសែល ត្រានេ:** ***អំពីប្រភពវប្បធម៌ខ្មែរ*** ភ្នំពេញ ឆ្នាំ ២០០៨

**១៤- មីសែល ត្រានេ:** ***ប្រាសាទភ្នំព្រះវិហារ: ស្ថាបត្យកម្មប្រាសាទបុរាណខ្មែរ*** សាកលវិទ្យាល័យ ន័រតុន ភ្នំពេញ ឆ្នាំ ២០០៩

**១៥- អាដេម៉ារ ឡឺក្លែរ:** ***ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជមក*** បណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ ២០០៤

**១៦- ហ្សក គ្រោស្លីយេ:** ***គំនូរខ្មែរទាំង ៧៦*** មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ភ្នំពេញ ឆ្នាំ ២០០៣

**១៧- ចាន់ ស៊ីម:** ***សៀវភៅជំនួយស្មារតី សម្រាប់រៀនគូរ និង ចម្លាក់ដោយខ្លួនឯង*** ២ ភាគ ភ្នំពេញ គ្មានឆ្នាំ

**១៨- ថាច់ ម៉ាន់ផាត និង កែវ សុគុន:** ***អាទិទេពក្រុងអង្គរ*** ភ្នំពេញ គ្មានឆ្នាំ

**១៩- មួង សគុណារី:** ***នយោបាយ និងសេដ្ឋកិច្ច ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១*** សារណាក្នុងការបំពេញយកបរិញ្ញាប័ត្របុរាណវិទ្យា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្ប: ភ្នំពេញ ឆ្នាំ ២០០៦

## ខ. ឯកសារជាភាសាបរទេស

*Angkor et dix siècles d'art khmer*. Réunion des Musées Nationaux. Paris 1997, English version: Angkor and ten centuries of Khmer Art, National Galery of Art, Washington, 1997.

Aymonier, Étienne. *Le Cambodge,* 3 vols, Paris, 1900-1904; An English version: *The Khmer Heritage in Thailand*, translated by W.E.J. Tips, White Lotus Press, Bangkok, 1999.

Barth, August. *Œuvres*, vol. I, Paris, 1914.

— et Bergaingne, Abel. *Inscriptions sanskrites du Champa et du Cambodge,* Paris, 1885-93.

Bernon, Olivier de, 'A propos du retour des bakous dans le palais royal de Phnom Penh' in



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*Études thématiques 6, Renouveaux religieux en Asie*, EFEO, Paris, 1997, pp. 33-58;
— 'Le Buddh Damnây', note sur un texte apocalyptique khmer' *BEFEO 81*, 1994, pp. 83-96;
— 'Note sur l'hydraulique théocratique angkorienne', *BEFEO 84*, 1997, pp. 340-348;
— 'Le plus ancien édifice subsitant de Phnom Penh: une tour ankorienne sise dans l'enceinte de Vatt Unnalom' *BEFEO 88*, 2001, pp. 248-60;

Bizot, François, (éd.) 'La consécration des statues et le culte des morts' in *Recherches nouvelles sur le Cambodge*, pp. 101-39, EFEO, Paris, 1994.

Bhattacharya, Kamleswar, *Les religions brahmaniques dans l'ancien Cambodge, d'après l'épigraphie et l'iconographie,* EFEO 49, Paris, 1961.

Boisselier, Jean, *Le Cambodge,* Paris, éd. Picard, 1966;
— *La statuaire du Champa,* EFEO, Paris, 1963;
— *Tendances de l'art khmèr: Commentaires sur 24 chefs-d'œuvre du Musée de Phnom Penh,* Presse Universitaires de France, Paris, 1956;
— *Studies on the Art of Ancient Cambodia,* Translated and edited by Natasha Eilenberg and Robert Brown. Reyum Publishing, Phnom Penh, 2008.

Briggs, L.P. *The Ancient Khmer Empire*, White Lotus Press, Bangkok, 1999.
— *The Genealogy and Successors of Sivacharya. Supression of the Great Sacerdotal Families by Suryavarman I.*

Chandler, David P., *A History of Cambodia,* Westview Press, Boulder, also Oxford UK, 1993;
— *The Land and People of Cambodia,* Harper Collins Publishers, New York, 1991;
— *Facing the Cambodian Past,* Silkworm Books, Chaiang Mai, 1996.

Clark, J. *Bayon: New Perspectives*, River Books, Bangkok, 2007.

Coedès, George, *Articles sur le pays Khmer,* EFEO, Paris, 2 vols, 1989 and 1992;
— *Les états hindouisés d'Indochine et d'Indonésie,* Paris, 1948, reprinted by Editions E. de Boccard, Paris, 1964; An English version: *The Indianized States of South-East Asia,* East-West Center Press, 1968.
— *Inscription du Cambodge*, 8 vols, EFEO, 1937-1966;
— 'Les stèles de Sdok Kak Thom, Phnom Sandak et Prah Vihar' BEFEO 43, p. 56ff. (APKh II, pp. 167-265);
— *Un Grand Roi du Cambodge—JAYAVARMAN VII*; traduit du français en cambodgien par Kromkar Choum Mao, Éditions de la Bibliothèque Royale, 1935.
— *Les peuples de la péninsule indochinoise: Histoire et civilisation,* Dunod, Paris, 1962; reprint, Cedoreck, 2001.

Coral-Rémusat, G. de, *L'Art khmer. Les grandes étapes de son évolution*. Études d'art et d'éthnologie asiatiques I, Paris, 1951 (2 ème édition).

Dagens, Bruno, *Les Khmers,* Les Belles Lettres, Paris, 2003;
— 'Étude sur l'inconographie du Bayon (frontons et linteaux)' *Arts Asiatiques,* 1969,


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

pp. 123-67;
— *Traités, temples et images du monde indien: Études d'histoire et d'archéologie; Articles rassemblés par M.-L. Barazer-Billoret et V. Lefèvre,* Institut Français de Pondichéry et Presses Sorbonne Nouvelle, Paris, 2005.

Dalsheimer, Nadine, *Les collections du musée national de Phnom Penh: L'art du Cambodge ancien,* EFEO, Paris, 2001.

Delaporte, Louis, *Voyage au Cambodge,* Librairie Delagrave, Paris, 1880; republié par Maissonneuve & Larose, Paris, 1999.

Dumarçay, Jacques, *Histoire architecturale du temple du Bayon.* PEFEO, 1973;
— 'L'hydrolique khmère' in *Angkor et dix sciècles d'art khmer*, pp. 93-100.

Finot, Louis, 'Dharmaçâla au Cambodge' *BEFEO 25,* pp. 417-22;
— 'L'Inscription de Preah Khan' *BEFEO 4,* pp. 672-5;
— 'L'Inscription d'Angkor' *BEFEO 25,* pp. 289-407;
— *L'origine d'Angkor,* Éditions de l'institut bouddhique, Phnom Penh, 1956.

Finot, Parmentier et Goloubew, *Le temple d'Içvârapura,* Mémoires archéologiques, EFEO, Paris 1926, translated by J.H. Stape, *A Guide to the Temple of Banteay Srei,* White Lotus Press, Bangkok, 2000.

Frédéric, Louis, *La vie quotidienne dans la péninsule indochinoise à l'époque d'Angkor (800-1300),* Hachette, Paris, 1981.

Giteau, Madelaine, *Iconographie du Cambodge post-Angkoréenne,* EFEO, Paris, 1975;
— *Histoire du Cambodge,* Didier, Paris, 1957;
— *Histoire d'Angkor,* Kailash Éditions, Paris, 1999.

Glaize, Maurice, *Les Monuments du Groupe d'Angkor*, Adrien-Maisonneuve, Paris, 1963; new edition 1993, entitled *Angkor.*

Goloubew, Victor, 'Le cheval Balaha' *BEFEO 27,* pp. 223-38;

Grenier, François, 'Chronique royale du Cambodge' *JA 18, 1871, pp. 36-85* and *JA 20, 1872, pp. 112-44.*

Groslier, Bernard P., *Angkor et le Cambodge au XVIe sciècle d'après les sources portugaises et espagnoles,* Pris, 1958; An English version: *Angkor and Cambodia in the Sixteenth Century According to Portuguese and Spanish Sources,* Orchid Press, Bangkok, 2006;
— *Indochine, carrefour des arts,* Albin Miche, Paris, 1961;
— 'Étude sur le temps passé à la construction d'un grand temple khmer' *BEFEO XXXV,* PP. 57-68;
— 'Inscription du Bayon' EFEO, Paris, 1973;
— 'Mélanges sur l'Archéologie du Cambodge' EFEO, Paris, 1997.


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Guillon, Emmanuel, *Cham Art,* River Books, Bangkok, 2001;
— *The Mons, a civilization of Southeast Asia,* English translation from the French by James V. Di Crocco, The Siam Society, Bangkok, 1999;

Higham, Charles, *The Civilization of Angkor,* Weidenfeld & Nicolson, 2001.

Ishizawa, Yoshiaki and Marui, Masako, 'La découverte de 274 sculptures et d'un caitya bouddhiques lors des campagnes de fouilles de 2000 et 2001 au temple de Banteay Kdei à Angkor', *Arts asiatiques,* 57, 2002, pp. 206-17.

Jacob, Judith, *The traditional literature of Cambodia,* OUP, London, 1996;
— and Kuoch Haksrea, trans., *Reamker, The Cambodian Version of the Ramayana,* RAS, London, 1986;

Jacques, Claude. 'La carrière de Jayavarman II' *BEFEO 59,* pp. 205-20;
— 'L'emplacement d'Aninditapura & la carrière de Jayavarman II' *BEFEO 59,* pp. 193 -220;
— 'Les noms posthumes des rois dans l'ancien Cambodge' in *Fruits of Inspiration,* eds. Klokke, M and Erbert Groningen van Kooij. Forsten, 2001, pp. 1991-8;
— Angkor, Bordas, Paris, 1990.
— 'Études d'épigraphie cambodgienne. La stèle du Baphuon, K583', *BEFEO 63,* 1976, pp. 351-368;
— (ed.) *Études épigraphiques sur le pays Cham* de Louis Finot, Édouard Huber, George Coedès et Paul Mus, *EFEO,* Paris, 1995;
— and Michael Freeman, *Angkor, Citadels and Palaces,* River Books, Bangkok, 1997; French edition: *Angkor: Résidences des dieux,* Éd. Olizane, Geneva, 2001.

— and Lafond, P., *The Khmer Empire: Cities and Sanctuaries from the 5th to the 13th Century*. River Books. Bangkok, 2007.

Keo, Pich et Nicola Smith, *La Statuaire Khmère en Pierre: miniguide des principaux styles d'art khmer à travers les scultures,* Musée National du Cambodge, Phnom Penh, 1996.

Khin Sok, *L'annexation du Cambodge par les Vietnamiens au XIXe siècle d'après les deux poèmes du vénérable Batum Baramey Pich,* You Feng, Paris, 2002;
— *Histoire du Cambodge de la fin du XVIe au début du XVIIIe,* EFEO, Paris, 1995;
— *Le Cambodge entre le Siam et le Vietnam (de 1775—1860),* EFEO, Paris, 1991;
— *Chroniques royales du Cambodge (de Bana Yat à la prise de Lanvaek),* EFEO, Paris, 1988.

Khoo, James, (ed.) *Art and Archaeology of Fu Nan: Pre-Khmer Kingdom of the Lower Mekong Valley*, Orchid Press, Bangkok, 2003.

Khun Samen, *Prasat Preah Vihear,* Japan Printing House, Phnom Penh, 2008;
— *The New Guide to the National Museum Phnom Penh,* Printing House Ariyathoar, Phnom Penh, 2006.

Klairung Amratisha, *The Cambodian novel, a study of its emergence and development,* presented for



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

the degree of Doctor of Philosophy of the University of London (School of Oriental and African Studies), 1998.

Leclère, A., *Cambodge: fêtes civiles et religieuses,* Imprimerie nationale, Paris, 1916;
— *Histoire du Cambodge*, Paris, 1914.

Le Bonheur, A. *Angkor: Temples en Péril*, Herscher, 1989

Lunet de Lajonquière, É. *Inventaire descriptif des monuments du Cambodge*, Tome I et II, Phnom Penh, 2003.

Malleret, Louis, 'L'archéologie du delta du Mékong: L'exploration archéologique et les fouilles d'Oc-éo.' Paris: PEFEO: XLIII-1, 1959;
— L'archéologie du delta du Mékong: L'exploration archéologique et les fouilles d'Oc-éo. Paris: PEFEO: XLIII-2. 1960
— L'archéologie du delta du Mékong: La culture du Fou-nan. Paris: PEFEO: XLIII-3. 1962
— L'archéologie du delta du Mékong: Le Cisbassac. Paris: PEFEO: XLIII-4. 1963.

Marchal, Henri, 'Kutîsvara' *BEFEO 37,* pp. 333-46;
— 'Le dégagement de Prasad Kok Po' *BEFEO 37,* pp. 361-78.

o'Naghten, Hedwige Multzer, *Les Temples du Cambodge: Architecture et Espace sacré,* Geuthner, Paris, 2000.

Parmentier, Henri, *L'Art khmer primitif*. Paris: PEFEO, 1927;
— *History of Khmer Architecture*. Eastern Art 3:141-179; 1931;
— Complément à l'art khmèr primitive. BEFEO 35, 1935;
— *L'art architectural Hindou dans l'Inde et en Extrême-Orient*. Paris: Van Oest, 1948.

Roveda, Vittorio, *Khmer Mythology,* Bangkok, 1997;
— *Preah Vihear,* River Books, Bangkok, 2000;
— *Sacred Angkor: The Carved Reliefs of Angkor Wat, photography by Jaro Poncar,* Thames Hudson (London) and River Books, Bangkok, 2002.

Sakar, H.B. *Cultural Relations between India and Southeast Asia Countries,* Delhi, 1985.

Sak-Humphry, Chhany, *The Sdok Kak Thom Inscription,* with assistance of Philip N. Jenner, The Editions of the Buddhist Institute, Phnom Penh, 2005.
Saveros Lewitz, 'Inscriptions modernes d'Angkor' *BEFEO 59,* 1972, pp. 101-21 et 211-49;
— 'Les inscriptions modernes d'Angkor Vat' *JA 260,* 1972, pp. 105-29;
— 'Texte en Khmer moyen: inscriptions modernes d'Angkor 2 & 3' *BEFEO 57,* pp. 99-126;

Saveros Pou, *Nouvelles inscriptions du Cambodge*, vol 1. EFEO, Paris, 1989;
— *Nouvelles inscriptions du Cambodge*, vols 2 et 3. EFEO, Paris, 1996;
— et Philip N. Jennar, 'Les Cpap ou 'codes de conduite khmère', *BEFEO 62,* 1975,



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

pp. 369-94.

Seidenfaden, Erick, 'Complément à l'inventaire descriptif des monuments du Cambodge pour les quatre provinces du Siam oriental' *BEFEO 22,* pp. 55-99;
Skilling, Peter, 'The advent of Theravâdin Buddhism to mainland South-East Asia' *JIABS, 20, 1,* 1997, pp. 93-107;
— 'Buddhism in Cambodia in the Early Period', Paper read to the EFEO in Phnom Penh, early February 1997.

Smitthi Siribhadra and Mayuree Veraprsert: *Lintels: a comparative study of lintels in Cambodia and Thailand.* Siam Commercial Bank, Bangkok, 1989.

Smitthi Siribhadra, Elizabeth Moore, Michael Freeman, *Palaces of Gods, Khmer Art & Architecture in Thailand,* River Books, London, 1992.

Snellgrove, D. *Angkor Before and After: A Cultural History of the Khmers*. Orchid Press. Bangkok, 2004.

Stern, Philippe, *Le Bayon d'Angkor et l'évolution de l'art khmer*; in Étude et discussion de la chronologie des monuments khmers. Annales du Musée Guimet, Biblio. De vulgarisation, 47. Paris; Paul Geuthner, 1923;
— *La transition de l'art pré-angkoréen à l'art angkorien et Jayavarman II*. In Études d'Orientalisme. À la mémoire de Raymonde Linossier publiées par le Musée Guimet. Paris; Ernest Leroux, 1932;
— Le style de Kulen; Décor architectural et statuaire. BEFEO. 38. 1938;
— *L'art du Champa. Étude d'art et d'éthnologie asiatique*. 3. Paris: Adrien Maisonneuve. 1946

Subhadradis Diskul, M.C. (editor and contributor), *The Arts of Srîvijaya,* UNESCO, 1986.

Tranet, Michel, *Sambaur-Prei-Kuk, monuments d'Içânavarman (615-28),* vol. 1, 1995-96, vol. 2, 1996-97, vol. 3, 1998-99, fianced by the Toyota Foundation and printed in Cambodia.
— 'Adhémard Leclère: Sa vie, ses travaux' *Seksa Khmer 7,* 1984, pp. 3-33;
— *L'origine de la civilization et de la religiosité khmères,* 1981;
— *Les proto-khmer du Cambodge,* 2001.

Vann, Molyvann, *Les cites khmères anciennes,* TOYOTA Foundation, Phnom Penh, 1999.
— *Cités du Sud-est asiatique: Le Passé et le Présent,* Thèse de doctorat en Architecture de l'université de Paris 8, soutenu le 25 juin 2008.

Woodward, Hiram W., 'Practice and Belief in Ancietn Cambodia: Claude Jacques' Angkor and the *Devarâja* question' *JSAS 3(2),* pp. 249-61.

Zhou Daguan (Chou Ta-Kuan), *The Customs of Cambodia*, Bangkok, 2001.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២- ឯកសារជាស្នាដៃទស្សនាវដ្ដី ព្រឹត្តបត្រ និង សារព័ត៌មាន

### ក. ឯកសារជាភាសាខ្មែរ

**១- កេរដំណែលខ្មែរ** ទស្សនាវដ្ដីសិល្បៈ និង បុរាណវិទ្យា ឆ្នាំទី ១- លេខ ០១ មិថុនា- សីហា ២០០៩

### ខ. ឯកសារជាភាសាបរទេស

Angkor: L'art khmer au Cambodge et en Thaïlande, in Dossiers Histoire et Archéologie, *No 125, mars 1988*.

Angkor: 200 km2 de temples et de palais: Études et techniques de restauration, in Dossiers d'Archéologie, *No 221*.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia



## បណ្ឌិត ហង់ ជួន ណារ៉ុន

បណ្ឌិត **ហង់ ជួន ណារ៉ុន** បច្ចុប្បន្នជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ក.ប.ស.) និងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** បានសិក្សាសេដ្ឋកិច្ចអន្តរជាតិនៅ **សកលវិទ្យាល័យរដ្ឋគៀវ** (Kiev State University) នៅសាធារណៈរដ្ឋអ៊ុយក្រែន និង នៅ **វិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងមូស្គូ** (Moscow State Institute of International Relations)(MGIMO) ពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៩១ ។ បន្ទាប់ពីបានទទួលសញ្ញាប័ត្រអនុបណ្ឌិត និង បណ្ឌិតផ្នែកសេដ្ឋកិច្ចអន្តរជាតិនៅ **វិទ្យាស្ថានរដ្ឋទំនាក់ទំនងអន្តរជាតិនៃទីក្រុងមូស្គូ** លោកបានធ្វើការក្នុងបេសកកម្មការទូត និង នៅស្ថាប័នស្រាវជ្រាវ ជាអ្នកវិភាគសេដ្ឋកិច្ច និងនយោបាយ ។ លោកធ្លាប់ធ្វើជាទីប្រឹក្សារបស់ធនាគារពិភពលោកប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ នៅឆ្នាំ ២០០៤ លោកបានចូលរៀនក្នុងកម្មវិធីប្រតិបត្តិនៅសាលា **កេណេឌី** (JF Kennedy School) របស់រដ្ឋាភិបាលនៃសកលវិទ្យាល័យ **ហាវ៉ាដ** (Harvard University) និង នៅឆ្នាំ ២០០៨ បានទៅធ្វើកម្មសិក្សានៅ **សាលារដ្ឋបាលជាតិ** (ENA) នៅទីក្រុងប៉ារីស ។ នៅឆ្នាំ ២០០៧ លោកបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី** (MII) និង នៅឆ្នាំ ២០០៨ សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី **វិទ្យាស្ថានធានារ៉ាប់រង** (CII) នៃចក្រភពអង់គ្លេស ។ លោកជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងនៃចក្រភពអង់គ្លេស (ACII) និង ជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (AMII) ផងដែរ ។

បណ្ឌិត **ហង់ ជួន ណារ៉ុន**ធ្លាប់កាន់តំណែងជាច្រើននៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចជា អ្នកសម្របសម្រួលស្រាវជ្រាវនៃក្រុមទីប្រឹក្សាសេដ្ឋកិច្ច និង ជាអនុប្រធាននាយកដ្ឋានទី១ នៃនាយកដ្ឋានថវិកា និងហិរញ្ញកិច្ច ។ បន្ទាប់មកលោកត្រូវបានតែងតាំងជាអគ្គលេខាធិការរង ទទួលបន្ទុកគោលនយោបាយ រួមមាន គោលនយោបាយហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុសាធារណៈ អាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការវិភាគគោលនយោបាយ ក៏ដូចជាទទួលបន្ទុកខាងចរចាជាមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ។ លោកជាអ្នកនិពន្ធឯកសារគោលនយោបាយរបស់រដ្ឋាភិបាល និង សៀវភៅស្តីពីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈកម្ពុជា ។

បណ្ឌិត **ហង់ ជួន ណារ៉ុន** សមាជិក និងប្រធានក្រុមប្រឹក្សាភិបាលនៃសហគ្រាសរបស់រដ្ឋមួយចំនួន ដូចជា **ក្រុមហ៊ុនជាតិធានារ៉ាប់រងបន្តកម្ពុជា** (Cambodia Re) **ទូរគមនាគមន៍កម្ពុជា** (TC) និង **អគ្គិសនីកម្ពុជា** (EDC) ក៏ដូចជាវិទ្យាស្ថានស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល (NGO) ដូចជា **វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI) **វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍** (CBNRMLI) និង **យុវតារាកម្ពុជា** (Youth Star Cambodia) ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្នាដៃរបស់អ្នកនិពន្ធ


១- **Hang Chuon Naron**—*L'Économie du Cambodge: La lute pour le développement*, Phnom Penh, 2005

២- **Hang Chuon Naron**—*Essais économiques*, Phnom Penh, 2007

៣- **Hang Chuon Naron et Patrick Gilbert-Desvallons**—*Les finances publiques du Cambodge*, Phnom Penh, 2007

៤- **Hang Chuon Naron**—*Cambodia: Recent Macroeconomic and Financial Sector Development*, Phnom Penh, 2008

៥- **Hang Chuon Naron**—*Three Essays on Macroeconomic Management of Cambodia*, Phnom Penh, 2008

៦- **Hang Chuon Naron**—*Introduction to Insurance*, Phnom Penh, 2008

៧- **ហង់ ជួន ណារ៉ុន- ម៉ាក្រូសេដ្ឋកិច្ច** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

៨- **Hang Chuon Naron and Patrick Gilbert-Desvallons**—*Public Finance in Cambodia*, Phnom Penh: Preah Vihear Editions, 2009

៩- **ហង់ ជួន ណារ៉ុន** និង **ហ្ស៊ីលប៊ែ ដឺវ៉ាល់ឡុង- ហិរញ្ញវត្ថុសាធារណៈ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

១០- **ហង់ ជួន ណារ៉ុន- ប្រាសាទព្រះវិហារ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

**ប្រាសាទព្រះវិហារ** គឺជាស្ថាបត្យកម្មខ្មែរដ៏ល្អវិចិត្រគ្មានពីរក្នុងលោក ដែលមានលក្ខណៈជាប្រាង្គប្រាសាទច្រើនតភ្ជាប់គ្នាដោយវិថីក្រាលថ្ម និងជណ្តើរ សាងសង់នៅលើអ័ក្សប្រវែង ៨០០ ម៉ែត្រ ដោយឆ្លុះបញ្ចាំងតាមរយៈប្លង់ប្រាសាទ ចម្លាក់ក្បូរក្បាច់រចនា និងទំនាក់ទំនងទៅនឹងបរិស្ថានទេសភាពដ៏សែនអស្ចារ្យក្រៃលែង ។

**ប្រាសាទព្រះវិហារ** មានតម្លៃជាសកលលេចធ្លោ ដែលឆ្លុះបញ្ចាំងពីភាពពេញលេញរបស់ប្រាសាទ សភាពដើមរបស់ប្រាសាទ ស្នាដៃឯកកើតចេញពីទេពកោសល្យឆ្នៃប្រឌិតរបស់មនុស្សខ្មែរ តម្លៃស្ថាបត្យកម្មរបស់ប្រាសាទ និង ការតុបតែងលម្អ ដូចជាចម្លាក់ និងទេវកថាដែលពាក់ព័ន្ធ ។


**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

Phone: (855)23 722 664 Fax: (855) 23 427 798

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

២០៨ អា មហាវិថីព្រះនរោត្តម ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

Phone: (855)23 726 449 Fax: (855) 23 726 447



ISBN-9789995099022

9 789995 099022



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia